ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរក ការពិត



- ទស្សនវិស័យមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង
- សាក្សីធ្វើសក្ខីកម្មអំពីការបោសសម្អាតផ្ទៃក្នុង

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរស្រុកនិងឃុំទូទាំងព្រះរាជាណាចក្រកម្ពុជា

លេខ២០០ ខែសីហា ឆ្នាំ២០១៦

# ស្វែងរកការពិត

លេខ២០០ ខែសីហា ឆ្នាំ២០១៦

## ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

## មាតិកា


◆ ទស្សនវិស័យមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង ....................................... ១

### ផ្នែកឯកសារ

◆ ចៅ សាវ៉ាន ជាមួយសកម្មភាពប្រឆាំងបដិវត្តន៍ ....................................... ២

◆ លាង អ៊ាងម៉េង ហៅ ឡាច លាង កម្មកររោងចក្រ ....................................... ៤

◆ យុវជន-យុវនារីបដិវត្តន៍ ប្ដេជ្ញាចុះប្រឡូកធ្វើពលកម្ម ....................................... ១៤

### ផ្នែកប្រវត្តិសាស្ត្រនិងការស្រាវជ្រាវ

◆ ស្លាកសញ្ញាបង្ហាញពីទីតាំងប្រវត្តិសាស្ត្រ ....................................... ២១

◆ អតីតកាលផ្សារភ្ជាប់ជាមួយអ្នកជំនាន់ក្រោយ ....................................... ២៣

◆ សំ ចាន់ និងការរត់គេចខ្លួនដើម្បីរស់ ....................................... ២៤

◆ ជីវិតជាកងដឹកជញ្ជូនរបស់ សំ នឿន ....................................... ២៦

◆ ការតស៊ូដើម្បីរស់ ....................................... ២៨

◆ ជីវិតព្រាត់ប្រាស់ក្នុងអំឡុងពេលសង្គ្រាម ....................................... ២៩

◆ ស្ម័គ្រចិត្តដើម្បីបដិវត្តន៍ ....................................... ៣១

◆ ព្រះអង្គ សួស សំបុក ៖ "សង្គ្រាមគឺជាអំពើបាប" ....................................... ៣៣

◆ ទេព សៀក កម្មាភិបាលពេទ្យ-១ ....................................... ៣៥

◆ ចាប់ពីរបបខ្មែរក្រហម ដល់ឧប្បត្តិហេតុ ហំ បាលី ....................................... ៣៧

### ផ្នែកច្បាប់

◆ សាក្សីធ្វើសក្ខីកម្មអំពីការបោសម្អាតផ្ទៃក្នុង ....................................... ៤១

### វេទិកាពិភាក្សាសាធារណៈ

◆ ទូរថភ្លើងប្រាប់ពីអតីតកាល និងបច្ចុប្បន្នកាល ....................................... ៤៨

◆ លើកទី១សម្រាប់ខ្ញុំ សម្រាប់រយៈពេល៤៩ឆ្នាំ ....................................... ៥២

### ទំព័រស្រាវជ្រាវរកគ្រួសារ

◆ ៣ថ្ងៃ ប្រែជា ៣ឆ្នាំ ....................................... ៥៤

◆ ជីវិតពូរបស់ខ្ញុំក្នុងសម័យខ្មែរក្រហម ....................................... ៥៦

◆ រឿងរ៉ាវដែលខ្ញុំបានដឹងពីម្ដាយខ្ញុំ ....................................... ៥៨

◆ ជីវិតតស៊ូរបស់ម្ដាយខ្ញុំ ....................................... ៦០




ពូរបស់ កែវ ធារ៉ុន


## រក្សាសិទ្ធិ

មជ្ឈមណ្ឌលឯកសារកម្ពុជា



អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ
ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មាន
លេខ០២៩១ពម.៩៩
ចុះថ្ងៃទី២ ខែសីហាឆ្នាំ១៩៩៩

រូបថតឯកសារៈមជ្ឈមណ្ឌលឯកសារកម្ពុជា
និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង



***ស្នាដៃលេខនេះ ៖*** ទូន សិរីរតនា, កែវ ធារ៉ុន, ចាន់ ស្រីពៅ, ជា សុវត្ថិ, កែវ និមល, ហ៊ួន ស៊ីង៉ា, សម ចាន់មុន្នី, ផាន់ ម៉ារ៉ាឌី, រី លក្ខិណា, អេង កុកថាយ, អាលីស មើហ្គើរ, ដេង ពង្សរ៉ាស៊ី, សុខ វណ្ណៈ, គុណវុឌ្ឍ មុនីកញ្ចនា, ហ៊ុន កែវ លីដែត ***អ្នកនិពន្ធនិងស្រាវជ្រាវ ៖*** ទាវ សារៈមុនិន្ទ ***អ្នកបកប្រែ ៖*** ស៊ាង ចិន្តា ***និពន្ធនាយករងទី១ ៖*** ឆាំង យុ និង ញាណ សុជាតិ ***ជំនួយការនិពន្ធនាយក ៖*** សោម ប៊ុនថន ***ក្រាហ្វិកកុំព្យូទ័រ ៖*** សោម ប៊ុនថន ***គ្រប់គ្រងការចែកផ្សាយ ៖*** ឆេង វើង និង សន ល័ក្ខ Email: dccam@online.com.kh, Homepage: www.dccam.org, www.cambodiatribunal.org, www.cambodiasri.org

# ទស្សនវិស័យមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង

មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង ត្រូវបានបង្កើតឡើងក្នុងឆ្នាំ ២០១៥ ដោយធ្វើការផ្តល់នូវកម្មវិធីសិក្សាអប់រំ និងផ្សះផ្សាថ្នាក់សហគមន៍ផ្តោតលើការផ្សារភ្ជាប់ការបែងចែក និងការផ្តាច់ខ្លួនរវាងអតីតខ្មែរក្រហមនៅក្នុងតំបន់កាន់កាប់ចុងក្រោយរបស់គេ (អន្លង់វែង) និងប្រជាជនកម្ពុជាជំនាន់ក្រោយ ។ កម្មវិធីសិក្សានេះក៏ផ្តល់នូវបែបផែនអប់រំសម្រាប់ការសម្រាលនូវជម្លោះរវាងមនុស្ស និងការជំរុញឲ្យមានការចូលរួមពីស៊ីវិលឲ្យបានប្រសើរជាងមុន ។

គម្រោងនេះនឹងនាំយកសិស្សានុសិស្សទៅកាន់តំបន់កាន់កាប់ចុងក្រោយរបស់ខ្មែរក្រហមនៅអន្លង់វែងតាមរយៈទស្សនកិច្ចសិក្សាចំនួនបួនថ្ងៃ ដោយរួមបញ្ចូលនូវសកម្មភាពអប់រំប្រចាំថ្ងៃដែលទាមទារឲ្យមានការត្រិះរិះពិចារណា ការឆ្លុះបញ្ចាំង និងការតស៊ូមតិ ព្រមទាំងឱកាសក្នុងការធ្វើអន្តរកម្ម និងចោទសួរទៅកាន់អតីតកម្មាភិបាលខ្មែរក្រហម និងជនរងគ្រោះដែលរស់នៅក្នុងតំបន់នេះ ។ កម្មវិធីសិក្សា នេះលើកកម្ពស់ការយល់ដឹងប្រកបដោយការត្រិះរិះពិចារណាអំពីប្រវត្តិសាស្ត្រហិង្សារបស់កម្ពុជា នៅក្នុងបរិបទនៃទ្រឹស្តីប្រកួតប្រជែងនៃការដោះស្រាយ និងការកែប្រែជម្លោះ ។ ដំណើរទស្សនកិច្ចនេះ សម្រេចកម្មវត្ថុរបស់ខ្លួនតាមរយៈកិច្ចពិភាក្សាអន្តរកម្ម ការធ្វើមគ្គុទ្ទេសក៍ទស្សនកិច្ចទៅកាន់ទីតាំងប្រវត្តិសាស្ត្រក្នុងតំបន់ និងកម្មវិធីសិក្សាដែលប្រើប្រាស់រឿងរ៉ាវរបស់បុគ្គលដើម្បីបង្ហាញមេរៀនប្រវត្តិសាស្ត្រ និងសីលធម៌ ។

បន្ថែមពីលើការផ្តល់ជូនដំណើរទស្សនកិច្ចនេះ មជ្ឈមណ្ឌលគាំទ្រដល់ការសិក្សាស្រាវជ្រាវ និង ការយល់ដឹងថ្នាក់ជាតិអំពីប្រវត្តិសាស្ត្រនៃចលនារបស់ខ្មែរក្រហម តាមរយៈឯកសារបោះពុម្ពជាច្រើន បណ្ណាល័យ និងការចងក្រងឯកសារបន្តបន្ទាប់ ។ ទាក់ទងនឹងចំណុចនេះ បេសកកម្មរបស់មជ្ឈមណ្ឌល គឺមិនត្រឹមតែពង្រីកឥទ្ធិពលនៃកម្មវិធីអប់រំអំពើប្រល័យពូជសាសន៍ដែលត្រូវបានអនុវត្តនៅតាមបណ្តាសាលារៀនក្នុងប្រទេសកម្ពុជាប៉ុណ្ណោះទេ ក៏ប៉ុន្តែពង្រីកវិសាលភាពនៃចំណេះដឹងសាធារណៈអំពីប្រវត្តិសាស្ត្រនៃចលនារបស់ខ្មែរក្រហម ដែលមិនស្ថិតនៅក្នុងទំហំនៃការវិនិច្ឆ័យរបស់តុលាការខ្មែរក្រហម ។ ការស្រាវជ្រាវរបស់មជ្ឈមណ្ឌលក្តោបលើអំឡុងរបស់កម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) និងចលនារបស់ខ្មែរក្រហមនៅមុនពេលរបបនេះកាន់អំណាច និងការដួលរលំនៃរបបនេះ ។

**មជ្ឈមណ្ឌលឯកសារកម្ពុជា**



រូបថតឆ្នាំ២០១៦ ៖ មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង (អតីតទីបញ្ជាការរបស់ តាម៉ុក) នៅលើភ្នំដងរែក

# ចៅ សាវ៉ាន ជាមួយសកម្មភាពប្រឆាំងបដិវត្តន៍

*ដកស្រង់ចេញពីឯកសារចម្លើយសារភាពលេខ J០០៦៨៣*

ចៅ សាវ៉ាន មានអាយុ២៩ឆ្នាំ កើតនៅភូមិតាគ្រែ ឃុំស្រែអន្ទាក់ ស្រុកប៉ៃលិន ខេត្តបាត់ដំបង ។ នៅឆ្នាំ១៩៦៩ សាវ៉ាន បានចូលធ្វើកិញការពារភូមិ បន្ទាប់មកនៅឆ្នាំ១៩៧៤ គាត់បានចូលស៊ើបការណ៍ពីខ្មែរក្រហម និងបានធ្វើសកម្មភាពបំផ្លាញគ្រាប់រំសេវ បំផ្លាញសម្ភារកងទ័ព និងបំផុសប្រជាជនជាច្រើនគ្រួសារឲ្យរត់ចោលផ្ទះ ។



ជនរងគ្រោះនៅក្នុងរបបខ្មែរក្រហម ។ ជនរងគ្រោះទាំងនេះត្រូវបានឆ្មាំគុកសួរពីប្រវត្តិរូប និងថតរូប មុននឹងសម្លាប់

ក្រោយថ្ងៃរំដោះឆ្នាំ១៩៧៥ សាវ៉ាន បន្តបំផ្លាញសត្ពាហនៈដោយដាក់ថ្នាំបំពុល បំផុសប្រជាជនឲ្យរត់ទៅសៀម កសាងកម្លាំងក្បត់ បំផ្លាញអំបិល ស្ករ និងដំឡូងអស់ជាច្រើន រហូតដល់អន្តការចាប់ខ្លួន ។

នៅក្នុងចម្លើយសារភាព ចៅ សាវ៉ាន បានរៀបរាប់ពីប្រវត្តិសកម្មភាពក្បត់របស់គាត់ដែលបានចូលរួមជាមួយ សេ.អ៊ី.អា និងឈ្មោះអ្នកដែលពាក់ព័ន្ធនៅក្នុងសកម្មភាពក្បត់ ។ ប៉ុន្តែយើងមិនដឹងចម្លើយសារភាពនេះពិត ឬយ៉ាងណានោះទេ ព្រោះគាត់ត្រូវឆ្លងកាត់ការវាយធ្វើទារុណកម្មពីអ្នកសួរចម្លើយ ។

ខាងក្រោមនេះជាការរៀបរាប់របស់ចៅ សាវ៉ាន៖

ខ្ញុំឈ្មោះ ចៅ សាវ៉ាន បានទទួលការអប់រំពីឈ្មោះ ឡោ ហើយនៅពេលស្គាល់ឈ្មោះនេះហើយ ខ្ញុំក៏បាននាំប្អូនខ្ញុំម្នាក់ឲ្យចូលធ្វើការងារការពារភូមិដូចខ្ញុំដែរ ។ បន្ទាប់មក ខ្ញុំក៏ទៅសួរនាំពី ឡោ ថាការងារត្រូវធ្វើយ៉ាងណា? ឡោ ក៏បាននិយាយថា ការងារការពារភូមិគឺពិនិត្យមនុស្សល្អអាក្រក់នៅក្នុងភូមិ ។ នៅពេលចូលធ្វើជាកិញការពារភូមិ ឡោ បានដាក់ផែនការឲ្យធ្វើ គឺ៖

ទី១) ដើរស៊ើបការណ៍តាមភូមិដើម្បីតាមដានខ្មែរក្រហម

ទី២) ទាក់ទងរកខ្សែកិញនៅតាមភូមិឲ្យដើររកអ្នកដែលធ្លាប់ធ្វើទាហាន ធ្លាប់ធ្វើមេភូមិចាស់ដើម្បីកសាង

ទី៣) ត្រូវរក្សាការសម្ងាត់ឲ្យបានប្រសិនបែកការណ៍ពីឈ្មោះណាឈ្មោះនោះត្រូវទទួលខុសត្រូវ ។

បន្ទាប់ ខ្ញុំតែងតែរាយការណ៍ជារឿយៗអំពីសភាពការណ៍ក្នុងភូមិដីស និងភូមិអន្លង់ រួមជាមួយខ្សែកិញក្នុងភូមិ និងសភាពការណ៍ នៅភូមិផ្សេង (ភូមិព្រៃធំ) ដែលមានមនុស្សរត់ចូលព្រៃអស់មួយចំនួន ។ ខ្ញុំបានប្រាប់ ឈ្មោះ ឈរ នៅភូមិដីស ឲ្យតាមដានខ្មែរក្រហម ក្រែងលោ វាចូលមកទាក់ទងប្រជាជនក្នុងភូមិ ។

ក្រោយមកទៀត ឈ្មោះឈរ បានរាយការណ៍ប្រាប់យើងពីសភាពការណ៍នៅក្នុងភូមិ ព្រោះឃើញអ្នកភូមិប្រជុំគ្នានៅពេលយប់ ហើយបាននិយាយគ្នាថា “ថ្ងៃមុន បងប្អូនរណសិរ្សមកប្រជុំ ហើយឲ្យយើងទាំងអស់គ្នា លាក់ស្រូវអង្ករ អំបិលទុកក្នុងព្រៃ” ។ ពេលទទួល

បានព័ត៌មាននេះ ឡោ ក៏យកទាហានមកកៀរអ្នកស្រុកចំនួន១៣ គ្រួសារ ឲ្យទៅនៅភូមិឃ្លាំង ។ បន្ទាប់មកទៀត ខ្មែរគិញឈ្មោះ ឆែម បានប្រាប់ខ្ញុំពីសភាពការណ៍នៅក្នុងភូមិអន្លង់ ដោយមានមនុស្សចម្លែកចូលមកពេលយប់ ហើយពិនិត្យទៅជាក្រុមខ្មែរក្រហម ។ ក្រោយទទួលបានដំណឹង ឡោ បានយកទាហានពីបន្ទាយឃ្លាំងមកត្រៀម និងបានបាញ់សម្លាប់ប្រជាជនម្នាក់ឈ្មោះ សន ដែលទើបតែចេញមកពីកាប់ឈើ ។ ទាហានបានចាប់អ្នកស្រុកយកទៅបន្ទាយអស់មួយចំនួនថែមទៀត ។

មួយរយៈក្រោយមក ឡោ បានហៅ សាវ៉ាន, ពើក, ឈិត, ឈរ និង ឆែម ដែលជាខ្មែរគិញ មកប្រជុំ ដោយបានលើកយកផែនការបីចំណុចមកអនុវត្តគឺ៖

ទី១) សូមឲ្យខ្មែរគិញនៅតាមភូមិទាំងអស់ធ្វើការតាមដានក្រុមខ្មែរក្រហមឲ្យមែនទែន

ទី២) សូមឲ្យខ្មែរគិញ ជួយអប់រំកុំឲ្យអ្នកស្រុកជឿខ្មែរក្រហម ព្រោះខ្មែរក្រហមជាចោរ

ទី៣) រក្សាការសម្ងាត់ឲ្យបាន កុំឲ្យបែកការណ៍ឲ្យសោះ ហើយខិតខំកសាងកម្លាំងតទៅទៀត ។

ពីចន្លោះឆ្នាំ១៩៦៩ ដល់ឆ្នាំ១៩៧០ ឡោ បញ្ជាឲ្យខ្ញុំទៅទាក់ទងខ្មែរគិញនៅភូមិផ្សេង ឈ្មោះ ស្តើង ដើម្បីសួរនាំពីសភាពការណ៍នៅក្នុងភូមិថ្លូវឆ្នង ដោយសារតែប្រជាជននៅក្នុងភូមិនោះជ្រួលច្របល់ពេលឮថាមានខ្មែរក្រហម ហើយមានប្រជាជនខ្លះចង់ចេញពីភូមិ ។ លុះពេលដឹងដំណឹងនេះ ខ្ញុំបាននិយាយទៅ ស្តើង ថា «បើដូចនោះមែន យើងបំផុសប្រជាជនឲ្យរត់ទៅប៉ៃលិនខ្លះទៅ» ។ បន្ទាប់ពីបំផុសប្រាប់ប្រជាជននៅក្នុងភូមិថ្លូវឆ្នងរួចហើយ ខ្ញុំក៏មករាយការណ៍ប្រាប់ ឡោ ។ ភ្លាមនោះ ឡោ ក៏បានហៅខ្មែរគិញទាំងអស់ឲ្យមកប្រជុំ និងដាក់ផែនការបន្តគឺ៖

ទី១) តាមដានក្រុមបដិវត្តន៍ ព្រោះឮថាមានអ្នកបដិវត្តន៍ចូលមកអប់រំប្រជាជនហើយ បើដឹងច្បាស់ ចាំមករាយការណ៍

ទី២) អប់រំប្រជាជនកុំឲ្យជឿលើបដិវត្តន៍ ដោយប្រាប់ប្រជាជនថា បដិវត្តន៍មានគ្នាតិចណាស់មិនអាចធ្វើអ្វីយើងបានទេ

ទី៣) ត្រូវរក្សាការសម្ងាត់ និងតាមដានឲ្យហ្មត់ចត់បន្តទៀត ។

ខ្ញុំតែងតែបន្តដើរតាមដានភូមិដទៃទៀត ហើយតែងតែរាយការណ៍ប្រាប់ ឡោ នៅពេលដែលមានសភាពការណ៍មិនស្រួល ។ អស់រយៈពេលជាច្រើនខែបន្ទាប់មកទៀត ឡោ បានចាត់តាំងខ្ញុំឲ្យធ្វើជាឈ្លប ហើយតាមរកឈ្មោះ យឿង ។ មិនយូរប៉ុន្មាន ខ្ញុំត្រូវបានបញ្ចូលជាខ្មែរ សេ.អ៊ី.អា ហើយ យឿង បានហៅខ្ញុំទៅប្រជុំ ដោយលើកផែនការបីចំណុច៖

ទី១) សូមឲ្យខ្មែរ សេ.អ៊ី.អា បេះស្រលាញ់ការងារ ដែលគាត់ឲ្យធ្វើ ហើយត្រូវតស៊ូប្រឆាំងដាច់ខាតជាមួយបដិវត្តន៍

ទី២) ខិតខំកសាងខ្មែរ សេ.អ៊ី.អា ឲ្យបានច្រើន ហើយរកអ្នកណាដែលអាចទុកចិត្តបាន

ទី៣) ត្រូវរក្សាការសម្ងាត់ ។ បន្ទាប់ពីដាក់ផែនការរួចហើយ យឿង ឲ្យខ្ញុំក្រោកឡើងនិយាយបេ្តជ្ញាថា «ខ្ញុំដាច់ខាតមិនក្បត់ សេ.អ៊ី.អា ទេ ទោះបីមានឧបសគ្គយ៉ាងណាក៏ដោយ ក៏តស៊ូជាមួយបងទាំងអស់ដែរ» ។

ពេលចូល សេ.អ៊ី.អា រួចហើយ ឈ្មោះ អ៊ុយ បានសូមឲ្យខ្ញុំទៅយកសម្ភារនៅខេត្តសៀមរាប ។ ពេលទៅដល់ ខ្ញុំបានរួមគ្នាជាមួយឈ្មោះ សឿម និង ឈ្មោះ ឆោម បំផ្លាញគ្រាប់អស់១៦០ គ្រាប់ ហើយបានក្រវែងឆ្នាំង និងចាន ចូលទៅក្នុងស្ទឹងសៀមរាបថែមទៀត ។ ខ្ញុំបានរួមសកម្មភាពដុតបំផ្លាញស្រូវសហករណ៍អស់ចំនួន ១០ បាវ ។ ក្នុងឆ្នាំ១៩៧៤ អ៊ុយ បានចាត់តាំងខ្ញុំឲ្យធ្វើការជាមួយខ្មែរខាងភូមិដំណាក់សាលា បន្ទាប់មក ខ្ញុំក៏បានរួមសកម្មភាពដុតបំផ្លាញស្រូវអស់៦០ពំនូក និងបំផ្លាញអំបិលអស់ពីរការ៉ុងដោយយកទៅចាក់ចូលក្នុងទឹក ។ ក្រៅពីនោះ ខ្ញុំតែងតែរួមសកម្មភាពបំផុសអ្នកស្រុកឲ្យចេញពីភូមិ ។

នៅឆ្នាំ ១៩៧៦ អ៊ុយ បានហៅខ្ញុំឲ្យមកនៅកងឈ្លបស្រុក និងបានចាត់តាំងខ្ញុំឲ្យដើរធ្វើការក្នុងស្រុកទាំងមូល ។ ពេលនោះ ខ្ញុំបានបំផុសប្រជាជនថ្មីនៅតាមសហករណ៍ឲ្យរត់ទៅសៀម ថែមទាំងចូលរួមសកម្មភាពបំផ្លាញស្រូវ និងអំបិលនៅក្នុងសហករណ៍ទៀត ។

រហូតដល់ឆ្នាំ១៩៧៧ អ៊ុយ បានប្រាប់ក្រុមទាំងអស់ឲ្យផ្អាកសកម្មភាពបំផុស រហូតដល់ខែ៤ ឆ្នាំដដែល ខ្ញុំបានទទួលដំណឹងថា កងស្រុកត្រូវបានរំលាយ ហើយចាប់តាំងពីពេលនោះមក ខ្ញុំមិនបានធ្វើសកម្មភាពអ្វីទាំងអស់ រហូតដល់ថ្ងៃទី២២ ខែវិច្ឆិកា អង្គការចាប់ខ្លួនខ្ញុំមកឃុំឃាំងតែម្តង ។ **ធួន សិរីរតនា**

# លាង អ៊ាងម៉េង ហៅ ឡាច លាង កម្មកររោងក្រឡឹង

*ដកស្រង់ចេញពីឯកសារចម្លើយសារភាពJ០០៦៥៨*

លាង អ៊ាងម៉េង ហៅ ឡាច លាង ធ្លាប់ជាកម្មកររោងក្រឡឹងនៅភ្នំពេញ ។ លាង អ៊ាងម៉េង បានចូលបក្សពលករវៀតណាមនៅឆ្នាំ១៩៦៥ ។ នៅឆ្នាំ១៩៧០ គាត់បានដឹកនាំបក្ខពួកមួយចំនួនទៅបង្កប់ក្នុងបដិវត្តន៍ នៅខេត្តកំពង់ស្ពឺ ។ នៅឆ្នាំ១៩៧៥ គាត់ត្រូវបានផ្លាស់មកនៅរោងក្រឡឹងចោមចៅរហូតដល់ពេលអង្គការចាប់ខ្លួន ។

ក្នុងឯកសារចម្លើយសារភាព លាង អ៊ាងម៉េង បានរៀបរាប់ពីសកម្មភាពរបស់គាត់ដែលប្រឆាំងនឹងបដិវត្តន៍ ។ ប៉ុន្តែយើងមិនដឹងថា ការសារភាពនេះពិតប្រយ៉ាងណានោះទេ ព្រោះគាត់ត្រូវឆ្លងកាត់ការវាយធ្វើទារុណកម្មពីអ្នកសួរចម្លើយ ។ ខាងក្រោមនេះជាការរៀបរាប់របស់ លាង អ៊ាងម៉េងផ្ទាល់ ៖

ខ្ញុំឈ្មោះ លាង អ៊ាងម៉េង ហៅ ឡាច លាង អាយុ៣៧ឆ្នាំ មានស្រុកកំណើតនៅក្រុងភ្នំពេញ មានរបរជាកម្មករក្រឡឹងដែក ។ ប្រពន្ធឈ្មោះ ង លី ឆេ អាយុ៣៩ឆ្នាំ មានកូនតូចៗពីរនាក់ (ប្រុសម្នាក់ ស្រីម្នាក់) បច្ចុប្បន្នអង្គការចាប់ខ្លួនដែរ ។

កាលពីឆ្នាំ១៩៥១ ខ្ញុំបានចូលរៀនអក្សរចិនអស់រយៈពេល៦ឆ្នាំ បន្ទាប់មកចូលធ្វើជាកម្មករកាត់កញ្ចក់រយៈពេល៣ឆ្នាំ ។ នៅឆ្នាំ១៩៦០ ខ្ញុំបានចូលធ្វើការជាកម្មករក្រឡឹងដែក នៅហាងគុងលាងនៅភ្នំពេញ រហូតដល់ថ្ងៃរដ្ឋប្រហារថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ ។

បីខែបន្ទាប់ពីរដ្ឋប្រហារ អង្គការបានបញ្ជូនខ្ញុំឲ្យទៅរៀនបច្ចេកទេសធ្វើគ្រាប់បែក និងជួសជុលកាំភ្លើងជាមួយយួននៅមុំ



លលាដ៏ក្បាល និងឆ្អឹងជនរងគ្រោះ ត្រូវបានតម្កល់ទុកសម្រាប់គោរពបូជា ក្រោយពេលរបបខ្មែរក្រហមដួលរលំនៅឆ្នាំ១៩៧៩ ។

ស្រែចែង រយៈពេល៨ខែ ។ ក្រោយពីរំដោះទូទាំងប្រទេសនៅឆ្នាំ ១៩៧៥ អង្គការបានផ្លាស់ខ្ញុំឲ្យទៅនៅចោមចៅ រហូតទទួលបាន តួនាទីជាប្រធានបច្ចេកទេស ។

## ១) អំពីរយៈកាលនៅក្រុងភ្នំពេញ

នៅឆ្នាំ១៩៦២ ខ្ញុំបានចូលក្នុងសមាគមមួយ ដែលជា សមាគមប្រឆាំងបក្សកុម្មុយនីស្តកម្ពុជា និងគាំទ្របក្សពលករវៀតណាម ។ សមាគមនេះ ជារូបភាពចំហ គឺសមាគមកីឡា តែរូបភាពសម្ងាត់បម្រើផែនការបក្សពលករវៀតណាម ដែលមានឈ្មោះ ស៊ី អ៊ី ជាគណៈកម្មការដឹកនាំ ។ បីឆ្នាំដំបូង ខ្ញុំអត់ទទួលបានការអប់រំ ឬមាននាទីអ្វីទេ ជាសមាជិកធម្មតា ។ រហូតមកដល់ឆ្នាំ១៩៦៥ គណៈដឹកនាំចាត់តាំង ស៊ី អ៊ី បានអប់រំ និងបំពាក់បំប៉នគោលជំហរ សតិអារម្មណ៍ឲ្យយើងខ្ញុំបម្រើបក្សពលករវៀតណាមអស់ពីចិត្តពីថ្លើម និងត្រូវមានជំហរពុះពារឧបសគ្គ ទ្រាំទ្រការលំបាកវេទនាគ្រប់ពេល ។ ការអប់រំរបស់ ស៊ី អ៊ី មកលើខ្ញុំញឹកញាប់ និងបន្ទាប់មក ទើបដាក់ផែនការឲ្យខ្ញុំអនុវត្តដូចតទៅៈ

១) ឃោសនាអប់រំ ពង្រីកចាត់តាំងកម្លាំងបន្តទៀត

២) ឃោសនាអប់រំ យុវជន យុវនារី ឲ្យបរិច្ចាគវិភាគទាន ឧបត្ថម្ភដល់វៀតណាម

៣) ធ្វើសកម្មប្រឆាំងជាមួយបដិវត្តន៍កម្ពុជាគ្រប់រូបភាព

ក្រោយពី ស៊ី អ៊ី ណែនាំពីផែនការខាងលើរួចមក គាត់បានលើកពីយុទ្ធវិធី និងចាត់ឲ្យធ្វើសកម្មភាពប្រឆាំងបដិវត្តន៍កម្ពុជាតាមការជាក់ស្តែងសិន រហូតពេលណាកម្លាំងបដិវត្តន៍មានច្រើន ឬធ្វើសកម្មភាពចេញមុខវាយចក្រពត្តិ គឺយើងត្រូវធ្វើសកម្មភាពពាក់កណ្តាលចំហ ពាក់កណ្តាលសម្ងាត់ ។ ជារូបភាពចំហ គឺយើងត្រូវរួមជាមួយបដិវត្តន៍កម្ពុជាវាយចក្រពត្តិគ្រប់សកម្មភាពទាំងអស់ តែរូបភាពសម្ងាត់ និងខ្លឹមសារ គឺយើងប្រឆាំងបដិវត្តន៍វិញ ។

ក្នុងមជ្ឈដ្ឋានដែលទាក់ទង និងរួមប្រាស្រ័យក្នុងការធ្វើការងារប្រឆាំងបដិវត្តន៍មានបីកន្លែងៈ គឺ សមាគម អ៊ីលាង សមាគមកីឡា ហ្វាក្វាង និងមន្ទីរពេទ្យចិន ។ សកម្មភាពក្រៅពីនេះ ៈ គឺ អប់រំ និងពង្រឹងកម្លាំងរបស់ខ្លួនដែលមានក្នុងសមាគមឲ្យធ្វើសកម្មភាពប្រឆាំងកម្លាំងបដិវត្តន៍កម្ពុជា មានដូចជា ពិនិត្យ តាមដាន បង្ក្រាបកម្លាំងបដិវត្តន៍គ្រប់ពេលវេលាដើម្បីសម្រេចគោលបំណង ហូ ជីមិញ ដែលបក្សពលករគ្រប់គ្រងឥណ្ឌូចិនទាំងមូល និងប្រទេសតែមួយ ។

ក្រោយពីអប់រំណែនាំពីស្ថានការណ៍ខាងលើរួចមក នៅខែមេសា ឆ្នាំ១៩៧០ ឡាវ ម៉ក់ បានចាត់តាំងខ្ញុំឲ្យមកបង្កប់ស៊ីរូងផ្ទៃក្នុងបដិវត្តន៍កម្ពុជា តាមវិធីស្របច្បាប់ ដោយរួមកម្លាំងជាមួយបដិវត្តន៍កម្ពុជា វាយចក្រពត្តិអាមេរិកាំង ។

## ២) រយៈកាលនៅតំបន់រំដោះ

ខ្ញុំចេញដំណើរទៅកាន់តំបន់រំដោះតាមផ្លូវលេខ៤ ដោយមានគ្នា៣នាក់ គឺ ឡាវ ម៉ាច, វិន ឡុង និងរូបខ្ញុំ ។ ពេលធ្វើដំណើរមកដល់ខាងលិចក្រុងកំពង់ស្ពឺ ម្តុំពេជ្រនិល ក៏មានអង្គការចាំទទួលនៅទីនោះ ។ យើងខ្ញុំទៅស្នាក់នៅភ្នំពេជ្រនិលអស់រយៈពេលបួនខែជាមួយ តាហុង នៅភ្នំអាកោន ។

ខែកញ្ញា ឆ្នាំ១៩៧០ ខ្ញុំក៏ត្រូវបែកចេញពីបក្ខពួក ដោយអង្គការតម្រូវឲ្យទៅរៀនធ្វើគ្រាប់បែក គ្រាប់រំសេវ មីន និងជួសជុលកាំភ្លើងជាមួយយួន ។ រស់នៅជាមួយយួនអស់រយៈពេលប្រាំបីខែដំបូង យួនបានចាត់តាំងឲ្យខ្ញុំឲ្យដោះម៉ាស៊ីនត្រឡឹងមួយគ្រឿង និងឲ្យដាំបាយអស់រយៈពេលបីខែ ។ យួនបានអប់រំខ្ញុំ ឲ្យខំធ្វើការ និងឲ្យនៅជាមួយគេរហូត កុំទៅនៅជាមួយអង្គការបដិវត្តន៍កម្ពុជាវិញ ហើយពេលរំដោះប្រទេសរួច គេនឹងបញ្ជូនឲ្យទៅនៅប៉េកាំង ។

ក្រោយរំដោះទូទាំងប្រទេស នៅឆ្នាំ១៩៧៥ ខ្ញុំបានទៅជួបបក្ខពួកខ្ញុំវិញ ។ ពេលជួបគ្នាយើងបានសាកសួរគ្នាអំពីលទ្ធផលអនុវត្តកន្លងមក ព្រមទាំងរំឭកគ្នាឡើងវិញអំពីផែនការ ។ លុះដល់ខែ៤ ឆ្នាំ១៩៧៤ ខ្ញុំត្រូវបានផ្លាស់ឲ្យមកនៅមន្ទីរម-២១១ រោងក្រឡឹងកងពលទី២ ខាងជើងត្រពាំងអណ្តើក អស់រយៈពេលមួយឆ្នាំ ។

នៅទីនោះ ខ្ញុំបានបំផុស និងអប់រំបានមនុស្សម្នាក់ដើម្បីរួមក្នុងចលនាប្រឆាំងបដិវត្តន៍កម្ពុជា គឺឈ្មោះ សេង ចៃ ហៅ ច្រឹង អាណិកជនចិន និងក្រោយមក អប់រំបានមនុស្សពីរនាក់ថែមទៀត គឺឈ្មោះ គុង និង ម៉េង ។

ចំពោះសកម្មភាព ខ្ញុំបានអនុវត្តដូចរាយការណ៍ជូនអង្គការបដិវត្តន៍ខាងលើ ។ លុះដល់ថ្ងៃទី២៨ ខែមីនា ឆ្នាំ១៩៧៨ អង្គការចាប់ខ្លួនខ្ញុំតែម្តង ។

**កែវ ធាស្រ៊ុន**

# កាលវិភាគបញ្ចាំងខ្សែភាពយន្ត ឯកសារ ចាប់ពីខែមេសា ដល់ ខែធ្នូ ឆ្នាំ២០១៦
















*កាលបរិច្ឆេទបញ្ចាំង៖ រៀងរាល់ថ្ងៃសុក្រ វេលាម៉ោង១០ ៖ ០០ព្រឹក និង ម៉ោង៥ ៖ ១៥ រសៀល*

*ទីតាំង៖ អគារ H នៃវិទ្យាស្ថានជាតិអប់រំ (មហាវិថីព្រះសីហនុ ភ្នំពេញ)*

*សម្រាប់ព័ត៌មានបន្ថែមសូមទាក់ទង៖*

លោក ម៉ែន ពិចិត្រ
មជ្ឈមណ្ឌលឯកសារកម្ពុជា
ទូរស័ព្ទលេខ ០២៣ ២១៨ ០០៩
អ៊ីម៉ែលៈ truthmpechet@dccam.org
គេហទំព័រៈ www.dccam.org l www.cambodiasri.org

**ខែមេសា ឆ្នាំ២០១៦**

◆ ថ្ងៃទី១ ខែមេសា វេលាម៉ោង ១ ព្រឹក និង ម៉ោង ៥ ៈ ១៥ រសៀល បញ្ចាំងរឿង «គុកឥតជញ្ជាំង» ដោយទូរទស្សន៍ជាតិកម្ពុជា (៩៥ នាទី)

◆ ថ្ងៃទី៨ ខែមេសា វេលាម៉ោង ១០ ព្រឹក និង ម៉ោង ៥ ៈ ១៥ រសៀល បញ្ចាំងរឿង «ការផ្សារសម្លាត់នៅមន្ទីរស-២១» ដោយ ដេវីត អូកូហ្វូណា (David Okuefuna) (៣០ នាទី)

◆ ថ្ងៃទី២២ ខែមេសា វេលាម៉ោង ១០ព្រឹក និង ម៉ោង៥ ៈ ១៥ រសៀល បញ្ចាំងរឿង «ឋាននរក៩ជាន់» ដោយ Cinema Dept. FPD ក្នុងឆ្នាំ១៩៨៧ (១៣១.២៨នាទី)

◆ ថ្ងៃទី២៩ ខែមេសា វេលាម៉ោង ១០ព្រឹក និង ម៉ោង៥ ៈ ១៥ រសៀល បញ្ចាំងរឿង «ប្រាសាទអង្គរវត្តដែលកំបាំង» ដោយ Discover Magazine ក្នុងឆ្នាំ១៩៩៩ (៣០.១៥ នាទី)

**ខែឧសភា ឆ្នាំ២០១៦**

◆ ថ្ងៃទី២០ ខែឧសភា វេលាម៉ោង ១០ព្រឹក និង ម៉ោង៥ ៈ ១៥ រសៀល បញ្ចាំងរឿង «កម្ពុជា ៈ ការស្លាប់ និង ការចាប់កំណើត» ដោយ Germany ក្នុងឆ្នាំ១៩៨០ (៩០ នាទី)

◆ ថ្ងៃទី២០ ខែឧសភា វេលាម៉ោង ១០ព្រឹក និង ម៉ោង ៥ ៈ ១៥ រសៀល បញ្ចាំងរឿង «អង្គការ» ដោយ Germany ក្នុងឆ្នាំ១៩៨១ (៩០ នាទី)

**ខែមិថុនា ឆ្នាំ២០១៦**

◆ ថ្ងៃទី៣ ខែមិថុនា វេលាម៉ោង ១០ព្រឹក និង ម៉ោង ៥ ៈ ១៥ រសៀល បញ្ចាំងរឿង «សង្គ្រាមក្នុងព្រៃ» ដោយ Germany ក្នុងឆ្នាំ ១៩៨៣ (៩០ នាទី)

◆ ថ្ងៃទី១០ ខែមិថុនា វេលាម៉ោង ១០ ព្រឹក និង ម៉ោង៥ ៈ ១៥ រសៀល បញ្ចាំងរឿង «រវាងសន្តិភាព និងយុត្តិធម៌ ៈ រឿងកន្ទុយហួសទៅស្នូមឲ្យកន្ទុយហួសទៅចុះ» ដោយ ព្រូណូ ការ៉ាតេ (Bruno Carette) ក្នុងឆ្នាំ១៩៩៩ (៣៧នាទី)

◆ ថ្ងៃទី១៧ ខែមិថុនា វេលាម៉ោង ១០ព្រឹក និង ម៉ោង៥ ៈ ១៥ រសៀល បញ្ចាំងរឿង «ជីវិ២ (ជីវិជនភៀសខ្លួន)» ដោយ រិទ្ធី ប៉ាន់ ក្នុងឆ្នាំ១៩៨៩ (៦០ នាទី)

◆ ថ្ងៃទី១៧ ខែមិថុនា វេលា ម៉ោង ១០ព្រឹក និង ម៉ោង៥ ៈ ១៥ រសៀល បញ្ចាំងរឿង «ប៉ុល ពត ៈ ការសម្លាប់» ដោយ ភីធើ ហើខំ (Peter Hercombe) (៥១ នាទី)

**ខែកក្កដា ឆ្នាំ២០១៦**

◆ ថ្ងៃទី១ ខែកក្កដា វេលាម៉ោង ១០ព្រឹក និង ម៉ោង៥ ៈ ១៥ រសៀល បញ្ចាំងរឿង «សាក្សីកម្ពុជា» បណ្ណសាររបស់ ដេវីត ហាក (David Hawk Archives) (១១១.២នាទី)

◆ ថ្ងៃទី៨ ខែកក្កដា វេលាម៉ោង ១០ ព្រឹក និង ម៉ោង ៥ ៈ ១៥ រសៀល បញ្ចាំងរឿង «សកម្មភាពគោរពវិញ្ញាណក្ខន្ធនៅបូជនីយដ្ឋានជើងឯក» ដោយ FPD ក្នុងឆ្នាំ១៩៩៨

◆ ថ្ងៃទី១៥ ខែកក្កដា វេលាម៉ោង ១០ ព្រឹក និង ម៉ោង ៥ ៈ ១៥ រសៀល បញ្ចាំងរឿង «ព្រះអាទិទេពចុងក្រោយ» ដោយ ជេមស៍ ជើរ៉ាន (James Gerrand) (១១៨នាទី)

◆ ថ្ងៃទី២២ ខែកក្កដា វេលាម៉ោង១០ព្រឹក និង ម៉ោង ៥ ៈ ១៥ រសៀល បញ្ចាំងរឿង «តំបន់អន្ទង់វែង (តាម៉ុក)» ដោយ ជេមស៍ ជើរ៉ាន (James Gerrand) (១៧៤.៥៧នាទី)

◆ ថ្ងៃទី២៩ ខែកក្កដា វេលាម៉ោង ១០ព្រឹក និង ម៉ោង៥ ៈ ១៥ រសៀល បញ្ចាំងរឿង «កម្ពុជា ៣បួន៨ ឆ្នាំទីសូន្យ និងឆ្នាំទី១» ក្នុងឆ្នាំ១៩៧៩ (១៥៦នាទី)

**ខែសីហា ឆ្នាំ២០១៦**

◆ ថ្ងៃទី៥ ខែសីហា វេលាម៉ោង ១០ ព្រឹក និង ម៉ោង ៥ ៈ ១៥ រសៀល បញ្ចាំងរឿង «ស្រមោលអតីតកាល ៈ រឿងចំនួនបួនដែលនិយាយអំពីការផ្សះផ្សា» ដោយ Express TV (១២០នាទី)

◆ ថ្ងៃទី១២ ខែសីហា វេលាម៉ោង ១០ព្រឹក និង ម៉ោង ៥ ៈ១៥ រសៀល បញ្ចាំងរឿង «ស្រមោលរបស់ ប៉ុល ពត» ដោយ អាមេនដា ផៃក (Amanda Pike) ក្នុងឆ្នាំ២០០២ (២៥នាទី)

◆ ថ្ងៃទី១៩ ខែសីហា វេលាម៉ោង ១០ ព្រឹក និង ម៉ោង ៥ ៈ ១៥ រសៀល បញ្ចាំងរឿង «ក្តីសង្ឃឹមដ៏តិចតួចចេញពីវាលពិឃាត» ដោយ ធារ៉ា ដេលហ្គាដូ (Tiara Delgado) (៣៨នាទី)

◆ ថ្ងៃទី២៦ ខែសីហា វេលាម៉ោង១០ព្រឹក និង ម៉ោង ៥ ៈ ១៥ រសៀល បញ្ចាំងរឿង «ទម្លាយភាពស្ងប់ស្ងាត់» ដោយ មជ្ឈមណ្ឌលឯកសារកម្ពុជា (៦៩នាទី)

**ខែកញ្ញា ឆ្នាំ២០១៦**

◆ ថ្ងៃទី២ ខែកញ្ញា វេលាម៉ោង១០ព្រឹក និង ម៉ោង៥ ៈ ១៥ រសៀល បញ្ចាំងរឿង «បទសម្ភាសន៍ជាមួយ ប៉ុល ពត» ដោយ ភីធើ ហ្វ្របឺក (Peter Froberg) ក្នុងឆ្នាំ២០០៤ (៥១នាទី)

◆ ថ្ងៃទី៩ ខែកញ្ញា វេលាម៉ោង ១០ ព្រឹក និង ម៉ោង៥ ៈ ១៥ រសៀល បញ្ចាំងរឿង «ប៉ុល ពត ៈ ដំណើរទៅកាន់វាលពិឃាត» ដោយ ជេនចនស្តុន (Jane Johnston) (៥០នាទី)

◆ ថ្ងៃទី១៦ ខែកញ្ញា វេលាម៉ោង ១០ព្រឹក និង ម៉ោង ៥ ៈ ១៥ រសៀល បញ្ចាំងរឿង «យុត្តិធម៌ដែលបានពន្យាពេល និងយុត្តិធម៌ ដែលបានបដិសេធ (ការកាត់ទោសមេដឹកនាំខ្មែរក្រហម)» ក្នុងឆ្នាំ២០០៥ (៥៤.២៤នាទី)

◆ ថ្ងៃទី២៣ ខែកញ្ញា វេលាម៉ោង ១០ព្រឹក និង ម៉ោង៥ ៈ ១៥ រសៀល បញ្ចាំងរឿង «រឿងរ៉ាវពីទឹកដីកម្ពុជាក្រោម» (៧០នាទី)

**ខែតុលា ឆ្នាំ២០១៦**

◆ ថ្ងៃទី៧ ខែតុលា វេលាម៉ោង ១០ព្រឹក និង ម៉ោង៥ : ១៥ រសៀល បញ្ចាំងរឿង «នៅក្រោយជញ្ជាំងមន្ទីរស-២១» ដោយ មជ្ឈមណ្ឌលឯកសារកម្ពុជា ក្នុងឆ្នាំ២០០៧ (៣០ នាទី)

◆ ថ្ងៃទី១៤ ខែតុលា វេលាម៉ោង ១០ព្រឹក និង ម៉ោង ៥ : ១៥ រសៀល បញ្ចាំងរឿង «ដំណើរទៅកាន់វាលពិឃាត» ដោយ ជេន ចនស្តុន (Jane Jonhston) (៥០ នាទី)

◆ ថ្ងៃទី២១ ខែតុលា វេលាម៉ោង ១០ព្រឹក និង ម៉ោង ៥ : ១៥ រសៀល បញ្ចាំងរឿង «ដល់ពេលស្វែងរកយុត្តិធម៌» ដោយ KMF Films ក្នុងឆ្នាំ២០០៧ (៤០ នាទី)

◆ ថ្ងៃទី២៨ ខែតុលា វេលាម៉ោង ១០ព្រឹក និង ម៉ោង៥ : ១៥ រសៀល បញ្ចាំងរឿង «មើលទៅមុខ មើលទៅក្រោយ» ដោយ DMC ក្នុងឆ្នាំ២០០៧ (៥២.៣០ នាទី)

**ខែវិច្ឆិកា ឆ្នាំ២០១៦**

◆ ថ្ងៃទី៤ ខែវិច្ឆិកា វេលាម៉ោង ១០ព្រឹក និង ម៉ោង ៥ : ១៥ រសៀល បញ្ចាំងរឿង «ការរាំទៅរកការស្លាប់ : សត្វស្វាមន្តអាគម និងភាពរិលវល់របស់កម្ពុជា» ដោយ ចេនេត ហ្គាតនើ (Janet Gardner) ក្នុងឆ្នាំ២០១០ (៥៦នាទី)

◆ ថ្ងៃទី៤ ខែវិច្ឆិកា វេលាម៉ោង ១០ ព្រឹក និង ម៉ោង៥ : ១៥ រសៀល បញ្ចាំងរឿង «ការកាត់ទោស ប៉ុល ពត នៅអន្លង់វែង នៅថ្ងៃទី២៥ ខែកក្កដា ឆ្នាំ១៩៩៧» ដោយ ឡុង សារិន ក្នុងឆ្នាំ ១៩៩៧ (៤៣.៣០ នាទី)

◆ ថ្ងៃទី៤ ខែវិច្ឆិកា វេលាម៉ោង ១០ ព្រឹក និង ម៉ោង ៥ : ១៥ រសៀល បញ្ចាំងរឿង «៣ឆ្នាំ ៨ខែ ២០ថ្ងៃ» ដោយ រ៉ូសេន សេដណាតា (Roshane Saidnattar) ក្នុងឆ្នាំ២០០៩ (៩៨.០៦នាទី)

◆ ថ្ងៃទី២៥ ខែវិច្ឆិកា វេលាម៉ោង ១០ ព្រឹក និង ម៉ោង៥ : ១៥ រសៀល បញ្ចាំងរឿង «ក្មេងសម្រាប់ដាក់លក់» ដោយ NBC TV ក្នុងឆ្នាំ២០០៤ (៤៣នាទី)

**ខែធ្នូ ឆ្នាំ២០១៦**

◆ ថ្ងៃទី២ ខែធ្នូ វេលាម៉ោង ១០ ព្រឹក និង ម៉ោង៥ : ១៥ រសៀល បញ្ចាំងរឿង «វិប្បដិសារី» ក្នុងឆ្នាំ ២០០៨ (Royal Archives)

◆ ថ្ងៃទី៩ ខែធ្នូ វេលាម៉ោង១០ព្រឹក និង ម៉ោង ៥ : ១៥ រសៀល បញ្ចាំងរឿង «កង់ទ័ពខ្មែរក្រហម» ដោយ ព្រូណូ ការ៉ាតេ (Bruno Carette) និង សេន មេត្តា (Sien Meta) ក្នុងឆ្នាំ ២០០៧ (៩៥នាទី)

◆ ថ្ងៃទី១៦ ខែធ្នូ វេលាម៉ោង ១០ ព្រឹក និង ម៉ោង ៥ : ១៥ រសៀល បញ្ចាំងរឿង «ពេលព្រះអាទិត្យអស្តង្គត» ដោយ ព្រះបាទ នរោត្តម សីហនុ

◆ ថ្ងៃទី២៣ ខែធ្នូ វេលាម៉ោង ១០ព្រឹក និង ម៉ោង៥ : ១៥ រសៀល បញ្ចាំងរឿង «កុំស្មានបងភ្លេច : ខ្មែរបាត់បង់តន្ត្រីរ៉ក់» ដោយ ចន ពីរ៉ូស៊ី (Jonh Pirozzi) (១០៧នាទី)

◆ ថ្ងៃទី៣០ ខែធ្នូ វេលាម៉ោង ១០ ព្រឹក និង ម៉ោង ៥ : ១៥ រសៀល បញ្ចាំងរឿង «ក្បូនទឹកទន្លេ» ដោយ កល្យាណី ម៉ម ក្នុងឆ្នាំ២០១២ (៨៣នាទី)

# ការិយាល័យព័ត៌មានសាធារណៈ

“ការិយាល័យព័ត៌មានសាធារណៈ” របស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានបើកបម្រើជូននិស្សិត អ្នកស្រាវជ្រាវ បុគ្គលិករាជការ និងអង្គការក្រៅរដ្ឋាភិបាល និងបុគ្គលទាំងឡាយដែលមានចំណាប់អារម្មណ៍ចង់យល់ដឹងអំពីប្រវត្តិសាស្ត្ររបបកម្ពុជាប្រជាធិបតេយ្យ និងព្រឹត្តិការណ៍វិវឌ្ឍរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឬសាលាក្តីខ្មែរក្រហម ។

មជ្ឈមណ្ឌលឯកសារកម្ពុជាជាកន្លែងប្រមូលផ្តុំ និងចងក្រងឯកសារអំពីរបបកម្ពុជាប្រជាធិបតេយ្យបានច្រើនបំផុត ។ ឯកសារនៅមជ្ឈមណ្ឌលឯកសារកម្ពុជាមានប្រាំប្រភេទ ។ ប្រភេទឯកសារទីមួយគឺឯកសារជាក្រដាសសន្លឹកដែលមានចំនួនជិតមួយលានទំព័រ ។ ប្រភេទឯកសារទីពីរគឺជាបទសម្ភាសន៍ដែលបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាចុះទៅធ្វើសម្ភាសន៍ជាមួយជនរងគ្រោះនិងអតីតកម្មាភិបាលខ្មែរក្រហម ។ ប្រភេទឯកសារទីបីគឺជារូបថតទាក់ទងទៅនឹងសម័យខ្មែរក្រហម ។ ប្រភេទឯកសារទីបួនគឺជាឯកសារទាក់ទងទៅនឹងការធ្វើផែនទីរណ្តៅសាកសព និងទីតាំងសម្លាប់របស់ខ្មែរក្រហម និងឯកសារប្រភេទទីប្រាំគឺជាខ្សែភាពយន្តឯកសារដែលបានផលិតឡើងក្នុងរបបខ្មែរក្រហម និងសម័យក្រោយមកទៀត ។

តាមរយៈការិយាល័យព័ត៌មានសាធារណៈ សាធារណជនអាចអាននឹងស្រាវជ្រាវឯកសារទាំងនេះបាន ។ ឯកសារខ្លះទៀតរួមមាន ៖ ប្រវត្តិរូបកម្មាភិបាលខ្មែរក្រហម ចម្លើយសារភាព កំណត់ហេតុរបស់បក្ស ទូរលេខឆ្លើយឆ្លងព័ត៌មានដែលបានមកពីការសម្ភាសន៍ជាមួយអតីតកម្មាភិបាលខ្មែរក្រហម និងទិន្នន័យគន្ថនិទ្ទេសបង្ហាញពីរណ្តៅសាកសព ទីតាំងគុក និងបូជនីយដ្ឋានប្រល័យពូជសាសន៍ ។

ការិយាល័យព័ត៌មានសាធារណៈមានទីតាំងនៅអគារលេខ៦៦ មហាវិថីព្រះសីហនុ ខាងកើតវិមានឯករាជ្យ ។ ការិយាល័យរបស់យើងបើកជូនសាធារណជនពីថ្ងៃច័ន្ទដល់ថ្ងៃសុក្រ ពេលព្រឹកពីម៉ោង៨ដល់ម៉ោង១២ និងពេលរសៀលពីម៉ោង២ដល់ម៉ោង៥ ។ ប្រសិនបើអស់លោកអ្នកមានចម្ងល់ ឬចង់រៀបចំព្រឹត្តិការណ៍ជាក្រុមណាមួយ សូមទាក់ទងបុគ្គលិករបស់យើង ស៊ិន សុធីតា តាមរយៈទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ឬអ៊ីម៉ែល truththida.s@dccam.org ។





















# ថ្នាក់រៀននៅទួលស្លែង

មជ្ឈមណ្ឌលឯកសារកម្ពុជាបានបង្កើតថ្នាក់រៀនសាធារណៈមួយនៅសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង ។ ថ្នាក់រៀននេះត្រូវបានបង្កើតឡើងក្នុងខែវិច្ឆិកា ឆ្នាំ២០១១ ដោយមានកិច្ចសហការរវាងមជ្ឈមណ្ឌលឯកសារកម្ពុជា និងក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ។ សារមន្ទីរទួលស្លែងគឺជាអតីតសាលារៀនដ៏ទំនើបមួយដែលបានសង់ឡើងជាលើកដំបូងនៅក្នុងឆ្នាំ១៩៦២ ។ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ខ្មែរក្រហមបានប្រែក្លាយសាលារៀននេះទៅជាគុកដ៏សម្ងាត់បំផុតមួយក្នុងចំណោមគុកចំនួន១៩៦ទូទាំងប្រទេស ។ អ្នកទោសភាគច្រើនដែលត្រូវបញ្ជូនទៅទួលស្លែង គឺជាកម្មាភិបាលខ្មែរក្រហមដែលត្រូវបានចោទប្រកាន់ពីបទប្រព្រឹត្តអំពើក្បត់ជាតិ ដូចជា ការសហការជាមួយរដ្ឋាភិបាលបរទេស ឬធ្វើជាអ្នកស៊ើបការណ៍ឲ្យសេ.អ៊ី.អា ឬកា.ហ្សេ.បេ ជាដើម ។



ចាប់តាំងពីការប្រែក្លាយពីកន្លែងរៀនសូត្រមួយទៅជាកន្លែងដ៏គួរឲ្យរន្ធត់ និងមហន្តរាយមួយ ទួលស្លែងមិនដែលទទួលបានមុខងាររបស់ខ្លួនដូចកាលពីដើមវិញឡើយ ។ ទោះបីជាយ៉ាងនេះក្តី នៅពេលអនាគតដើម្បីទាមទារមកវិញនូវកេរដំណែលអប់រំដែលមានលក្ខណៈវិជ្ជមានរបស់ទួលស្លែង និងដើម្បីបន្ថែមសមាសភាពអប់រំមួយទៅក្នុងសារមន្ទីរនេះ ថ្នាក់រៀននេះ ត្រូវបានបង្កើតឡើងដើម្បីផ្តល់ការបង្រៀន និងការពិភាក្សាដោយឥតគិតថ្លៃអំពីប្រវត្តិសាស្ត្ររបបខ្មែរក្រហម និងប្រធានបទដែលជាប់ទាក់ទង ដូចជា អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ ថ្នាក់រៀននេះ ក៏ជាវេទិកាសាធារណៈមួយសម្រាប់ឲ្យអ្នកមកទស្សនា និងអ្នកដែលនៅរស់រានមានជីវិតចែករំលែកព័ត៌មានគ្នាក្នុងការថែរក្សារយៈកាលនៃប្រវត្តិសាស្ត្រកម្ពុជាដ៏មានសារសំខាន់មួយទុកឲ្យអ្នកជំនាន់ក្រោយបានរៀនសូត្រ ។

បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជា និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង ដែលមានសញ្ញាបត្រមកពីបរទេស និងបានទទួលវិញ្ញាបនបត្រពីក្រសួងអប់រំ យុវជន និងកីឡា ផ្នែកការបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-៧៩) ព្រមទាំងមានការចូលរួមពីអ្នកជំនាញជាតិ និងអន្តរជាតិដែលមានជំនាញលើប្រវត្តិសាស្ត្រប្រទេសកម្ពុជា និងអ្នកដែលនៅរស់រានមានជីវិតពីមន្ទីរស-២១ នឹងបង្រៀននៅថ្នាក់រៀននេះ ។ ព័ត៌មានទាក់ទងនឹងថ្នាក់រៀននេះ សូមទាក់ទង ម៉ែន ពិចិត្រ តាមរយៈទូរស័ព្ទលេខៈ ០២៣ ២១១ ៨៧៥ ឬអ៊ីម៉ែលៈ truthmpechet@dccam.org ។

**◆ទីកន្លែង ៖ អគារ "ក" ជាន់លើ ◆ពេលវេលា ៖ ច័ន្ទ ២-៣រសៀល, ពុធ ៩-១០ព្រឹក, សុក្រ ២-៣រសៀល**

# ស្វែងយល់អំពីគេហទំព័រឃ្លាំមើលការវិវឌ្ឍរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

# www.cambodiatribunal.org

*គេហទំព័រឃ្លាំមើលការវិវឌ្ឍរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា www.cambodiatribunal.org គឺជាប្រភពឈានមុខគេនៃសារព័ត៌មានដំណឹងវិវឌ្ឍថ្មីៗ ព្រមទាំងបទអត្ថាធិប្បាយរបស់អ្នកជំនាញជាច្រើនទៅលើដំណើរការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាទាំងមូល ។ រយៈពេលកន្លងមកនេះព័ត៌មានយ៉ាងច្រើនត្រូវបានផ្សព្វផ្សាយនៅលើគេហទំព័រនេះ ។ គេហទំព័រនេះបង្កលក្ខណៈងាយស្រួលបំផុតសម្រាប់សាធារណជនទាំងឡាយក្នុងការស្វែងយល់អំពីដំណើរការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។*

*សំណុំរឿងព្រហ្មទណ្ឌលេខ០០២ដែលទាក់ទិននឹងជនជាប់ចោទពីរនាក់ទៀតគឺ ខៀវ សំផន គណៈប្រធានរដ្ឋនៃរបបកម្ពុជាប្រជាធិបតេយ្យ និង នួន ជា អនុលេខាបក្សនិងជាប្រធានរដ្ឋសភានៃរបបកម្ពុជាប្រជាធិបតេយ្យបានចាប់ផ្តើមបើកសវនាការកាលពីខែវិច្ឆិកា ឆ្នាំ២០១១ និងបានប្រកាសសាលក្រមលើកទីមួយកាលពីខែសីហា ឆ្នាំ២០១៤ ។*

*ដើម្បីជួយកាត់បន្ថយចំនួនអ្នកខកខានមិនបានតាមដានដំណើរការដោយផ្ទាល់ឲ្យមកនៅត្រឹមកម្រិតតូចមួយ គេហទំព័រឃ្លាំមើលការវិវឌ្ឍរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា www.cambodiatribunal.org ត្រូវបានបង្កើតដោយមានផ្នែកជាច្រើនទាក់ទិននឹងរបាយការណ៍ប្រចាំថ្ងៃអំពីសវនាការ វីដេអូ សវនាការទាំងមូលនិងយោបល់ផ្សេងៗរបស់ជនរងគ្រោះទាក់ទងនឹងសវនាការ សារព័ត៌មានផ្សេងៗជុំវិញតុលាការ របាយការណ៍របស់តុលាការ និងអង្គការក្រៅរដ្ឋាភិបាល ដំណើរការនីតិវិធីផ្សេងៗនៃអង្គជំនុំជម្រះ ប្រវត្តិសាស្ត្រ ប្រវត្តិរបស់តុលាការនេះ និងបទអត្ថាធិប្បាយរបស់អ្នកជំនាញ ។*

*គេហទំព័រនេះនឹងជួយបង្កលក្ខណៈងាយស្រួលគ្រប់គ្រាន់ សម្រាប់និស្សិតគ្រប់គ្រឹះស្ថានសិក្សាដែលមានបំណងចង់សិក្សាស្វែងយល់អំពីដំណើរនីតិវិធីអង្គជំនុំជម្រះវិសាមញ្ញដែលជាដំណើរការមានលក្ខណៈចម្រុះជាតិ និងអន្តរជាតិ ។ ឧទាហរណ៍ ការយកទ្រឹស្តីច្បាប់មួយដែលមានលក្ខណៈស្មុគស្មាញ និងចម្រូងចម្រាសមកអនុវត្តដោយអង្គជំនុំជម្រះវិសាមញ្ញគឺទ្រឹស្តី «សហកម្មឧក្រិដ្ឋកម្មរួម» ដែលភាសាអង់គ្លេសហៅថា «Join Criminal Enterprise» ដែលតាមរយៈទ្រឹស្តីនេះ ជនសង្ស័យអាចត្រូវបានដាក់ឲ្យទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌចំពោះបទឧក្រិដ្ឋទាំងឡាយដែលប្រព្រឹត្តឡើងទៅតាម «ផែនការឧក្រិដ្ឋកម្មរួម» ដែលភាសាអង់គ្លេសហៅថា «Common Criminal Plan» ។ ដូច្នេះ យើងអាចចូលទៅរកដំណើរការនីតិវិធីផ្សេងៗនៃអង្គជំនុំជម្រះឬបទអត្ថាធិប្បាយរបស់អ្នកជំនាញដើម្បីស្វែងយល់ថាតើចៅក្រមបានសម្រេចយ៉ាងដូចម្តេចចំពោះការដែលយកទ្រឹស្តីនេះមកអនុវត្តនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ តើមានភាគីផ្សេងទៀតដែរឬទេ ដែលមានយោបល់ទៅលើបញ្ហានេះ?*

*ប្រសិនបើមិនចង់ចំណាយពេលវេលាច្រើនដើម្បីមើលវីដេអូសវនាការដែលប្រព្រឹត្តឡើងពេញមួយថ្ងៃដែលអាចចំណាយពេលពី៦ទៅ៨ម៉ោងនោះ សាធារណជនអាចចូលទៅក្នុងផ្នែករបាយការណ៍ប្រចាំថ្ងៃអំពីសវនាការ ។ ក្នុងផ្នែកនេះ យើងមានអ្នកឃ្លាំមើលសវនាការម្នាក់ដែលត្រូវបានបញ្ជូនឲ្យទៅអង្គុយនៅក្នុងបន្ទប់សវនាការផ្ទាល់ បន្ទាប់មកអ្នកឃ្លាំមើលនេះសរសេររបាយការណ៍ខ្លីមួយដែលរៀបរាប់អំពីខ្លឹមសារសំខាន់ៗទាំងឡាយទាក់ទិននឹងសវនាការពេញមួយថ្ងៃនោះតែម្តង ។ របាយការណ៍បែបនេះមានជាភាសាខ្មែរដែរ ។* ***វ៉ាន់ថាន់ ពៅដារ៉ា***

# គេហទំព័រទស្សនាវដ្ដីស្វែងរកការពិតជាភាសាខ្មែរ
# www.truthcambodia.com

*ទស្សនាវដ្ដីស្វែងរកការពិត បង្កើតគេហទំព័រ* www.truthcambodia.com *ក្នុងគោលបំណងផ្សព្វផ្សាយ និងអប់រំឲ្យបានកាន់តែទូលំទូលាយអំពីរបបកម្ពុជាប្រជាធិបតេយ្យ (របបខ្មែរក្រហម) ដើម្បីសម្រេចឲ្យបាននូវការចងចាំ យុត្តិធម៌ និងការផ្សះផ្សាជាតិក្នុងសង្គមដែលទទួលរងនូវការបែកបាក់ និង សង្រ្គាមជាច្រើនទសវត្សរ៍ ។*

*គេហទំព័រ* www.truthcambodia.com *ក៏នឹងដើរតួនាទីដ៏សំខាន់ផងដែរក្នុងការចែករំលែកព័ត៌មានអំពីដំណើរការសវនាការកាត់ទោសមេដឹកនាំខ្មែរក្រហមជាមួយសាធារណជន និងជួយសាលាក្ដីក្នុងការរំលែកព័ត៌មានទាក់ទងប្រវត្តិសាស្ត្រខ្មែរក្រហម នៅខណៈពេលអត្ថបទមួយចំនួននៅក្នុងគេហទំព័រនេះត្រូវបានយកទៅប្រើប្រាស់ជាភ័ស្តុតាងដើម្បីដាក់បន្ទុកមេដឹកនាំខ្មែរក្រហម ។*

*គេហទំព័រ* www.truthcambodia.com *បែងចែកជា៥ផ្នែកសំខាន់ គឺ១) ផ្នែកឯកសារ ២) ផ្នែកប្រវត្តិសាស្ត្រ ៣) ផ្នែកច្បាប់ ៤) ផ្នែកវេទិកាពិភាក្សាជាសាធារណៈ និង ៥) ផ្នែកស្រាវជ្រាវស្វែងរកក្រុមគ្រួសារដែលបានស្លាប់ ឬបាត់ខ្លួនក្នុងរបបខ្មែរក្រហម ។ នៅក្នុងគេទំព័រ* www.truthcambodia.com *ក៏មានផ្ទុកនូវឯកសារជាវីដេអូ, សំឡេង, រូបថត និងឯកសារដើមរបស់ខ្មែរក្រហមដែរ ។*

*អត្ថបទសម្រាប់ផ្នែកទី១) នឹងរៀបរៀងឡើង ដោយស្មេរមជ្ឈមណ្ឌលឯកសារកម្ពុជា ដោយផ្អែកលើឯកសារដើមទាំងស្រុង ។ សរសេរឲ្យស្រួលអាន គឺការសង្ខេបចេញពីឯកសារដើមមកជាអត្ថបទ ។ គោលបំណងនៃផ្នែកនេះ គឺចង់ជម្រាបជូនសាធារណជនថា តើមានឯកសារអ្វីខ្លះដែលតម្កល់នៅមជ្ឈមណ្ឌលឯកសារកម្ពុជា ។ ផ្នែកទី២) គឺជាអត្ថបទវិភាគលើប្រវត្តិសាស្ត្រនៃរបបខ្មែរក្រហម ។ អត្ថបទផ្នែកនេះគឺជាអត្ថបទចូលរួមមកពីអ្នកជំនាញជាន់ខ្ពស់លើប្រវត្តិសាស្ត្រខ្មែរក្រហម ហើយមានទិសដៅសម្រិតសម្រាំងប្រវត្តិសាស្ត្រនេះឲ្យមានភាពកាន់តែសុក្រឹតទ្បើងទៀត ។ ផ្នែកទី៣) គឺជាផ្នែកច្បាប់ដែលធ្វើការវិភាគដោយមេធាវី ឬចៅក្រម ឬអ្នកជំនាញការច្បាប់អន្តរជាតិ ។ ការវិភាគនេះនឹងជួយជាគំនិតលើផ្នែកច្បាប់ថា តើឧក្រិដ្ឋកម្មអ្វីខ្លះដែលបានកើតឡើងក្នុងរបបខ្មែរក្រហម ហើយថា តើឧក្រិដ្ឋកម្មនីមួយៗត្រូវតែដោះស្រាយតាមនីតិវិធីបែបណា ដើម្បីរកឲ្យបាននូវយុត្តិធម៌ពិតប្រាកដមួយដល់ជនរងគ្រោះ ។ ផ្នែកទី៤) គឺជាវេទិកាពិភាក្សា និង ផ្ដល់គំនិតនានាលើបញ្ហាខ្មែរក្រហម ។ អត្ថបទទីនេះ គឺជាវិភាគទានចូលរួមពីសំណាក់អង្គការក្រៅរដ្ឋាភិបាលនានា សមាជិករាជរដ្ឋាភិបាល គ្រូ សិស្ស និស្សិត ជាដើម ។ល ។ ផ្នែកទី៥) គឺជាទំព័រស្រាវជ្រាវស្វែងរកក្រុមគ្រួសារដែលបានស្លាប់ ឬ បាត់ខ្លួនក្នុងរបបខ្មែរក្រហម ឬការសាកសួររកព័ត៌មានអំពីមិត្តភក្ដិ សាច់សារលោហិតដែលបានស្លាប់ដោយសាររបបខ្មែរក្រហម ។ ជាទំព័រឈឺចាប់ អាណោចអាធ័ម ប៉ុន្តែក៏ជាទំព័ររម្ងាប់ការមន្ទិលសង្ស័យដើម្បីសេចក្ដីសុខក្នុងខ្លួនជាអមតៈដែរ ។*

*សរុបសេចក្ដីទៅផ្នែកទាំង៥ ខាងលើនៃគេហទំព័រ* www.truthcambodia.com *នឹងបើកចំហជូនដល់ការចូលរួមស្វែងរកការពិតពីសាធារណជនគ្រប់ស្រទាប់ ជាន់ថ្នាក់ ដោយមិនប្រកាន់ពណ៌សម្បុរ ភេទ អាយុ ឬនិន្នាការនយោបាយណាមួយឡើយ ។ គេហទំព័រ* www.truthcambodia.com *នឹងបម្រើដល់សាធារណជន និងដើម្បីជួយជ្រោមជ្រែងស្វែងរកយុត្តិធម៌ជូនដល់ប្រជាជនកម្ពុជាគ្រប់រូប ។ គ្រប់លិខិត ឬអត្ថបទ ដែលផ្ញើមកកាន់គេហទំព័រ* www.truthcambodia.com *សូមដាក់ឈ្មោះ មុខងារ អាសយដ្ឋាន និងលេខទូរសព្ទសម្រាប់ធ្វើសេចក្ដីបញ្ជាក់លើខ្លឹមសារនៃលិខិត ឬអត្ថបទ មុនការចេញផ្សាយ ។*

*គេហទំព័រ* www.truthcambodia.com *សូមរក្សាសិទ្ធិក្នុងការកែលម្អពាក្យពេចន៍នៃលិខិតទាំងឡាយ ក្នុងន័យថែរក្សានូវអត្ថន័យដើមទាំងស្រុង ។ ប៉ុន្តែ គេទំព័រ* www.truthcambodia.com *នឹងចុះផ្សាយទាំងស្រុងចំពោះអត្ថបទចូលរួមទាំងឡាយ ។*

# យុវជន-យុវនារីបដិវត្តន៍ប្តេជ្ញាចុះប្រឡូកធ្វើពលកម្ម បង្កបង្កើនផល ដើម្បីលត់ដំ ពង្រឹងគោលជំហរ បដិវត្តន៍ខ្លួនផង និងរួមចំណែកការពារ និងកសាងប្រទេសជាតិយ៉ាងសកម្មផង

*ដកស្រង់ចេញទស្សនាវដ្តីយុវជន និងយុវនារីបដិវត្តន៍ លេខ៧ ខែកក្កដា ឆ្នាំ១៩៧៥ ឯកសារD២១៣៨១*

ក្នុងសម័យសង្រ្គាមបដិវត្តន៍ ចលនាក្តៅធំមានបី គឺ ៖ ចលនាវាយសម្រុកខ្លាំងនៅសមរភូមិមុខមួយ ចលនារកទឹកបង្កបង្កើនផលនៅសមរភូមិក្រោយមួយ និងចលនាតស៊ូកសាងផ្ទៃក្នុងមួយ ។ កន្លងមក យុវជន យុវនារីបដិវត្តន៍យើង បានចុះប្រឡូក សស្រោកសស្រាំ ក្នុងចលនាក្តៅធំទាំងបីនេះ ដើម្បីលត់ដំកសាងខ្លួនផង និងរួមចំណែកយ៉ាងសកម្មក្នុងសង្រ្គាមបដិវត្តន៍ វាយបណ្តេញចក្រពត្តិអាមេរិក និងបរិវារ និងវាយរំលំរបបអាណានិគមនិយមថ្មីរបស់បក្សពួកអាក្បត់លន់នល់, សិរីមតៈ, សឺង ង៉ុកថាញ់, ចេង ហេង, អ៊ិន តាំ, ឡុង បូរេត, សុស្តែន ផង រហូតដល់បណ្តើមបានជ័យជម្នះទាំងស្រុង និងជាស្ថាពរ ។ ដូច្នេះ ក្នុងសម័យសង្រ្គាមបដិវត្តន៍តឹងតែងលំបាកវេទនាបំផុតកន្លងទៅនេះ យុវជន យុវនារីបដិវត្តន៍យើង បានលត់ដំសាកល្បងនឹងកសាងពង្រឹងគោលជំហរបដិវត្តន៍ខ្លួន ទាំងខាងនយោបាយ សតិអារម្មណ៍ និងចាត់តាំងក្នុងចលនាក្តៅធំបីនេះ ជាបន្តបន្ទាប់ជាប់ជានិច្ច ។ ដោយសារយើងមានគោលជំហរបដិវត្តន៍ខ្ពង់ខ្ពស់ ទាំង



កសិករសហករណ៍ នៅស្រុកកោះធំ កំពុងនាំគ្នាប្រមូលផលពោតទុកខ្ចុកខ្ចូនខ្លួន និងខ្ចុកកងទ័ពនៅសមរភូមិមុខ

ខាងគោលជំហរមាគ៌ានយោបាយក៏រឹងប៉ឹង ទាំងខាងគោលជំហរសតិអារម្មណ៍ក៏ត្រឹមត្រូវ ទាំងខាងគោលជំហរចាត់តាំងក៏ត្រឹមត្រូវហ្មត់ចត់ ទើបយើងអាចវាយឈ្នះចក្រពត្តិអាមេរិក ដែលជាមហាអំណាចចក្រពត្តិធំជាងគេបំផុត និងសាហាវឃោរឃៅបំផុតនៅលើសកលលោកនេះ ។

ឥឡូវ ប្រទេសជាតិយើងត្រូវបានរំដោះទាំងស្រុង និងជាស្ថាពរហើយ ។ សុខសន្តិភាពក៏កើតមានឡើងវិញ នៅលើទឹកដីកម្ពុជាយើងហើយដែរ តែយុវជន យុវនារីបដិវត្តន៍យើង នៅត្រូវពង្រឹងគោលជំហរបដិវត្តន៍ខ្លួន លើគ្រប់ផ្នែកឲ្យកាន់តែរឹងប៉ឹងថែមទៀត ដើម្បីសម្រេចភារកិច្ចការពារប្រទេស និងកសាងប្រទេសឈានទៅដល់ទីដៅប្រកបដោយជោគជ័យទាំងស្រុងក្នុងពេលខាងមុខឆាប់ៗនេះ ។ ដោយប្រទេសកម្ពុជា ជាប្រទេសកសិកម្មឱនថយកិច្ចការពារប្រទេស និងកសាងប្រទេសត្រូវផ្អែកលើកសិកម្មជាមូលដ្ឋាន ព្រោះយើងមានទុនជាមធ្យោបាយផលិតកម្មខាងកសិកម្មគ្រប់គ្រាន់ ។

ដូច្នេះ ចលនាក្តៅ និងធំជាងគេក្នុងសម័យការពារប្រទេស និងកសាងប្រទេស ក្រោយពេលរំដោះនេះ គឺចលនាបង្កបង្កើនផល ។ ដូច្នេះ យុវជន យុវនារីបដិវត្តន៍យើងទាំងអស់ ត្រូវចុះប្រឡូកធ្វើពលកម្មបង្កបង្កើនផល ឲ្យសស្រោកសស្រាំ ដើម្បីលត់ដំកសាង និងពង្រឹងគោលជំហរបដិវត្តន៍ខ្លួនផង និងរួមចំណែកការពារប្រទេស និងកសាងប្រទេសឲ្យចាកផុតពីភាពជាប្រទេសកសិកម្មឱនថយឈានទៅកាន់ឋានៈជាប្រទេសកសិកម្មសម័យ និងឧស្សាហកម្មឲ្យបានឆាប់រហ័សផង ។

ជាក់ស្តែងយុវជនយុវនារីបដិវត្តន៍យើង ត្រូវចុះទៅជនបទចូលប្រឡូកជាមួយប្រជាជនកសិករយើង លើកទំនប់ ជីកស្រះ ជីកប្រឡាយ ធ្វើអាងទឹកឲ្យបានច្រើនស្អេកស្កះពាសពេញនៅគ្រប់ភូមិឃុំ ដើម្បីម្ចាស់ការលើបញ្ហាទឹកឲ្យបានកម្រិតកាន់តែខ្ពស់ថែមទៀត ។ ធ្វើយ៉ាងនេះទើបយើងអាចបង្កបង្កើនផលបានទាំងប្រាំងទាំងវស្សា ដោយឯករាជ្យម្ចាស់ការពីមេឃពីភ្លៀង ។ ដូច្នេះ ទើបយើងអាចវាយសម្រុកបង្កបង្កើនផលបានពេញទំហឹង ដោយប្រើអស់លទ្ធភាពដី លទ្ធភាពទឹក និងលទ្ធភាពកម្លាំងពលកម្មដែលយើងមាន ។ ធ្វើយ៉ាងនេះ ទើបយើងអាចជំរុញចលនាបង្កបង្កើនផល និងបង្កើនផលិតផលកសិកម្ម ឲ្យបានឡើងខ្ពស់ជាលំដាប់ និងដោយសន្ទុះលឿនទៀតផង ។ ដូច្នេះបញ្ហាគន្លឹះនៅក្នុងចលនាបង្កបង្កើនផល គឺបញ្ហាទឹកដែលយើងត្រូវគិតគូរដោះស្រាយជាបន្ទាន់ ។ ឲ្យតែមានទឹក គឺយើងនឹងអាចដាំអ្វីៗបានទាំងអស់ ហើយដាំបានគ្រប់រដូវទៀតផង ។

ព្រមជាមួយគ្នានេះ យុវជន យុវនារីយើង ត្រូវចុះប្រឡូកធ្វើស្រែជាមួយប្រជាជនយើង ដោយចុះប្រឡូកភ្ជួររាស់ ដកស្ទូងឲ្យសស្រោកសស្រាំ និងស្វាហាប់សកម្មប្រយុទ្ធក្នុងស្មារតីវាយសម្រុកដូចកាលយើងវាយសម្រុកខ្មាំងនៅសមរភូមិមុខក្នុងសម័យសង្គ្រាមបដិវត្តន៍ដូច្នោះដែរ ។

ដើម្បីចុះប្រឡូកវាយសម្រុកក្នុងចលនាបង្កបង្កើនផលឲ្យបានស្វាហាប់ យុវជន យុវនារីយើង ជាបឋម ត្រូវជម្រុះទស្សនៈខុសឆ្គងពីសង្គមចាស់ ឲ្យអស់រលីងជ្រះស្រឡះសិន ហើយបំពាក់នូវទស្សនៈគោលជំហរបដិវត្តន៍ត្រឹមត្រូវ ចំពោះការងារពលកម្មបង្កបង្កើនផលនេះ ឲ្យបានរឹងប៉ឹង ទើបយើងយល់នូវតម្លៃនៃការងារពលកម្មបង្កបង្កើនផល ហើយពេញចិត្តពេញថ្លើម និងចុះទៅប្រឡូកធ្វើការងារពលកម្មបង្កបង្កើនផលជាមួយប្រជាជនយើង ។ ដូច្នេះទើបយើងបង្កបង្កើនផលក្នុងសន្ទុះស្វាហាប់ និងសកម្មប្រយុទ្ធដោយទ្រាំទ្រការលំបាកវេទនា ខ្វះសព្វខ្វះគ្រប់ និងអាចពុះពារនូវគ្រប់ឧបសគ្គតូចធំទាំងប៉ុន្មានដែលយើងនឹងជួបប្រទះ ។

**១) ទស្សនៈខុសឆ្គងចំពោះការងារពលកម្មបង្កបង្កើនផល**

កាលនៅក្នុងសង្គមចាស់ ដែលជាសង្គមអាណានិគមពាក់កណ្តាលសក្តិភូមិ និងជាសង្គមមនុស្សជិះជាន់មនុស្ស ពួកចក្រពត្តិសក្តិភូមិ នាយទុនប្រតិកិរិយា វារស់នៅហ៊ឹហា សម្បូរសប្បាយដោយសារតែការជិះជាន់កម្លាំងពលកម្មរបស់ប្រជាជន កម្មករ កសិករ និងពលករផ្សេងទៀតទាំងអស់ ។ ចំណែកឯពួកវា គ្មានបញ្ចេញកម្លាំងធ្វើពលកម្មបង្កបង្កើនផលអ្វីបន្តិចបន្តួចសោះឡើយ ។ ពួកវាជិះជាន់ប្រជាជន ពលករ ដែលជាអ្នកបង្កបង្កើនផលចិញ្ចឹមផ្គត់ផ្គង់ក្បាលពួកវា បីដូចជាសត្វធាតុទៀត ។ ព្រមជាមួយនេះ ពួកវានៅបានផ្សព្វផ្សាយនូវទស្សនៈគោលជំហរប្រតិកិរិយារបស់ពួកវានេះ ទៅក្នុងចំណោមយុវជនយុវនារីយើង ឃោសនាអប់រំយុវជនយុវនារីយើង ឲ្យស្អប់ខ្ពើម មើលងាយមើលថោកការងារពលកម្ម

បង្កបង្កើនផលទៀតផង ។ ពោលគឺវាអប់រំឲ្យយុវជន យុវនារីយើង ស្អប់ខ្ពើម និងមើលងាយ មើលថោកប្រជាជន ពលករ ដែលជាអ្នកផលិតស្បៀងអាហារ និងរបស់របរប្រើប្រាស់សព្វសារពើ ដើម្បីពន្លក់យុវជន យុវនារីយើង ឲ្យរីករាយស្ម័គ្រចិត្ត និងមានមោទកភាពទៅធ្វើជាឧបករណ៍ ឬជាដៃជើងរបស់ពួកវា មកជិះជាន់បង្ក្រាប រាតត្បាតប្រជាជនឯងវិញ យ៉ាងព្រហើនកោងកាចបំផុត ។

ដូច្នេះហើយ បានជាកាលនៅក្នុងសង្គមចាស់ យុវជន យុវនារីយើងជាទូទៅ មានទស្សនៈគោលជំហរស្អប់ខ្ពើម និងមើលងាយ មើលថោកការងារពលកម្ម បង្កបង្កើនផលជាទីបំផុត ហើយគេចាត់ទុកកម្មករ កសិករ និងប្រជាជនពលករផ្សេងៗ ថាជាមនុស្សថោកទាបជាងគេនៅក្នុងសង្គមជាតិ ។ ម្ល៉ោះហើយ ខ្លួនគេក៏ប្រកែប្រកាន់ខ្លួន មិនហ៊ានធ្វើការងារពលកម្ម បង្កបង្កើនផលទេ ខ្លាចទាបថោក ខ្លាចគេមើលងាយ ខ្លាចគេថាខ្លួនអន់ ។ ដូច្នេះ បើធ្វើការងារពលកម្ម គេមានទស្សនៈសតិអារម្មណ៍ខ្មាស់គេ ។ ដោយយុវជន យុវនារីនៅក្នុងសង្គមចាស់ភាគច្រើនលើសលប់ មានទស្សនៈគោលជំហរខុសឆ្គងបែបនេះ ពួកចក្រពត្តិ សក្តិភូមិ នាយទុនប្រតិកិរិយា ក៏ងាយអូសទាញ និងទិញទឹកចិត្តយុវជន យុវនារីយើង ឲ្យទៅធ្វើជាឧបករណ៍បម្រើការជិះជាន់ និងអំពើឧបាយមុខពាលយង់ឃ្នងរបស់ពួកវាបានដោយស្រួលដែរ ។

ឧទាហរណ៍ៈ បើយុវជន យុវនារី ជាកូនអ្នកមានសម្បត្តិទ្រព្យ គ្មានចេះធ្វើពលកម្មអ្វីសោះ ។ គេរស់នៅសប្បាយហ៊ឺហា សម្បូរបែប ដោយសារតែទ្រព្យសម្បត្តិធនធានដែលឪពុកម្តាយ គេរកស៊ីមានបានលើគំនរញើសឈាម និងគំនរទុក្ខវេទនារបស់ប្រជាជនពលករយើង ។ គេត្រៀមចាំតែបន្តវេនជិះជាន់ សង្កត់សង្កិនលើប្រជាពលករ ជាបន្តពីឪពុកម្តាយគេទៀត ។

ឧទាហរណ៍ៈ បើជាកូនអ្នកខ្សត់ខ្សោយវិញ យុវជន យុវនារីយើងដែលមានបញ្ញាឈ្លាសវៃ គិតតែពីខិតខំរៀនសូត្របានសញ្ញាបត្រធំ ដើម្បីបានធ្វើនាហ្មឺន មន្ត្រី បានប្រាក់ខែច្រើន អាចរស់នៅសុខស្រួលសម្បូរសប្បាយ ដោយមិនបាច់ធ្វើការងារពលកម្មបង្កបង្កើនផលហត់នឿយច្រើន ។ ទោះបីខ្លួនគេត្រូវធ្លាក់ខ្លួនទៅជាឧបករណ៍ជាបរិវារ ឬជាដៃជើងរបស់ចក្រពត្តិអាណានិគមបរទេស និងរបស់សក្តិភូមិ នាយទុនប្រតិកិរិយា ក្នុងការជិះជាន់រាតត្បាត កាប់សម្លាប់ប្រជាជនឯងយ៉ាងឃោរឃៅព្រៃផ្សៃ ហ្វាស៊ីសយ៉ាងណាក៏គេមិនគិតដែរ ។ ចង់ប្រទេសជាតិ ប្រជាជនខ្លួន ធ្លាក់ទៅជាខ្ញុំកញ្ជះចក្រពត្តិអាណានិគម ឬមហាអំណាចបរទេសណា ក៏គេមិនឈឺចាប់ដែរ ។ ចង់ប្រជាជនខ្លួនរងទុក្ខវេទនា អត់ឃ្លានដាច់ពោះស្លាប់គរដើរលើគ្នាយ៉ាងណា ក៏គេមិនខ្វល់ដែរ ។ គេគិតតែពីធ្វើយ៉ាងណា ឲ្យខ្លួនគេ និងក្រុមគ្រួសារគេ អាចរស់នៅស្រណុកសុខស្រួល ដោយមិនបាច់ធ្វើការងារពលកម្មធ្ងន់ ។

ឧទាហរណ៍ៈ យុវជន យុវនារីខ្លះទៀត ដែលខ្វះមធ្យោបាយរៀនសូត្រ ឬមានបញ្ញាមិនសូវគ្រប់គ្រាន់ មិនអាចរៀនយកសញ្ញាបត្រធំ ធ្វើជានាហ្មឺន មន្ត្រីដូចគេបាន ក៏មិនព្រមចុះទៅជនបទជួយបង្កបង្កើនផលឪពុកម្តាយ ដើម្បីចិញ្ចឹមជីវិតដែរ ។ យុវជន យុវនារីខ្លះ សុខចិត្តលក់អាយុជីវិតខ្លួន ទៅធ្វើជាសាច់ទ័ព ឬធ្វើជាកុម្ម៉ង់ដូបម្រើការឈ្លានពាន និងអំពើរីបជាន់ ឆក់ប្លន់របស់ចក្រពត្តិអាណានិគមបរទេស និងរបស់សក្តិភូមិ នាយទុនប្រតិកិរិយាក្បត់ជាតិ មកកាប់សម្លាប់ ឆក់ប្លន់ប្រជាជនឯងទៅវិញ ។

យុវជន យុវនារីខ្លះ សុខចិត្តប្រព្រឹត្តអំពើចោរកម្ម ដើរឆក់ ដើរលួច ដើរប្លន់ទ្រព្យសម្បត្តិគេទៅចិញ្ចឹមជីវិត ជាជាងធ្វើពលកម្មបង្កបង្កើនផលឧបត្ថម្ភខ្លួន ។

យុវនារីខ្លះទៀត រហូតដល់ទៅសុខចិត្តលះបង់កេរ្តិ៍ខ្មាសលក់រូបរាងកាយ លក់រូបឆោមរបស់ខ្លួន ធ្វើជាប្រពន្ធចុងរបស់គេ ឬធ្វើជាស្រីពេស្យា ដើម្បីបានប្រាក់កាសចិញ្ចឹមជីវិត តែមិនសុខចិត្តចុះទៅជនបទបង្កបង្កើនផលចិញ្ចឹមជីវិត រស់នៅក្នុងសេចក្តីថ្លៃថ្នូរទេ ។ល ។

ឧទាហរណ៍ទាំងអស់នេះ បញ្ជាក់ឲ្យឃើញច្បាស់ថា ដោយសារតែមានទស្សនៈគោលជំហរខុសឆ្គងចំពោះការងារពលកម្ម បង្កបង្កើនផលនេះ កាលនៅក្នុងសង្គមចាស់ យុវជន យុវនារីយើងច្រើនលើសលប់ បានធ្លាក់ទៅជាចំណីរបស់ចក្រពត្តិអាណានិគមបរទេស និងជាចំណីរបស់សក្តិភូមិ នាយទុនប្រតិកិរិយាយ៉ាងឈឺចាប់ខ្លោចផ្សាបំផុត ។

នៅក្នុងជួរបដិវត្តន៍ និងក្នុងជួរប្រជាជនយើង សព្វថ្ងៃហើយក៏ដោយ ទស្សនៈគោលជំហរស្អប់ខ្ពើម មើលងាយមើលថោកការងារពលកម្មបង្កបង្កើនផលនេះ ក៏មិនទាន់សាបរលាបអស់ដែរ ដូច្នេះហើយបានជាមានយុវជន យុវនារីយើងខ្លះ (ចំនួនតិចទេ) នៅមិនទាន់ស្រឡាញ់ចូលចិត្តការងារពលកម្មបង្កបង្កើនផល នៅមិនទាន់

ពេញចិត្តពេញថ្លើម និងចុះទៅប្រឡូក ធ្វើពលកម្មរកទឹកបង្កបង្កើនផល ជាមួយប្រជាជនកសិករនៅឡើយ ។ គេនៅចូលចិត្តធ្វើការងាររការិយាល័យ មន្ទីរ ក្រសួង ធ្វើពេទ្យ ឬជាំបាយ ឬធ្វើកងការពារ ។ល ។ បើអង្គការប្រគល់ការងារទាំងនេះឲ្យធ្វើ គេរីករាយសប្បាយចិត្ត ។ តែបើអង្គការប្រគល់ភារកិច្ច ឲ្យចុះទៅបង្កបង្កើនផលនៅកសិដ្ឋាន ឬចុះទៅជនបទបង្កបង្កើនផលជាមួយប្រជាជនក្នុងក្រុមសហករណ៍ គេមិនរីករាយ មិនជ្រះថ្លាទេ ។ ជួនកាលរហូតដល់ទៅមានការមន្ទិលសង្ស័យថា អង្គការដាក់ទោស ឬធ្វើទណ្ឌកម្មគេទៀតផង ។ ម៉្លោះហើយ គេចុះទៅបង្កបង្កើនផល ទាំងក្តីទោមនស្ស ទាំងអាក់អន់ស្រពន់ចិត្ត ។ ដូច្នេះ គេធ្វើពលកម្មបង្កបង្កើនផល ដោយសោះអង្គើយ មិនស្វាហាប់ មិនសកម្មប្រយុទ្ធ ពុះពារការលំបាក ពុះពារឧបសគ្គតូចធំឡើយ ។ បើធ្វើបានក៏ធ្វើ បើជួបឧបសគ្គអ្វីបន្តិចបន្តួច ក៏រាថយ ។ បើធ្វើបានប៉ុណ្ណា ក៏យកប៉ុណ្ណឹង បើធ្វើមិនបានក៏ហី ។ ដូច្នោះ គេបង្កបង្កើនផល ដោយគ្មានស្មារតីទទួលខុសត្រូវចំពោះបក្ស និងប្រជាជនឡើយ គេគ្មានទស្សនៈវាយសម្រុកថា បង្កបង្កើនផល ដើម្បីការពារប្រទេស និងកសាងប្រទេសជាតិឡើយ ។ បើមិត្តយើងបង្កបង្កើនផលក្នុងទស្សនៈគោលជំហរខុសឆ្គងបែបនេះ នោះប្រាកដជាពុំអាចលត់ដំកសាងខ្លួន និងពង្រឹងគោលជំហរបដិវត្តន៍ខ្លួនបានឡើយ ទោះបីជាមិត្តយើងធ្វើពលកម្មជប់ម្ភៃឆ្នាំទៅមុខទៀតក៏ដោយ ហើយប្រាកដជាពុំអាចរួមចំណែកការពារ និងកសាងប្រទេសដោយជោគជ័យឡើយ ។

២) ទស្សនៈគោលជំហរបដិវត្តន៍ ចំពោះការងារពលកម្មបង្កបង្កើនផលៈ

ចំពោះជនកុម្មុយនីស្ត ជនបដិវត្តន៍ និងជនចម្រើនជឿនលឿនទាំងអស់នៅលើសកលលោក ការងារពលកម្មបង្កបង្កើនផលជាការងារដែលមានតម្លៃជាងគេបំផុតនៅក្នុងលោកយើងនេះ ។ បើគ្មានការងារពលកម្មបង្កបង្កើនផល ពោលគឺបើគ្មានកម្មករ កសិករ និងពលករផ្សេងៗទៀតទេ នោះមនុស្សយើងនឹងពុំមានស្បៀងអាហារ ពុំមានសម្លៀកបំពាក់ និងប្រដាប់ប្រដាប្រើប្រាស់ជាចាំបាច់ផ្សេងៗឡើយ ។ សង្គមមនុស្សយើង ក៏ពុំអាចចម្រើន ជឿនលឿនទៅមុខបានដែរ ។ សរុបទៅ បើគ្មានការងារពលកម្ម បង្កបង្កើនផល មនុស្សយើងក៏ពុំអាចរស់រានមានជីវិតបានដែរ ។

បើយើងពិនិត្យមើលតែក្នុងក្របខណ្ឌប្រទេសជាតិយើង ក្នុង



កងចល័តនៅស្រុកកៀនស្វាយ កំពុងជញ្ជូនស្មៅ រៀបចំដីសម្រាប់ស្ទូងស្រូវប្រាំង ឲ្យបានស្អាត និងកំពុងវាយសម្រុកស្ទូងស្រូវប្រាំង នៅការដ្ឋានស្រែអំពិល



កសិករនៅស្រុកកោះធំដាក់រហាត់បញ្ចូលទឹកក្នុងស្រែ នៅទំនប់ជ្រោយស្រូវ

សម័យសង្គ្រាមបដិវត្តន៍ វាយចក្រពត្តអាមេរិក និងបរិវារ ក៏យើងអាចឃើញតួនាទី និងសារសំខាន់ដ៏ធំធេងសម្បើមណាស់ នៃចលនាបង្កបង្កើនផល ។ ក្នុងពេលដែលវីរកងកម្លាំងប្រដាប់អាវុធបដិវត្តន៍យើង បើកឆាកវាយសម្រុកខ្លាំងយ៉ាងខ្លាំងក្លាបំផុតនៅសមរភូមិមុខ បើប្រជាជនយើងនៅសមរភូមិក្រោយ មិនវាយសម្រុកបង្កបង្កើនផលឲ្យខ្លាំងក្លា សស្រោកសស្រាំ ទាំងយប់ទាំងថ្ងៃ ទាំងប្រាំង ទាំងវស្សាទេ នោះកងទ័ពយើង មុខជាខ្វះស្បៀងហើយ ។ ដូច្នេះ មុខជាគ្មានកម្លាំងវាយសម្រុកខ្លាំងឡើយ ។ដូច្នោះ យើងពុំអាចដណ្ដើមមហាជ័យជម្នះជាប្រវត្តិសាស្ត្រដូចសព្វថ្ងៃនេះបានឡើយ ។ សរុបមក បើគ្មានចលនាបង្កបង្កើនផល នៅសមរភូមិក្រោយ ក៏គ្មានមហាជ័យជម្នះសព្វថ្ងៃនេះដែរ ។

ក្នុងសម័យសន្តិភាព ដែលយើងរំដោះប្រទេសជាតិយើង បានទាំងមូលហើយនោះ ភារកិច្ចចម្បងរបស់យើង គឺត្រូវវាយសម្រុកបង្កបង្កើនផល ឲ្យបានកាន់តែខ្លាំងក្លា និងកាន់តែច្រើនទ្វេឡើង មួយជា១០០ដងថែមទៀត ដើម្បីមានលទ្ធភាពការពារប្រទេស និងកសាងប្រទេសជាតិយើង ឲ្យបានខ្លាំងក្លា និងសម្បូរសប្បាយក្នុងរយៈពេលដ៏ខ្លីខាងមុខនេះ ។

ដើម្បីការពារប្រទេស និងកសាងប្រទេសជាតិឲ្យបានឈានដល់ទិសដៅដូចដែលយើងចង់បាននេះ យុវជន យុវនារីយើង ត្រូវមានទស្សនៈឲ្យបានច្បាស់លាស់ និងត្រឹមត្រូវថា ប្រទេសកម្ពុជាយើងជាប្រទេសកសិកម្មឧិនថយ ។ ដូច្នេះ ជាជំហានដំបូង ក្នុងការកសាងប្រទេសជាតិ យើងត្រូវផ្អែកលើកសិកម្ម ពិសេសការបង្កបង្កើនផលខាងកសិកម្មជាមូលដ្ឋាន មិនមែនផ្អែកលើឧស្សាហកម្មជាមូលដ្ឋានទេ ។ ក្នុងកិច្ចដំណើរការខាងកសិកម្មនេះទៀតសោត ក៏ត្រូវមានទស្សនៈគោលជំហរ ឯករាជ្យ ម្ចាស់ការ ខ្លួនទីពឹងខ្លួនជាសំខាន់ មិនមែនពឹងផ្អែកលើជំនួយបរទេសជាសំខាន់ទេ ។ ដូច្នេះ គឺត្រូវពឹងផ្អែកលើកម្លាំងពលកម្មយើងជាសំខាន់ មិនមែនផ្អែកលើម៉ាស៊ីនជាសំខាន់ទេ ព្រោះម៉ាស៊ីនម្យ៉ាងយើងមិនទាន់ចេះធ្វើម្យ៉ាងទៀតវាស៊ីសាំងច្រើន ដែលប្រទេសយើងពុំទាន់ផលិតបាន ហើយវាជារបស់របរដែលយើងត្រូវទិញចូលពីបរទេសទាំងអស់ ។ ដូច្នេះ បើយើងពឹងផ្អែកលើម៉ាស៊ីន យើងដោះស្រាយមិនរួចទេ ឬមួយ យើងត្រូវពឹងពាក់សុំជំនួយបរទេស ។ បើធ្វើដូច្នេះ យើងនឹងពុំអាចឯករាជ្យ ម្ចាស់ការក្នុងកិច្ចការពារប្រទេស និងកសាងប្រទេសជាតិយើងបានឡើយ ។

កន្លងមក ក្នុងសម័យសង្គ្រាមបដិវត្តន៍ វាយចក្រពត្តិអាមេរិក និងបរិវារ យើងហ៊ានធ្វើពលិកម្មកម្រិតខ្ពស់ ទ្រាំទ្រការលំបាកវេទនាគ្រប់បែបយ៉ាង ខ្វះសព្វខ្វះគ្រប់ ធ្វើការតស៊ូបដិវត្តន៍ដោយឯករាជ្យម្ចាស់ការ ខ្លួនទីពឹងខ្លួនកម្រិតខ្ពស់បំផុត ដើម្បីរក្សានូវឯករាជភាព និងអធិបតេយ្យភាពរបស់ប្រជាជាតិ និងប្រជាជនយើងដាច់ខាត រហូតដល់ដណ្ដើមបានមហាជ័យជម្នះទាំងស្រុង និងជាស្ថាពរ ។ ឥឡូវយើងមានសុខសន្តិភាពហើយ យើងក៏ចង់ការពារ និងកសាងប្រទេសជាតិយើងដោយឯករាជ្យ ម្ចាស់ការតទៅទៀត ។ ដូច្នេះ ក្នុងកិច្ចដំណើរការការពារប្រទេស និងកសាងប្រទេសជាតិយើងបច្ចុប្បន្ន និងតទៅអនាគតទៀត យើងត្រូវពឹងផ្អែកលើធនធាននៃប្រទេសជាតិយើងលើកម្លាំងពលកម្មរបស់ប្រជាជនយុវជនយុវនារីយើងជាសំខាន់ ។ យើងមានលទ្ធភាពធ្វើបានពេញទី ព្រោះសព្វថ្ងៃ យើងមានមធ្យោបាយផលិតកម្មគ្រប់គ្រាន់ ជាដីធ្លី ដែលសម្បូរទៅដោយជីវជាតិ (ដីខ្មៅ ដីក្រហម ដីល្បាប់តាមមាត់ទន្លេ) ជាគោ-ក្របី ជាទន្លេ ស្ទឹង បឹងបួរ ដែលជាប្រភពផ្ដល់ទឹកគ្រប់គ្រាន់ ខួបប្រាំងខួបវស្សា ។ យើងមានកម្លាំងផលិតកម្មខ្លាំងក្លា ជាប្រជាជន យុវជន យុវនារី ដែលអន់អាចក្លាហាន មោះមុត ធ្លាប់ប្រយុទ្ធវាយឈ្នះចក្រពត្តិអាមេរិក និងបរិវារ និងជាកម្លាំងផលិតកម្មដែលត្រូវបានរំដោះ ទាំងនយោបាយ ទាំងសម្ភារ ទាំងស្មារតី ជាកម្លាំងផលិតកម្ម ដែលមានការភ្ញាក់រលឹកនយោបាយ និងភ្ញាក់រលឹកវណ្ណៈកម្រិតខ្ពស់ ។ ដូច្នេះ ជាកម្លាំងផលិតកម្មខ្លាំងក្លាមហិមាណាស់ ។ ក្រៅពីនេះ យើងមានរដ្ឋអំណាចនៅក្នុងដៃដែលអាចចាត់ចែងកិច្ចការសព្វសារពើ ទៅតាមឧត្តមគតិ និងសម

ស្របតាមផលប្រយោជន៍ដ៏ឧត្តុង្គឧត្តម នៃប្រទេសជាតិ និងប្រជាជនយើង ។

ដូច្នេះ បញ្ហាគន្លឹះនៅតែប្រជាជន និងយុវជន យុវនារីយើង ចុះប្រឡូកធ្វើដោយសកម្មប្រយុទ្ធ ស្វាហាប់ សស្រាក់សស្រាំ និងដោយស្មារតីទទួលខុសត្រូវខ្ពស់ ក្នុងឋានៈជាម្ចាស់ប្រទេស ម្ចាស់បដិវត្តន៍ ដែលកាន់កាប់វាសនាប្រទេសជាតិ និងប្រជាជនខ្លួនពេញទីប៉ុណ្ណោះ ។ បើយើងវាយសម្រុកបង្កបង្កើនផលបានច្រើន ជាស្រូវ អង្ករ ត្រីសាច់ ឈើព្រៃ កៅស៊ូ ពោត សណ្តែកលូ ។ល ។ នោះយើងនឹងអាចដោះស្រាយ កែប្រែជីវភាពប្រជាជនយើង ឲ្យបានគ្រប់គ្រាន់សម្បូរធូរធាផង និងអាចដឹកនាំចេញទៅលក់ដូរនៅឯបរទេសផង ហើយទិញជាម៉ាស៊ីន ជារោងចក្រ ជាគ្រឿងសាស្ត្រាវុធ និងរបស់របរប្រើប្រាស់ចាំបាច់ផ្សេងៗទៀត ដើម្បីយកមកការពារប្រទេស និងកសាងប្រទេសជាតិយើង ឲ្យឈានទៅជាប្រទេសកសិកម្មសម័យ និងឧស្សាហកម្មជាបណ្តើរៗ ។ ដូច្នេះ ឲ្យតែមានផលិតផលកសិកម្មច្រើន នោះយើងនឹងអាចការពារប្រទេស និងកសាងប្រទេសយើងដោយឯករាជ្យ ម្ចាស់ការបានពេញទី ។ ដូច្នេះ ដើម្បីកិត្តិយសជាតិ ដើម្បីសេចក្តីថ្កុំថ្កើងរុងរឿងនៃប្រទេសជាតិយើង និងដើម្បីរក្សានូវឯករាជភាព និងអធិបតេយ្យភាពរបស់ប្រទេសជាតិ និងប្រជាជនយើងបានជារៀងរហូតទៅ យុវជនយុវនារីកម្ពុជា មិនត្រូវដេកចាំសុំទានជំនួយបរទេសឡើយ ។ យើងត្រូវពឹងផ្អែកធនធាននៃប្រទេសជាតិយើង លើកម្លាំងពលកម្មយើង លើសមត្ថភាព និងលទ្ធភាពរបស់ប្រជាជនយើង ហើយនាំគ្នាលាត់ដៃអាវមូរជើងខោ យ៉ាងណែនចុះប្រឡូក ធ្វើពលកម្មបង្កបង្កើនផលឲ្យសស្រាក់សស្រាំឡើង វាយសម្រុកស្តារសេដ្ឋកិច្ច និងកសាងប្រទេសជាតិយើងទាំងអស់គ្នា ។ ឲ្យតែមានផលិតផលកសិកម្មច្រើន នោះយើងនឹងមានអ្វីៗទាំងអស់ ដែលយើងចង់បាន ។ យើងមានលទ្ធភាពធ្វើពេញទី ។

ដូច្នេះ ការចុះប្រឡូកធ្វើពលកម្មបង្កបង្កើនផល ជាការរួមចំណែកយ៉ាងសកម្ម និងយ៉ាងស័ក្តិសិទ្ធបំផុតក្នុងកិច្ចការពារប្រទេស និងកសាងប្រទេស នាយុគសម័យថ្មីយើងនេះ ។ មិនត្រឹមតែប៉ុណ្ណោះ ការងារពលកម្មបង្កបង្កើនផល កែប្រែនូវលោកទស្សនៈរបស់យើង ពីស្អប់ខ្ពើម មើលងាយមើលថោកការងារពលកម្ម មកស្រឡាញ់ និងគោរពការងារពលកម្មវិញ ពីស្អប់ខ្ពើមមើលងាយមើលថោក ជិះជាន់សង្កត់សង្កិនប្រជាជន ពលករ មកមានមនោសញ្ចេតនា ស្រឡាញ់គោរព និងជឿជាក់លើកម្លាំងប្រជាជនពលករវិញ ។ ដូច្នេះ ការងារពលកម្មបង្កបង្កើនផល វាកសាងនិងពង្រឹងនូវគោលជំហរស្នេហាមាតុភូមិ ស្នេហាជាតិ និងគោលជំហរគោរពស្រឡាញ់ និងស្មោះត្រង់បម្រើប្រជាជនជានិច្ច ។ ដូច្នេះ ការងារពលកម្ម បង្កបង្កើនផល វាពង្រឹងជំហរជាតិ និងជំហរវណ្ណៈឲ្យដល់យុវជន-យុវនារីយើង ធ្វើឲ្យយុវជន យុវនារីយើង មានគោលជំហរទ្រាំទ្រការលំបាកវេទនាសព្វបែបយ៉ាងបាន និងមានពិសោធន៍រស់នៅ ដោយឯករាជ្យម្ចាស់ការ ខ្លួនទីពឹងខ្លួន មិនជិះជាន់កម្លាំងពលកម្មគេ ហើយក៏មិនពឹងផ្អែក ឬដេករង់ចាំតែសុំទានជំនួយបរទេសឡើយ ។ ដូច្នោះ វាពង្រឹងគោលជំហរបដិវត្តន៍ឲ្យដល់យុវជន យុវនារីយើងជាលំដាប់ ។

ដូច្នេះ យុវជន យុវនារីកម្ពុជា ដែលស្នេហាជាតិ ដែលចង់ឲ្យប្រទេសជាតិខ្លួន សម្បូរសប្បាយថ្កុំថ្កើងរុងរឿង ក្នុងឯករាជភាព អធិបតេយ្យភាពពេញទីនោះ ចាំបាច់ត្រូវប្តេជ្ញាចុះប្រឡូកធ្វើពលកម្មបង្កបង្កើនផល ជាមួយប្រជាជនកម្ពុជាទាំងមូល ដើម្បីលត់ដំ ហ្វឹកហ្វឺនកសាងខ្លួនផង ពង្រឹងនូវគោលជំហរបដិវត្តន៍របស់ខ្លួនផង និងរួមចំណែកការពារប្រទេស និងកសាងប្រទេសយ៉ាងសកម្មស័ក្តិសិទ្ធបំផុតផង ។ កន្លងមក មិត្តយុវជន យុវនារីយើង ធ្លាប់បានរួមចំណែកយ៉ាងសកម្មក្នុងសង្គ្រាមបដិវត្តន៍ វាយកម្ទេចសង្គ្រាមឈ្លានពានដ៏មហាឃោរឃៅ ហ្វាស៊ីសអស្ចារ្យរបស់ចក្រពត្តិអាមេរិក និងបរិវារ ដណ្តើមបានមហាជោគជ័យទាំងស្រុង និងជាស្ថាពរ ។ ដូច្នេះ ក្នុងសម័យសន្តិភាពឥឡូវនេះក៏មិត្តយុវជនយុវនារីយើង ប្រាកដជា និងចុះប្រឡូកបង្កបង្កើនផល ការពារប្រទេស និងកសាងប្រទេសប្រកបដោយជោគជ័យទាំងស្រុងទៀតពុំខានឡើយ ឲ្យតែមិត្តយុវជន យុវនារីយើងជម្រះឲ្យអស់នូវទស្សនៈគោលជំហរខុសឆ្គងដែលនៅមានសេសសល់ក្នុងខ្លួននៅឡើយ ។ ការបង្កបង្កើនផលក្នុងពេលសន្តិភាពយ៉ាងណា ក៏មិនលំបាកដូចធ្វើសង្គ្រាមវាយចក្រពត្តិអាមេរិក និងបរិវារដែរ ។ ប្រទេសជាតិ ប្រជាជន និងបក្សកុម្មុយនីស្តកម្ពុជា ដាក់ក្តីសង្ឃឹមទាំងស្រុងទៅលើមិត្តហើយ ហើយជឿជាក់ថា មិត្តយុវជន យុវនារីយើង និងចុះប្រឡូកធ្វើពលកម្មបង្កបង្កើនផល រួមចំណែកការពារប្រទេស និងកសាងប្រទេសជាតិ យ៉ាងស្វាហាប់សស្រាក់សស្រាំ នៅគ្រប់ទិសទីពុំខានឡើយ ។ **ឆេង ឌេង**

# មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង ៖
# រឿងរ៉ាវប្រវត្តិសាស្ត្រចេញពីតំបន់អន្លង់វែង



មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង ផ្តើមដំណើរឆ្ពោះទៅរកការកសាងសន្តិភាព ការបង្រួបបង្រួម និងការផ្សះផ្សា នៅក្នុងតំបន់តស៊ូចុងក្រោយរបស់ខ្មែរក្រហមនៅអន្លង់វែង ។

◆ មជ្ឈមណ្ឌលឯកសារកម្ពុជា សហការជាមួយក្រសួងទេសចរណ៍

◆ រូបថតឆ្នាំ២០១៦ ៖ អតីតទីបញ្ជាការរបស់ តាម៉ុក នៅលើភ្នំដងរែក

◆ ព័ត៌មានបន្ថែមសូមទំនាក់ទំនងបណ្ឌិត លី សុខឃាង នាយកមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង តាមរយៈទូរសព្ទលេខ ០២៣ ២១១ ៨៧៥ ឬ ០១២ ៥៧០ ៤៦៥ និងសារអេឡិចត្រូនិច truthlysokkheang@dccam.org

# ស្លាកសញ្ញាបង្ហាញពី ទីតាំងប្រវត្តិសាស្ត្រត្រូវបានដាក់ដំឡើង

*រយៈពេលជិតមួយឆ្នាំចាប់តាំងពីដំណើរការគម្រោងរបស់ខ្លួន មជ្ឈមណ្ឌលសន្តិភាពអន្លង់វែងដែលស្ថាបនាឡើងដោយមជ្ឈមណ្ឌលឯកសារកម្ពុជា សហការជាមួយក្រសួងទេសចរណ៍ និងអាជ្ញាធរដែនដី ដែលធ្វើការងារផ្ដោតសំខាន់ទៅលើសន្តិភាព ការចងចាំ និងការផ្សះផ្សា បានដឹកនាំសិស្ស-និស្សិត ចំនួនជាង១៨០នាក់ មកពីសាកលវិទ្យាល័យនានា នៅទូទាំង ប្រទេសកម្ពុជា ថៃ អូស្ត្រាលី អាមេរិក ដែលមានចំណាប់អារម្មណ៍ទាក់ទងនឹងប្រវត្តិសាស្ត្រខ្មែរក្រហម ឲ្យមកទស្សនកិច្ចសិក្សានៅតំបន់អន្លង់វែង ។ ក្រុមការងារបាននាំសិស្ស-និស្សិត ចុះទៅមើលទីតាំងប្រវត្តិសាស្ត្រ ជួបសម្ភាសជាមួយអតីតខ្មែរក្រហមនៅស្រុកអន្លង់វែងផ្ទាល់ ក្នុងគោលបំណងឲ្យសិស្ស-និស្សិតទាំងនេះ ស្វែងយល់ពីការតស៊ូ ជីវភាពរស់នៅ និងផ្នត់គំនិតរបស់អតីតខ្មែរក្រហមទាំងនេះ បន្ទាប់ពីបានធ្វើសមាហរណកម្មចុះចូលជាមួយរាជរដ្ឋាភិបាលតាំងពីឆ្នាំ១៩៩៩មក ។ មជ្ឈមណ្ឌលសន្តិភាពអន្លង់វែងក៏បានផ្ដល់ឱកាស និងលើកទឹកចិត្តឲ្យសិស្ស-និស្សិត សរសេរអត្ថបទ ដោយលើកឡើងពីគំនិតយោបល់ផ្ទាល់ខ្លួនទាក់ទងនឹងដំណើរការសន្តិភាព ការផ្សះផ្សា នៅក្នុងតំបន់នៅថ្ងៃខាងមុខ និងចែករំលែកពីបទពិសោធរបស់ខ្លួនជាមួយមិត្តភក្តិរួមថ្នាក់ និងអ្នកដែលខ្លួនស្គាល់ដែរ ។*












ក្រៅពីកិច្ចការទាំងនេះ មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង បាន និងកំពុងបន្តកិច្ចការងារកែលម្អ និង ថែរក្សាតំបន់ប្រវត្តិសាស្ត្រអន្លង់វែងដែលនៅសេសសល់ទាំង១៤កន្លែង រួមមាន ៖ ១) ផ្លូវរបស់ ប៉ុល ពត ២) កន្លែងកាត់ទោស ប៉ុល ពត, ៣) ផ្ទះកណ្តាលរបស់ តាម៉ុក, ៤) ភ្នំ២០០ ៥) ផ្ទះ ប៉ុល ពត និង ខៀវ សំផន ៦) ឃ្លាំងនៅជើងភ្នំ ៧) ផ្លូវរបស់ សុន សេន ៨) វាលស្រែគំរូ ៩) ទីតាំងការដ្ឋានដឹកជញ្ជូនរបស់ តាម៉ុក, ១០) បឹងអន្លង់វែង ១១) ផ្ទះនិងសារមន្ទីររបស់ តាម៉ុក ១២) អតីតមន្ទីរពេទ្យរបស់ តាម៉ុក ១៣) សាលារៀនរបស់ តាម៉ុក និង ១៤) ស្ពានអូរដឹក ឬស្ពាន តាម៉ុក ដែលមានចែងនៅក្នុងអនុក្រឹតរបស់ក្រសួងទេសចរណ៍ដាក់ទីតាំងទាំងនេះ ជាទីតាំងប្រវត្តិសាស្ត្រដែលត្រូវថែរក្សា និងការពារ ។

កន្លងមក ក្រុមការងាររបស់មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង បានរៀបចំការដាក់តាំងដាក់តាំងពិព័រណ៍រូបថត ព្រឹត្តិការណ៍ និង កាលប្បវត្តិសំខាន់ៗ នៅក្នុងរបបខ្មែរក្រហម នៅផ្ទះ ឬសារមន្ទីររបស់ តាម៉ុក ស្ថិតនៅក្នុងបឹងអន្លង់វែង និងនៅការិយាល័យមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង (អតីតទីបញ្ជាការរបស់ តាម៉ុក) សម្រាប់ប្រជាជននៅក្នុងសហគមន៍ និងភ្ញៀវដែលចូលមកតំបន់នេះទស្សនា ក្នុងគោលបំណងជំរុញឲ្យមានការយល់ដឹងកាន់តែស៊ីជម្រៅពីប្រវត្តិនៅក្នុងសហគមន៍នេះទាំងមូល ។

មកដល់បច្ចុប្បន្ន ដើម្បីជួយសម្រួលក្នុងការផ្តល់ព័ត៌មានពីទីតាំងប្រវត្តិសាស្ត្រសំខាន់ៗក្នុងស្រុកអន្លង់វែងនេះ ដល់អ្នកចម្ងាយ និងភ្ញៀវទេសចរណ៍ មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង សហការជាមួយក្រសួងទេសចរណ៍ និងអាជ្ញាធរដែនដី បានរៀបចំដំឡើងស្លាកសញ្ញាបង្ហាញពីទីតាំងប្រវត្តិសាស្ត្រនៅក្នុងតំបន់នេះថែមទៀត ។

បណ្ឌិត លី សុខឃាង នាយកមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង ដែលទទួលបន្ទុកការងារដំឡើងស្លាកសញ្ញាទាំងនេះបានឲ្យដឹងថា "ស្លាកសញ្ញាបង្ហាញទីតាំងនេះ នឹងបង្កភាពងាយស្រួលដល់អ្នកដែលមិនធ្លាប់រស់នៅ និងមកដល់តំបន់អន្លង់វែងពីមុនមកឲ្យស្គាល់ពីប្រវត្តិតំបន់នេះ និងនាំអ្នកទាំងនេះ ទៅដល់គោលដៅតែម្តង ដោយមិនចាំបាច់ចំណាយពេលសាកសួរព័ត៌មាន ។ ប៉ុន្តែបើយើងមិនមានស្លាកសម្គាល់នេះទេ ក៏អាចជាការលំបាកមួយផ្នែកដែរ ព្រោះភ្ញៀវដែលមកដល់តំបន់នេះហើយ មិនដឹងត្រូវទៅមើលកន្លែងណាទៀតដែលជាការខាតបង់នូវការយល់ដឹងពីប្រវត្តិសាស្ត្រ នៅក្នុងសហគមន៍នេះ" ។

ជាមួយគ្នានេះ រឿន អាយុ៣៧ឆ្នាំ ប្រជាជនរស់នៅភូមិដាំ ឃុំត្រពាំងពាងប្រិយ៍ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ បានសម្តែងការត្រេកអរ និងថ្លែងអំណរគុណដល់អាជ្ញាធរដែនដី ក្រសួងទេសចរណ៍ និងមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង ដែលបានដំឡើងស្លាកសញ្ញាសម្គាល់ទីតាំងនេះ ។

រឿន បានឲ្យដឹងថា ស្លាកសញ្ញាទាំងនេះនឹងជាប្រយោជន៍ទាក់ទាញភ្ញៀវទេសចរណ៍ឲ្យដឹងពីតំបន់ប្រវត្តិសាស្ត្រ ដូចជា ភ្នំ២០០ ឃ្លាំងគ្រាប់ និងជាកន្លែងកែច្នៃគ្រាប់របស់ខ្មែរក្រហម ។ គាត់សង្ឃឹមថា ស្លាកសញ្ញានេះនឹងអាចបង្កើនចំណូលដល់គាត់ តាមរយៈភ្ញៀវចូលមកតំបន់របស់គាត់ មិនត្រឹមតែប៉ុណ្ណោះ គាត់ក៏អាចនិយាយពីទីតាំងនៅលើស្លាកសញ្ញានេះប្រាប់ដល់កូនចៅរបស់គាត់ដែលកំពុងរៀននៅថ្នាក់បឋមសិក្សាថែមទៀត ។ ជាចុងក្រោយ គាត់មានប្រសាសន៍ នឹងជួយថែរក្សាស្លាកសញ្ញាឲ្យនៅគង់វង្ស ។

ចំណែកយាយ សូត អាយុ៨៤ឆ្នាំ រស់នៅស្រុកអន្លង់វែងនេះដែរ មានប្រសាសន៍ថា មានភ្ញៀវទេសចរណ៍ជាច្រើនបានសួរនាំគាត់ពីទីតាំងប្រវត្តិសាស្ត្រក្នុងតំបន់អន្លង់វែង ដូច្នេះនៅពេលមានស្លាកសញ្ញាសម្គាល់នេះ នឹងកាន់តែបង្កភាពងាយដល់ភ្ញៀវដើម្បីរកទីតាំង ហើយគាត់ក៏អាចនិយាយពីរឿងរ៉ាវទាក់ទងនឹងទីតាំងទាំងនេះប្រាប់ដល់ភ្ញៀវផងដែរ ។

ការដំឡើងស្លាកសញ្ញានេះ មិនត្រឹមតែបង្ហាញទីតាំង និងទាញចំណាប់អារម្មណ៍ប្រជាជនឲ្យផ្តោតលើប្រវត្តិសាស្ត្រក្នុងសហគមន៍អន្លង់វែងប៉ុណ្ណោះទេ ប៉ុន្តែក៏ជួយថែរក្សាប្រវត្តិសាស្ត្រ នៅក្នុងតំបន់អន្លង់វែង ទាំងមូលឲ្យនៅគង់វង្ស និងរស់រវើក ។ នៅពេលដែលអ្នកមកទស្សនាតំបន់នេះ មើលឃើញអក្សរដែលសរសេរលើស្លាកសញ្ញាសម្គាល់ទាំងនេះ អ្នកទាំងនោះប្រាកដជានឹកឃើញពីរឿងរ៉ាវក្នុងរបបខ្មែរក្រហម ជម្លោះនៅក្នុងតំបន់អន្លង់វែង និងការផ្តាច់ខ្លួនរបស់អតីតកម្លាំងខ្មែរក្រហមចុះចូលជាមួយរាជរដ្ឋាភិបាលដែលនាំមកនូវសន្តិភាពមកដល់សព្វថ្ងៃមិនខាន ។

**សោម ប៊ុនថន**

# អតីតកាលផ្សារភ្ជាប់ជាមួយអ្នកជំនាន់ក្រោយ



អន្លង់វែង គឺជាមូលដ្ឋានរឹងមាំចុងក្រោយរបស់ខ្មែរក្រហម ។ មកដល់បច្ចុប្បន្ននេះមនុស្សមួយចំនួន ជាពិសេសអ្នកដែលធ្លាប់ឆ្លងកាត់ពីរបបខ្មែរក្រហម តែងតែមានការខ្លាចរអាពេលដែលឮពាក្យថាអន្លង់វែង ព្រោះអ្នកទាំងនោះគិតថា តំបន់នេះជាតំបន់របស់ខ្មែរក្រហមជាច្រើនរស់នៅ ។ អ្នកទាំងនោះ នៅតែមានអារម្មណ៍ភ័យខ្លាច ហើយអ្នកខ្លះនៅតែមិនហ៊ានមកអន្លង់វែងនៅឡើយ ។

ម៉ៅ គឹមសួរ អាយុ២០ ជាគរុសិស្សឆ្នាំទី២ នៃវិទ្យាស្ថានជាតិអប់រំ ផ្នែកភាសាបារាំង-ខ្មែរ ពេលដែលឮពាក្យ អន្លង់វែង គឹមសួរ នឹកឃើញដល់ខ្មែរក្រហម ។ ទោះបីជា គឹមសួរ ជាក្មេងដែលកើតក្រោយរបបខ្មែរក្រហម តែ គឹមសួរ បានដឹងពីរបបមួយនេះ តាមរយៈឪពុកម្តាយ ចាស់ទុំបានប្រាប់ ។ ក្នុងនាមជាគរុសិស្ស គឹមសួរ មានការចាប់អារម្មណ៍ខ្លាំងលើប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ។ ហេតុនេះ គឹមសួរ បានចុះឈ្មោះចូលរួមក្នុងដំណើរទស្សនកិច្ចសិក្សារបស់មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង ។

គឹមសួរ ទៅដល់អន្លង់វែងដំបូង គឺមិនដូចអ្វីដែលខ្លួនធ្លាប់គិតនោះទេ អន្លង់វែងមិនមែនជាតំបន់ដែលគួរឲ្យភ័យខ្លាចដូចពីមុនទេ ។ អន្លង់វែងពេលនេះ មិនស្ងាត់ដូចមុនទេ គឺអ៊ូអរ មានផ្សារលក់ដូរទំនិញគ្រប់ប្រភេទ ជាពិសេសមានអ្នកចំណូលថ្មីមករស់នៅ និងរកស៊ីយ៉ាងច្រើន ។ អ្វីៗមិនដូចជាការដែល គឹមសួរ ធ្លាប់គិតមុននឹងមកដល់អន្លង់វែងទេ មិនថាអតីតខ្មែរក្រហម ឬអ្នកចំណូលថ្មី អ្នកទាំងអស់គ្នារស់នៅជាមួយគ្នាដោយភាតរភាព ។

នៅក្នុងដំណើរទស្សនកិច្ចសិក្សានេះ គឹមសួរ បានទទួលនូវបទពិសោធន៍ និងទស្សនាតំបន់ប្រវត្តិសាស្ត្រជាច្រើននៅក្នុងតំបន់អន្លង់វែង ។ គឹមសួរ មានឱកាសបានជួបសម្ភាសជាមួយអតីតខ្មែរក្រហម និងសាកសួរអ្នកទាំងនោះពីដំណើរជីវិតរបស់គាត់ចាប់តាំងពីមុនរបបខ្មែរក្រហមរហូតដល់បច្ចុប្បន្ន ។

គឹមសួរ យល់ថា ពិតជាអស្ចារ្យណាស់ដែលបានជួបសម្ភាសផ្ទាល់ជាមួយអតីតខ្មែរក្រហម និងសាកសួរនូវអ្វីដែលខ្លួនមានចម្ងល់ជាយូរមកហើយ ដែលទាក់ទងនឹងប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ។ សម្រាប់ គឹមសួរ ផ្ទាល់ ការចុះមកជួបសំណេះសំណាលជាមួយប្រជាជនដែលជាអតីតខ្មែរក្រហមពិតជាសំខាន់ និងជាវិធីល្អមួយ ព្រោះទង្វើនេះជួយកាត់បន្ថយគម្លាតរវាងក្មេងជំនាន់ក្រោយនិងអ្នកជំនាន់មុនដែលជាអតីតខ្មែរក្រហមដូចគាត់ទាំងអស់គ្នា ។ ទាំងនេះ ក៏បង្ហាញឲ្យឃើញថា អ្នកជំនាន់ក្រោយ មិនមានការរើសអើងចំពោះអតីតខ្មែរក្រហមទាំងនោះដែរ ហើយវាក៏បង្ហាញពីការសាមគ្គីគ្នា ដើម្បីចៀសវាងជម្លោះផ្ទៃក្នុងរវាងខ្មែរ និងខ្មែរ ដូចអតីតកាលទៀត ។

ចំពោះ គឹមសួរ ការសិក្សាស្វែងយល់ ការចែករំលែកបទពិសោធ ការនិយាយ ឬស្តាប់ពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យក៏ដូចជាតំបន់អន្លង់វែង ដែលជាសកម្មភាពមួយក្នុងដំណើរទស្សនកិច្ចសិក្សារបស់មជ្ឈមណ្ឌលសន្តិភាពអន្លង់វែងនាពេលនេះ គឺជាផ្នែកមួយក្នុងការបង្កើនការផ្សារភ្ជាប់រវាងក្មេងជំនាន់ក្រោយជាមួយនឹងបទពិសោធអតីតកាលរបស់អ្នកជំនាន់មុន និងដើម្បីធ្វើឲ្យប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យកាន់តែមានការយល់ដឹងទូលំទូលាយពីសំណាក់អ្នកជំនាន់ក្រោយ ។

**ឆាយ សារះមុនិន្ទ**

# សំ ចាន់ និងការរត់គេចខ្លួនដើម្បីរស់

ជាជនរងគ្រោះម្នាក់ពីរបបខ្មែរក្រហម សំ ចាន់ បានជួបប្រទះនូវរឿងរ៉ាវឈឺចាប់ជាច្រើន ដែលគាត់មិនអាចបំភ្លេចបាន ទោះបីជាកន្លងហួសទៅជាង៣០ឆ្នាំមកហើយក្ដី ។ ចាន់ កើតក្នុងឆ្នាំ១៩៥០ នៅភូមិព្រៃទំពូង ឃុំពើក ស្រុកអង្គស្នួល ខេត្តកណ្ដាល ។ គាត់ជាកូនប្រុសពៅ ក្នុងចំណោមបងប្អូនប្រុសស្រីបួននាក់ ។

នៅឆ្នាំ១៩៧២ ចាន់ បានរៀបការជាមួយនឹងនារីម្នាក់ឈ្មោះ នាង ស៊ីម ។ បន្ទាប់ពីជ័យជម្នះទូទាំងប្រទេសរបស់ខ្មែរក្រហម នៅថ្ងៃទី១៧ មេសា ១៩៧៥ គ្រួសាររបស់ ចាន់ ត្រូវខ្មែរក្រហមជម្លៀសដោយបង្ខំចេញពីផ្ទះ ។ អំឡុងពេលធ្វើដំណើរតាមផ្លូវ យោធាខ្មែរក្រហមបានចាប់ខ្លួន ចាន់ ជាមួយនឹងមនុស្សដទៃទៀត ដោយសង្ស័យថា ជាទាហាន លន់ នល់ យកទៅដាក់នៅវត្តរបងភ្លៀច


សំ ចាន់ ថតនៅអន្លង់វែង

ស្ថិតក្នុងស្រុកគងពិសី ខេត្តកំពង់ស្ពឺ ។ ប៉ុន្តែ ចាន់ បានលួចរត់រួច និងបានបែកឆ្ងាយពីគ្រួសារចាប់តាំងពីពេលនោះមក ។

ចាន់ គេចខ្លួន និងធ្វើដំណើរជាមួយអ្នកជម្លៀសឯទៀត ទៅដល់ស្រុកព្រៃកប្បាស ខេត្តតាកែវ ។ នៅទីនោះ អង្គការបានចាត់តាំងគាត់ឲ្យចូលកងវែកដី ដែលត្រូវធ្វើការជាច្រើនម៉ោងក្នុងមួយថ្ងៃ ហើយរបបអាហារដែលទទួលបានគឺមិនគ្រប់គ្រាន់នោះទេ ។ នៅឆ្នាំ១៩៧៦ អង្គការបានដក ចាន់ ពីកងវែកដី មកធ្វើនៅកងភ្ជួរវិញ ។ ការងារនៅកងភ្ជួរក៏លំបាកដូចជាកងវែកដីដែរ គឺគាត់ត្រូវក្រោកទៅភ្ជួរពីព្រលឹមរហូតដល់ម៉ោង១២ថ្ងៃត្រង់ទើបសម្រាកហូបបាយ ហើយពេលរសៀល ត្រូវភ្ជួរពីម៉ោង១ រហូតដល់ម៉ោង៨យប់ ។ កងភ្ជួររបស់ ចាន់ ដែលមានសមាជិក១០នាក់ គឺទទួលបានអង្ករតែមួយកំប៉ុងប៉ុណ្ណោះសម្រាប់ហូប ។

មានពេលមួយ ដោយស្រេកឃ្លានខ្លាំងពេក ចាន់ បានប្រថុយជីវិតលួចដំឡូងយកមកស្ងោរហូប ។ ជាអកុសល ពេលដែល ចាន់ កំពុងស្ងោរដំឡូង កងឈ្លបបានមកទាន់ និងបានចាប់ខ្លួនគាត់ ។ ឈ្លបបានបណ្ដើរ ចាន់ ទៅក្នុងព្រៃឆ្ងាយពីភូមិ ហើយឲ្យគាត់ជីករណ្ដៅជម្រៅមួយម៉ែត្រកន្លះ ដើម្បីកប់ខ្លួនឯង ។ ពេលនោះ ចាន់ បានលុតជង្គង់អង្វរឈ្លបទាំងនោះ សូមទុកជីវិតឲ្យគាត់ផង ។ ដោយសារតែពាក្យអង្វរក និងសេចក្ដីអាណិតអាសូរចំពោះ ចាន់ កងឈ្លបបានដោះលែងគាត់ ហើយប្រាប់ឲ្យ ចាន់ ចាកចេញទៅរស់នៅតំបន់ផ្សេងវិញ ។ ចាន់ បានរត់ទៅធ្វើនៅកងចល័តឃុំ នៅតំបន់៣៣ ។ អំឡុងពេលនោះ ខ្មែរក្រហមបានហៅប្រុសៗនៅកងចល័តដើម្បីធ្វើប្រវត្តិរូប ។ ចាន់ ត្រូវបានខ្មែរក្រហមសួរថា តើមិត្តធ្វើអ្វីពីមុនមក? ធ្វើជាទាហាន លន់ នល់ ឬ? ចាន់ បានឆ្លើយថា គាត់ជាអ្នកធាក់ស៊ីក្លូ ។

ឆ្នាំ១៩៧៨ អង្គការបានផ្លាស់ ចាន់ ពីកងចល័តឃុំ មកធ្វើនៅកងដំណាំវិញ ។ ចាន់ មាននាទីរែកទឹកស្រោចដំណាំ ក្នុងមួយថ្ងៃឲ្យបាន២០០អំរែក ។ នៅឆ្នាំដដែល អង្គការបានរៀបការឲ្យយុវជន

ហើយក្នុងចំណោមយុវជនទាំងនោះ ក៏មាន ចាន់ ម្នាក់ដែរ ។ ចាន់ រម្លឹកថា ពេលនោះ អង្គការរៀបចំការចំនួន៣០គូ ។ ពេលថ្ងៃរៀបការមកដល់ ចាន់ បានឃើញតែយុវជនចំនួន៣០ នាក់មកប៉ុណ្ណោះ ចំណែកយុវនារីឃុំ៣០ នាក់ទៀត គឺមិនឃើញមានវត្តមានទេ ។ ដូច្នេះ អង្គការក៏ចាត់ឲ្យយកយុវនារីនៅតំបន់ផ្សេងមករៀបការជំនួសទៅវិញ ។ ចាន់ បានរៀបការជាមួយមិត្តនារីឈ្មោះ សុខា និងបានកូនស្រីម្នាក់ ។ ជាអកុសល កូនស្រីរបស់ ចាន់ ដែលមានវ័យ១ឆ្នាំហើយនោះ បានស្លាប់ដោយសារជំងឺ និងគ្មានថ្នាំព្យាបាល ។

នៅឆ្នាំ១៩៧៩ កងទ័ពវៀតណាម និងកងទ័ពរណសិរ្សរំដោះជាតិកម្ពុជា បានសម្រុកផ្តួលរំលំរបបខ្មែរក្រហម ។ ពេលនោះ ចាន់ ក៏ដូចជាប្រជាជនដទៃទៀត បានរត់ភៀសខ្លួនទៅជាមួយខ្មែរក្រហម តែនៅតាមផ្លូវគាត់ត្រូវកងទ័ពវៀតណាមចាប់ខ្លួនបាន ។ គាត់ក៏បែកពីប្រពន្ធទីពីររបស់គាត់នាពេលនោះ ។ កងទ័ពវៀតណាម មិនបានធ្វើទុកបុកម្នេញគាត់ទេ ព្រោះគាត់ជាប្រជាជនធម្មតា តែវៀតណាមបានចាត់តាំងគាត់ និងប្រុសៗទាំងអស់ទៅជួយសែងអ្នករបួស និងសាកសពនៅសមរភូមិ ។ បន្ទាប់ពីសង្គ្រាមរវាងកងទ័ពរំដោះ និងខ្មែរក្រហមបានបញ្ចប់ ចាន់ ក៏ត្រូវបានអនុញ្ញាតឲ្យត្រឡប់មករកក្រុមគ្រួសារនៅស្រុកកំណើតវិញ ។ ជាភ័ព្វសំណាង ចាន់ បានធ្វើដំណើរមកដល់ពោធិ៍ចិនតុង ក៏បានជួបនឹងគ្រួសារគាត់ ហើយក៏នាំគ្នាមករស់នៅស្រុកកំណើតនៅស្រុកអង្គស្នួលវិញ ។

នៅឆ្នាំ១៩៨១ ចាន់ ក៏ផ្លាស់មករស់នៅ និងរកស៊ីនៅឃុំលំហាច ស្រុកអង្គស្នួល ខេត្តកណ្តាលដដែល ហើយក៏បានរៀបការប្រពន្ធក្រោយ និងមានកូនប្រុសស្រី៧នាក់ ។ ឆ្នាំ២០០០ ចាន់ និងគ្រួសារបានផ្លាស់មករស់នៅស្រុកអន្លង់វែងរហូតដល់សព្វថ្ងៃ ។ ចាន់ រម្លឹកថា មកដល់អន្លង់វែងដំបូងគឺមិនសូវមានអ្នកមករស់នៅច្រើនទេ គឺមានសភាពស្ងប់ស្ងាត់ មិនអ៊ូអរដូចបច្ចុប្បន្នទេ ។

ទោះបីជារបបខ្មែរក្រហមកន្លងផុតទៅជាច្រើនឆ្នាំក៏ដោយ តែសម្រាប់ ចាន់ របបមួយនេះនៅតែដិតដាមក្នុងចិត្តគាត់ជានិច្ចជាពិសេស គឺមរណភាពរបស់កូនស្រីគាត់ ។

**ចាន់ ស្រីពៅ**



ទីរួមស្រុកអន្លង់វែងពេលបច្ចុប្បន្ន

# ជីវិតជាកងដឹកជញ្ជូនរបស់ សំ នឿន

អន្លង់វែង គឺជាមូលដ្ឋានតស៊ូរឹងមាំចុងក្រោយរបស់ខ្មែរក្រហម បន្ទាប់ពីរបបនេះ បានដួលរលំនៅថ្ងៃទី៧ ខែមករា ឆ្នាំ ១៩៧៩ ។ ខ្មែរក្រហមនៅតំបន់អន្លង់វែង បានធ្វើការតស៊ូប្រយុទ្ធជាមួយរដ្ឋាភិបាលរហូតដល់ឆ្នាំ១៩៩៨ ទើបធ្វើសមាហរណកម្មចុះចូលជាមួយរដ្ឋាភិបាល ហើយតំបន់នេះ ក៏មានសុខសន្តិភាពចាប់ពីពេលនោះមក ។ ជាអ្នកដែលមានស្រុកកំណើតនៅ ខេត្តសៀមរាប សំ នឿន ក៏ជាជនរងគ្រោះម្នាក់ក្នុងរបបខ្មែរក្រហមដែរ បើទោះបីគាត់ជាអតីតកងដឹកជញ្ជូនរបស់ខ្មែរក្រហមក៏ដោយ ។ នឿន បានបាត់បង់បងប្រុសម្នាក់ ក្នុងចំណោមបងប្អូនរបស់គាត់បួននាក់ និងញាតិមិត្តមួយចំនួនទៀត ។ ក្នុងជីវិតរបស់ នឿន ជាកងដឹកជញ្ជូន


ជា សុវត្ថិ និស្សិតឆ្នាំទី៣ ផ្នែកប្រវត្តិវិទ្យា នៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ មកធ្វើទស្សនកិច្ចសិក្សានៅស្រុកអន្លង់វែង

គាត់បានឆ្លងកាត់ការលំបាកជាច្រើន ដែលរឿងរ៉ាវទាំងនេះ ហាក់បីជាដូចនៅថ្មីៗ សម្រាប់គាត់ ទោះបីជាវាកន្លងផុតទៅជាច្រើនឆ្នាំមកហើយ ។

នឿន ជាក្មេងម្នាក់ មិនបានរៀនសូត្រខ្ពង់ខ្ពស់នោះទេ ។ នៅឆ្នាំ១៩៧៣ នឿន បានបង្ខំចិត្តចូលរួមធ្វើបដិវត្តន៍តាមការឃោសនារបស់ខ្មែរក្រហម ។ ប្រសិនបើគាត់មិនព្រមចូលធ្វើ បដិវត្តន៍ទេ ខ្មែរក្រហមនឹងមិនឲ្យគាត់ និងគ្រួសាររស់នៅបានសុខឡើយ ។ ហេតុនេះ ដើម្បីសុវត្ថិភាពរបស់គ្រួសារ នឿន ត្រូវចូលរួមតស៊ូជាមួយខ្មែរក្រហម ។

ស្ថិតក្នុងវ័យ១៧ឆ្នាំ នឿន ត្រូវបានអង្គការខ្មែរក្រហមចាត់តាំងឲ្យធ្វើកងដឹកជញ្ជូនស្បៀងសម្រាប់ទ័ពនៅសមរភូមិមុខ ។ រាល់ពេល នឿន និងសមាជិកក្រុម២០នាក់ទៀត ត្រូវស្ពាយស្បៀងធ្វើដំណើរដោយថ្មើរជើងយកទៅផ្តល់ឲ្យកងទ័ពដែលកំពុងច្បាំងនៅសមរភូមិ ។ ទោះបីជាគាត់ធ្វើការនៅកងដឹកជញ្ជូនស្បៀង ក៏គាត់មិនទទួលបានរបបហូបចុកគ្រប់គ្រាន់ដែរ ។ នៅឆ្នាំ១៩៧៥ បន្ទាប់ពីខ្មែរក្រហមទទួលជ័យជម្នះទូទាំងប្រទេស នឿន មិនត្រូវបានអនុញ្ញាតត្រឡប់មកជួបជុំគ្រួសារវិញទេ ។ មិនខុសពីគ្រួសារដទៃទៀតដែរ គ្រួសាររបស់ នឿន ត្រូវខ្មែរក្រហមជម្លៀសចេញពីភូមិកំណើតឲ្យទៅរស់នៅ និងធ្វើការនៅកន្លែងដាច់ស្រយាល ។ គ្រួសាររបស់គាត់ត្រូវអង្គការជម្លៀសជាច្រើនលើក ដែលដំបូងជម្លៀសចេញពីភូមិកំណើតនៅខេត្តសៀមរាបទៅប៉ៃលិន រួចបន្តទៅខេត្តបាត់ដំបង និងព្រះវិហារ ។

នៅថ្ងៃមួយ បងប្រុសរបស់ នឿន ត្រូវកងឈ្លបមកនាំខ្លួនយកទៅដោយចោទថា ខ្ជិលយកការណ៍ ព្រោះខស្សរាប់ឃើញបងប្រុសរបស់គាត់ ដើរហើរសេរីគ្រប់ទីកន្លែង ។ ក្រោយមក មិនមានសមាជិកគ្រួសារណាម្នាក់ បានដឹងពីដោគវាសនារបស់បងប្រុសគាត់ទៅ ជាយ៉ាងណាទេ គឺបាត់ដំណឹងរហូត ។

បន្ទាប់ពីរបបខ្មែរក្រហមបានដួលរលំ នៅឆ្នាំ១៩៧៩ នឿន

នៅតែរស់នៅ និងបន្តការងាររបស់ខ្លួនជាមួយចលនាតស៊ូរបស់ខ្មែរក្រហមដែលនៅសេសសល់ដដែល ។ នឿន ត្រូវថ្នាក់លើចាត់តាំងឲ្យធ្វើនៅកងដឹកជញ្ជូនសព្វាវុធទៅសមរភូមិ ។ នឿន ត្រូវចំណាយពេលយ៉ាងតិច៥ថ្ងៃ ដើម្បីដឹកអាវុធគ្រាប់រំសេវ ទៅដល់សមរភូមិមុខ ។ គាត់បានឲ្យដឹងថា ផ្លូវធ្វើដំណើរ គឺមានគ្រោះថ្នាក់ណាស់ ។ គាត់ និងសមាជិកក្រុមត្រូវធ្វើដំណើរដោយប្រុងប្រយ័ត្ន ឬប្រើផ្លូវវាង ដើម្បីកុំឲ្យជួបទាហានរដ្ឋាភិបាល ឬកងទ័ពវៀតណាម ។

មកដល់ឆ្នាំ១៩៨៥ នឿន ត្រូវបានអង្គភាពរៀបចំគ្រួសារឲ្យ ។ ការរៀបការនេះ គឺមិនមានពិធីអ្វីធំដុំនោះទេ ហើយក៏គ្មានអាចារ្យ ឬឪពុកម្តាយទាំងសងខាងចូលរួមដែរ ដោយគ្រាន់តែចាប់ដៃឡើងប្តេជ្ញាប៉ុណ្ណោះ ។ នឿន និងប្រពន្ធក៏មិនដែលធ្លាប់ស្គាល់ ឬឃើញគ្នាពីមុនមកដែរ ។ នៅឆ្នាំ១៩៩០ នឿន និងប្រពន្ធបានផ្លាស់មកនៅអន្លង់វែង ដែលជាតំបន់ស្ថិតក្រោមការគ្រប់គ្រងរបស់តាម៉ុក ។ បន្ទាប់ពីសមាហរណកម្មជាមួយរដ្ឋាភិបាលឆ្នាំ១៩៩៨ មក តំបន់អន្លង់វែងបានប្រែពីតំបន់ដែលមានជម្លោះប្រដាប់អាវុធមកជាតំបន់ដែលពោរពេញដោយសន្តិភាព ។ ទន្ទឹមនឹងនោះ ក៏មានអ្នកចំណូលថ្មីជាច្រើន មករស់នៅ និងប្រកបអាជីវកម្មនៅតំបន់អន្លង់វែងនេះដែរ ។

នឿន បានឲ្យដឹងថា អន្លង់វែងលែងជាតំបន់ដែលរស់នៅដោយការភ័យខ្លាចហើយ ប្រជាជនក៏មិនចាំបាច់រត់គេចឡើងភ្នំទៀតឡើយ ។ ប្រជាជនម្នាក់ៗនៅពេលនេះ គឺរស់នៅដោយសុខសាន្ត និងមានសិទ្ធិប្រកបរបរ ឬធ្វើអ្វីដែលខ្លួនចង់ធ្វើបាន ។

ចំណែក នឿន បច្ចុប្បន្នមានដីពីរបីកន្លែងដែរ សម្រាប់ធ្វើចម្ការ ហើយក្រៅពីនេះ គាត់ប្រកបរបរជាជាងប៉ះកង់ម៉ូតូ ដែលជាមុខរបរបន្ទាប់បន្សំរបស់គាត់ ។

**ឋា សុខគ្គិ**



រូបកណ្តាល មាស ពៅ អាយុ៦១ឆ្នាំ ជាអតីតជាសមាជិកខ្មែរ រស់នៅឃុំអូរគគីកណ្តាល ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ បានរៀបរាប់ពីបទពិសោធន៍ឆ្លងកាត់សម័យសង្គ្រាម ប្រាប់ដល់សិស្សនិស្សិតដែលចុះមកធ្វើទស្សនកិច្ចសិក្សានៅតំបន់ប្រវត្តិសាស្ត្រអន្លង់វែង

# ការតស៊ូដើម្បីរស់

នៅក្នុងរបបខ្មែរក្រហម ម៉ៅ បូ ជាស្ត្រីម្នាក់ក្នុងចំណោមស្ត្រីជាម្តាយដទៃទៀត ដែលបានតស៊ូគ្រប់ការលំបាកសព្វបែបយ៉ាងដើម្បីការពារ និងបីបាច់ថែរក្សាកូននៅពេលមិនមានប្តីនៅក្បែរ ។ ទោះបីជា រៀបការជាប្តីប្រពន្ធហើយក៏ដោយ ក៏ ម៉ៅ បូ មិនបានរស់នៅជួបជុំប្តី និងគ្រួសារដែរ រហូតដល់របបខ្មែរក្រហមបានដួលរលំ ។ កូនប្រុសម្នាក់របស់គាត់បានស្លាប់ដោយសារជំងឺគ្មានថ្នាំព្យាបាល ។

រម្លឹកពីអតីតកាល ម៉ៅ បូ បានឲ្យដឹងថា ប្តីគាត់បានចូលធ្វើជាកងទ័ពពិសេសតាំងពីឆ្នាំ១៩៧៣មកម្ល៉េះ ។ បន្ទាប់ពីរបប លន់ នល់ ដួលរលំនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ប្តីរបស់គាត់ក៏ជាសមាជិកម្នាក់របស់ខ្មែរក្រហមដែរ ក្នុងការជម្លៀសប្រជាជនដោយបង្ខំចេញពីទីក្រុងភ្នំពេញ ទៅកាន់តំបន់ផ្សេងៗ ។ ក្រោយពីជ័យជម្នះនេះ បូ និងប្តី មិនបានរស់នៅជួបជុំគ្នាទេ ព្រោះអង្គការបានផ្លាស់ប្តីរបស់គាត់ពីភ្នំពេញឲ្យទៅឈរជើងនៅខេត្តរតនគិរី ។ ពេលដែលប្តីរបស់គាត់ផ្លាស់ទៅរតនគិរី បូ កំពុងតែមានទម្ងន់កូនទីបី ហើយគាត់ និងកូនពីរនាក់ទៀត ត្រូវអង្គការចាត់ឲ្យទៅរស់នៅខេត្តកំពង់ស្ពឺ ។ សម្លឹងមកកាន់ខ្ញុំដោយភាពស្រងូតស្រងាត់ បូ បន្តថា ពេលទៅដល់កំពង់ស្ពឺមិនទាន់បានប៉ុន្មានខែផង គាត់ក៏បានសម្រាលកូនទីបី ។ ជីវិតរបស់គាត់នៅពេលនោះ ពិតជាលំបាក និងកំសត់ខ្លាំងណាស់ ព្រោះសម្រាលកូនគ្មានប្តីនៅក្បែរ ហើយត្រូវរ៉ាប់រងមើលថែចិញ្ចឹមកូនពីរនាក់ទៀតដោយគ្មានញាតិមិត្តបងប្អូននៅក្បែរ សូម្បីតែម្នាក់ ។

បូ បានឲ្យដឹងថា ទោះបីជាមានប្តីធ្វើជាយោធា តែគាត់នៅតែធ្វើការងារដូចប្រជាជនដទៃទៀតដែរ ។ បន្ទាប់ពីសម្រាលកូនអង្គការមិនបានអនុញ្ញាតឲ្យគាត់សម្រាកយូរឡើយ ។ ជារៀងរាល់ថ្ងៃ គាត់ត្រូវងើបពីព្រលឹមដញ្ជូនអាចម៍គោទៅដាក់ស្រែ រហូតដល់ថ្ងៃត្រង់ទើបសម្រាកហូបបបរ ។ នៅពេលរសៀល គាត់ត្រូវចាត់ឲ្យទៅមើលក្មេងៗ ហើយវាក៏ជាឱកាសដែលអាចឲ្យគាត់មើលថែកូនតូចៗរបស់គាត់ដែរ ។

នៅអំឡុងឆ្នាំ១៩៧៨ នៅតំបន់ដែល បូ រស់នៅ មានការខ្វះខាតស្បៀង និងមានជំងឺរាតត្បាតផង ហើយកូនប្រុសពៅរបស់គាត់បានស្លាប់ដោយសារជំងឺ ទាំងមិនបានឃើញ និងស្គាល់មុខឪពុកផង ។ នៅឆ្នាំ១៩៧៩ បន្ទាប់ពីរបបខ្មែរក្រហមដួលរលំ បូ បានព្យាយាមស៊ើបសួររកប្តីតាមរយៈកងទ័ពខ្មែរក្រហម ព្រោះគាត់ឮថាប្តីរបស់គាត់បានផ្លាស់ចេញពីរតនគិរីទៅកាន់ភ្នំ១០០១ តំបន់ភ្នំដងរែក ដើម្បីប្រមូលកម្លាំងឡើងវិញប្រឆាំងនឹងរដ្ឋាភិបាល និងកងទ័ពវៀតណាម ។

ពេលនោះ គាត់បានមករក និងបានជួបប្តីនៅអន្លង់វែងដែលជាតំបន់ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ តាម៉ុក ។ បូ និយាយមកកាន់ខ្ញុំដោយញញឹមថា នៅអន្លង់វែង ដោយសារតែប្តីគាត់ជាកងទ័ព ហេតុនេះ ជីវិតរស់នៅមិនលំបាកដូចមុននោះទេ ព្រោះ តាម៉ុក ជាអ្នកផ្គត់ផ្គង់ជីវភាពរស់នៅរបស់គ្រួសារគាត់ទាំងស្រុង ។ បូ និងប្តី បានកាប់ឆ្ការដីមួយកន្លែងដើម្បីសង់ផ្ទះ ហើយពេលនោះតំបន់អន្លង់វែងនេះ ជាព្រៃក្រាស់ និងងាយកើតជំងឺគ្រុនចាញ់ណាស់ ។

ជាញឹកញយ នៅអន្លង់វែង តែងតែមានការប្រយុទ្ធគ្នារវាងកងទ័ពខ្មែរក្រហម និងកងទ័ពរដ្ឋាភិបាល ។ ដោយសារមានការប៉ះទង្គិចគ្នាជាញឹកញាប់ បូ ក៏បង្ខំចិត្តនាំកូនទាំងពីររត់ទៅនៅជំរំក្នុងទឹកដីថៃ ដោយពេលនោះ ប្តីរបស់គាត់មិនបានទៅជាមួយទេ ព្រោះនៅប្រយុទ្ធការពារអន្លង់វែង ។ បូ បានរស់នៅក្នុងជំរំមួយឆ្នាំ ទើបត្រឡប់មកជួបជុំប្តីនៅអន្លង់វែងវិញ ។ គាត់បានឲ្យដឹងថា នៅអន្លង់វែងនេះ តាម៉ុក គឺជាមនុស្សម្នាក់គត់ដែលមានឥទ្ធិពល និងមានការគាំទ្រយ៉ាងខ្លាំងពីប្រជាជន ព្រោះ តាម៉ុក បានយកចិត្តទុកដាក់ និងជួយផ្គត់ផ្គង់ជីវភាពប្រជាជន ជាពិសេស បានសាងសង់ស្ពាន ធ្វើផ្លូវ លើកទំនប់ ស្តាប្រឡាយ សង់សាលារៀន មន្ទីរពេទ្យជាដើម ។

នៅឆ្នាំ១៩៩៨ បន្ទាប់ពី តាម៉ុក ត្រូវបានចាប់ខ្លួន និងការធ្វើសមាហរណកម្មចុះចូលជាមួយរដ្ឋាភិបាលរួចមក សន្តិភាពក៏ចាប់មានឡើង ។ នេះគឺជាអ្វីដែល បូ ប្រាថ្នាជាយូរមកហើយ ហើយ បូ និងគ្រួសារក៏ឈប់រស់នៅដោយភាពភ័យខ្លាចទៀតដែរ ។ **កែវ និមល**

# ជីវិតព្រាត់ប្រាស់ក្នុងអំឡុងពេលសង្គ្រាម

នៅលើគ្រែរនាបឈើ ស្ថិតនៅក្រោមផ្ទះឈើមួយខ្នងប្រក់ក្បឿងពណ៌ក្រហម ខ្ញុំឃើញអ៊ឹ ឃុន ឡាប កំពុងសម្រាក ។ គាត់មានអាយុ៥០ឆ្នាំ មានស្រុកកំណើតនៅភូមិកំពង់ក្ដី ឃុំជីក្រែង ស្រុកជីក្រែង ខេត្តសៀមរាប ។ ឡាប បានរៀបរាប់ថា ជាកូនកណ្ដាល នៅក្នុងគ្រួសារដែលមានបងប្អូន៣នាក់ (ស្រី២នាក់ ប្រុស១នាក់) ។ គាត់ធំដឹងក្ដីឡើងជាមួយជីដូន ដែលមានឈ្មោះ ថា វ៉ាន់ ជាអ្នកចិញ្ចឹមបីបាច់ថែរក្សា ។ គាត់មិនដែលស្គាល់មុខឪពុកម្ដាយទេ គាត់គ្រាន់តែឮដំណឹងថាគាត់មានឪពុកឈ្មោះ សាន ត្រូវអង្គការនាំយកទៅក្នុងអំឡុងឆ្នាំ១៩៧៧ ហើយបាត់ខ្លួនរហូត ។ អ្នកជិតខាងដែលធ្លាប់ស្គាល់ និងរស់នៅជិតគ្នាបានប្រាប់ថា ឪពុករបស់គាត់បានត្រូវខ្មែរក្រហមសម្លាប់បាត់ហើយ ។ ចំណែកម្ដាយគាត់ឈ្មោះ ហួន បានស្លាប់ដោយសារជំងឺ ។ ដោយស្ថិតនៅក្នុងវ័យក្មេងពេក ទើបគាត់ចងចាំបាននូវរឿងរ៉ាវតែបន្តិចបន្តួចប៉ុណ្ណោះ ។ ចំណែកបងប្រុសរបស់គាត់ម្នាក់ទៀត មិនដែលបានរស់នៅជាមួយគ្នាទេ ដោយសារបងរបស់គាត់បានចូលបម្រើកងទ័ព ហើយផ្លាស់ប្ដូរទៅការពារនៅតំបន់ប្រាសាទព្រះវិហារ ។


ឃុន ឡាប

នៅក្នុងវ័យទើបតែ១៥ឆ្នាំ ឡាប ត្រូវបានចាស់ទុំផ្សំផ្គុំជាមួយប្ដីឈ្មោះ ហួយ ដែលមានតួនាទីជាកងទ័ពនៅសមរភូមិមុខ ។ ប្ដីគាត់បានស្គាល់បងប្រុសរបស់គាត់ នៅពេលប្រយុទ្ធនៅសមរភូមិរួមគ្នា ។ បន្ទាប់ពីរៀបការរួច គាត់មិនបាននៅជុំគ្នាជាមួយប្ដីទេ ដោយសារប្ដីគាត់ត្រូវទៅបម្រើការងារ និងបំពេញតួនាទី ហើយរយៈពេលពីរបីខែទើបបមកជួបគ្នាម្ដង ។

នៅក្នុងឆ្នាំ១៩៨០ យាយរបស់គាត់បានទទួលមរណភាពដោយសារតែវ័យចាស់ជរា ។ រហូតដល់មានការប្រទាញប្រទង់រវាងកម្លាំងរដ្ឋាភិបាលភ្នំពេញ និងខ្មែរក្រហម នៅឆ្នាំ១៩៨៣ ឡាប រួមទាំងប្រជាជនផ្សេងទៀតបានគេចពីស្រុកកំណើតទៅនៅលើភ្នំ៨០៨ (នៅជួរភ្នំដងរែក) ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ ម៉ើត (ខ្សែត្រៀមជួរមុខ) ដែលបានផ្ដល់ការហូបចុក និងការធានាទៅលើសុវត្ថិភាពរបស់ប្រជាជន ។ នៅពេលមានហេតុការណ៍វាយប្រយុទ្ធគ្នា យោធាខ្មែរក្រហមបានជម្លៀសប្រជាជនចេញពីភ្នំ៨០៨ទៅដល់ជំរំភូណាយ ស្ថិតនៅទឹកដីប្រទេសថៃ ដែលការហូបចុក និង សម្ភារប្រើប្រាស់គ្រប់យ៉ាងទទួលពីអង្គការអន្តរជាតិ ។

នៅឆ្នាំ១៩៨៩ គាត់បានចាកចេញពីជំរំមករស់នៅភ្នំ៨០៨ ដដែល ហើយទទួលបានជំនួយពីទាហានខ្មែរនៅតំបន់នោះផ្ទាល់ ដែលទទួលបានពី តាម៉ុក ដែលត្រូវជាប្រធានរបស់ ម៉ើត ។ ទោះបីយ៉ាងណាគាត់មិនមានផ្ទះជាក់លាក់ទេ គឺមានតែរោងតូចៗសង់ជាជួរ ហើយបាំងដោយតង់កៅស៊ូប៉ុណ្ណោះ ។ ការឧបត្ថម្ភនៅពេលនោះមិនបានទទួលគ្រប់គ្នានោះទេ ដោយសារប្រជាជនមានចំនួនច្រើន ។ ប្រជាជនមួយចំនួនបានទៅស្នាក់នៅអតីតមន្ទីរពេទ្យចាស់ ។

នៅពេលស្ងប់ស្ងាត់ការវាយប្រយុទ្ធគ្នា គាត់បានចុះពីលើភ្នំ

មកប្រកបរបរធ្វើស្រែចម្ការដដែលតែមិនបានវិលត្រឡប់ទៅរស់នៅស្រុកកំណើតវិញទេ ។ គាត់កើតបានកូនប្រុសម្នាក់ដោយមានអ្នកជិតខាងជួយមើលថែរក្សា ដែលជាចំណងដៃជាមួយស្វាមី ។ ការរស់នៅរបស់គ្រួសារគាត់មិនមានភាពជាក់លាក់នោះទេ ព្រោះនៅមានការវាយប្រយុទ្ធគ្នានៅឡើយ ហើយគាត់ត្រៀមខ្លួនគ្រប់ពេលដើម្បីរត់គេចទៅលើភ្នំ ។ គាត់បានរៀបចំខោអាវទុករួចរាល់នៅពេលយប់ ។ គាត់មិនហ៊ាននិយាយគ្នាឮទេនៅពេលឮសំឡេងគ្រាប់កាំភ្លើងម្ដងៗ គឺបានខ្សឹបរួចនាំគ្នារត់ឡើងទៅលើភ្នំតែម្ដង ។ អ្នកខ្លះរត់ចូលព្រៃដើម្បីលាក់ខ្លួនទាំងយប់ដោយធ្វើដំណើរដល់ទីណានាំគ្នាដេកនៅទីនោះតែម្ដង ។ នៅពេលគាត់ស្ងួនស្ងោរខ្លាំងសូម្បីតែកន្លែងខ្លះដែលគាត់មិនហ៊ានទៅពីមុនមក ក៏គាត់ទៅដែរធ្វើយ៉ាងណាឲ្យតែបានរួចផុតជីវិត ។ នៅពេលឃ្លានគឺសូម្បីតែស្លឹកគុយ ក៏គាត់បេះយកមកហូបដែរ ។ គាត់បានបែកពីប្ដី និងបីកូនរត់គ្រប់ទីកន្លែង ហើយសូម្បីសត្វសាហាវក៏គាត់លែងខ្លាចដែរឲ្យតែបានរួចជីវិត ។

ក្រោយមក មានមិត្តរួមក្រុមជាមួយប្ដីគាត់ ប្រាប់ថា ប្ដីរបស់គាត់បានស្លាប់បាត់ហើយ ដោយសារត្រូវគ្រាប់កាំភ្លើងនៅពេលប្រយុទ្ធគ្នានៅតំបន់ទន្លេសាប ដោយប្ដីគាត់បានផ្ដាំថា “មិនអាចត្រឡប់មកវិញបានទេ” ។ ឡាប តក់ស្លុតយ៉ាងខ្លាំងនៅពេលដឹងដំណឹងនេះ ហើយសូម្បីតែសាកសពក៏យកមកមិនបានដែរ ដែលធ្វើឲ្យគាត់អាណិតប្ដីយ៉ាងខ្លាំង ។ ឡាប ជាកូនកំព្រាតាំងពីតូច ហើយមកដល់ពេលនេះ កូនរបស់គាត់ក៏ក្លាយជាក្មេងកំព្រាដូចគាត់ដែរ ។ ក្រោយមក ឡាប បានសុំក្មេងស្រីម្នាក់ដែលឪពុកម្ដាយស្លាប់ចោលមកចិញ្ចឹមទៀត ។ នៅឆ្នាំ១៩៩៨ ឡាប បានចុះពីលើភ្នំមករស់នៅភូមិទួលប្រាសាទ ឃុំត្រពាំងតាវ ស្រុកអន្លង់វែង ខេត្តឧត្ដរមានជ័យ រហូតដល់សព្វថ្ងៃ ។

អ៊ំស្រីមិនដែលបានគិតថាខ្លួននឹងរស់រានមានជីវិតរហូតមកដល់សព្វថ្ងៃនេះឡើយ ដោយសារការអស់សង្ឃឹម និងភាពគ្មានលំនឹងក្នុងការរស់នៅ ។ គាត់មិនចង់ឲ្យអ្នកផ្សេងបានជួបនូវរឿងរ៉ាវដែលគាត់បានឆ្លងកាត់ឡើយ ។ គ្រប់ពេលដែលគាត់មើលទូរទស្សន៍ដែលបញ្ចាំងភាពយន្តទាក់ទងទៅនឹងសង្គ្រាម គឺធ្វើឲ្យគាត់ស្រក់ទឹកភ្នែកទាំងមិនដឹងខ្លួន ។ ជីវិតដែលនាំកូនរត់កាត់ព្រៃ នៅតែជាសុបិនសម្រាប់គាត់ ហើយគាត់សូមស្នាលាពីជីវិតព្រាត់ប្រាស់បែបនេះ ។

**ហ៊ួន ស៊ីថា**



រូបខាងឆ្វេង ៈ ឃុន ឡាប និង ហួន ស៊ីង៉ា និស្សិតឆ្នាំទី៣ ផ្នែកប្រវត្តិសាស្ត្រ នៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ថតពេលចុះស្រាវជ្រាវ[illegible] ក្នុងភូមិទួលប្រាសាទ ឃុំត្រពាំងតាវ ស្រុកអន្លង់វែង ខេត្តឧត្ដរមានជ័យ

# ស្ម័គ្រចិត្តដើម្បីបដិវត្តន៍

តំបន់អន្លង់វែង ជាតំបន់មួយដែលមានប្រវត្តិតាំងពីរយូរអង្វែងណាស់មកហើយ ហើយក៏ជាតំបន់តស៊ូចុងក្រោយរបស់ចលនាកុម្មុយនីស្តខ្មែរក្រហមដែរ ។ ប្រជាជនដែលធ្លាប់រស់នៅស្រុកអន្លង់វែងបានរៀបរាប់អំពីជីវិតលំបាកវេទនា និងភាពមិនមានទីលំនៅច្បាស់លាស់ក្នុងអំឡុងពេលសង្គ្រាម ដែលបន្តគ្របដណ្តប់មកលើជីវិតរស់នៅប្រចាំថ្ងៃរបស់គាត់ ។ ជីវិតហាក់ដូចជាដំណើរផ្សងព្រេង និងព្រួយបារម្ភជារៀងរាល់ថ្ងៃ ។ ការប្រយុទ្ធគ្នាបានកើតមានឡើងជាញឹកញាប់នៅតំបន់នេះ ធ្វើឲ្យប្រជាជនបង្ខំចិត្តរត់ភៀសខ្លួនពីកន្លែងមួយទៅកន្លែងមួយទៀតដើម្បីរួចផុតពីគ្រោះថ្នាក់ ។ ចំណែកកងទ័ពបានរងរបួស និងស្លាប់ជាច្រើននាក់ ហើយត្រូវសែងកាត់តាមភូមិជារៀងរាល់ថ្ងៃ រហូតដល់ថ្ងៃដែលកងទ័ពវៀតណាមបានដកចេញពីតំបន់នេះទើបស្ថានភាពបានប្រសើរឡើងវិញ ។

ជ័យ សាន អាយុ៦៨ឆ្នាំ មានស្រុកកំណើតនៅភូមិតាពោល ឃុំប្រាំបីមុំ ស្រុកថ្ពង ខេត្តកំពង់ស្ពឺ បច្ចុប្បន្នរស់នៅភូមិស្វាយចេក ឃុំថ្លាត ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ បានមានប្រសាសន៍ថា គាត់ចូលកងទ័ពចាប់តាំងពីឆ្នាំ១៩៧២ នៅពេលគាត់មានអាយុប្រហែល២០ឆ្នាំ ។ មូលហេតុដែលគាត់ចូលយោធាដោយសារពេលនោះមានអ្នកបំផុសឲ្យចូលរំដោះប្រទេស ព្រោះមានយន្តហោះទម្លាក់គ្រាប់បេ៥២លើប្រទេសកម្ពុជា និងដើម្បីនាំសម្តេចតាចូលមកប្រទេសវិញ ។ នៅខណៈនោះ គាត់ឃើញយុវជនជាច្រើនបានចូលបដិវត្តន៍ ទើបគាត់ស្ម័គ្រចិត្តចូលធ្វើយោធា ។ មកដល់ឆ្នាំ១៩៧៦ គាត់ត្រូវបានអង្គការចាត់តាំងឲ្យចូលធ្វើពេទ្យទាហាននៅរតនគិរី រហូតដល់ឆ្នាំ១៩៧៨ ។

នៅឆ្នាំ១៩៧៩ គាត់បានចេញពីរតនគិរីមករស់នៅស្រុកអន្លង់វែងដោយ ធ្វើដំណើរដោយថ្មើរជើង និងហូបតែដំឡូងក្រហម និងក្តួចបុំណ្ណោះដំនួសបាយ ។ មានអ្នកខ្លះដែលទ្រាំទ្រពុំបាននឹងការអត់ឃ្លាននេះ បានស្លាប់នៅតាមផ្លូវហើយអ្នកដែលមានជីវិតបាន



ជួរខាងមុខ រូបទីពីររាប់ពីស្តាំ ៖ សម ចាន់មុន្នី និស្សិតឆ្នាំទី៣ ផ្នែកអក្សរសាស្ត្រ នៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ថតពេលចុះទស្សនកិច្ចសិក្សានៅតំបន់ប្រវត្តិសាស្ត្រ ក្នុងស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ

រស់នៅក្រោមការគ្រប់គ្រងរបស់តាម៉ុក ។ ក្រោយមក តាម៉ុក ក៏បានចាត់តាំងគាត់ជាគ្រូបង្រៀន និងត្រូវបង្រៀនស្របតាមកម្មវិធីសិក្សាសម័យនោះ ។ សាន បានបន្តថា ប្រជាជនដែលរស់នៅទីនោះបានបើកស្បៀងអាហារ និងសម្ភារប្រើប្រាស់ផ្សេងៗទៀតពីឃ្លាំងរបស់ តាម៉ុក ដែលចែកឲ្យជារៀងរាល់ខែ ។ តាម៉ុកបានប្រាប់ឲ្យប្រជាជនដឹង និងចេះការពារទឹកដី ចេះសាមគ្គីគ្នា និងផ្តល់សិទ្ធិឲ្យរស់នៅស្មើៗគ្នា ។ ចំណែកផ្នែកនយោបាយ ខ្មែរក្រហមបានឃោសនាថា បើយើងទៅសារភាព ឬចូលរដ្ឋកម្ពុជា នោះយួននឹងវះពោះញាត់ស្មៅ គឺយើងមានតែផ្លូវស្លាប់ប៉ុណ្ណោះ ដូច្នេះយើងត្រូវតែតស៊ូ ដែលអាចស្លាប់ និងរស់ តើយើងត្រូវជ្រើសរើសយកមួយណា?

សម្រាប់ សាន យល់ថា គំនិតមេដឹកនាំកាលសម័យនោះល្អ ព្រោះគាត់បានទទួលបានចំណេះដឹងពីអ្នកទាំងនោះ ។ គាត់តែងតែឮពាក្យចចាមអារ៉ាមថា ខ្មែរក្រហមសម្លាប់ប្រជាជនច្រើន តែចំពោះគាត់ដែលជាអតីតយោធាខ្មែរក្រហមមិនភ័យខ្លាចទេ ព្រោះគាត់មិនដែលឃើញមេដឹកនាំខ្មែរក្រហមធ្វើបាបនរណាម្នាក់ដោយផ្ទាល់ភ្នែកទេ ។

ទោះជាយ៉ាងណា មានហេតុផលជាច្រើនចំពោះការបែកបាក់ និងឈានទៅរកជម្លោះផ្ទៃក្នុងនៃចលនាខ្មែរក្រហម ដែលអាចមកពីការសម្រេចចិត្តចូលរួមបោះឆ្នោត ទើបបង្កឲ្យមានភាពតានតឹងនៅក្នុងចំណោមមេដឹកនាំខ្មែរក្រហម ។ ដូច្នេះជម្លោះ និងការប្រយុទ្ធគ្នាដោយបើកចំហរវាងមេដឹកនាំខ្មែរក្រហមបែបនេះ បានធ្វើឲ្យប្រជាជនបាត់បង់ការជឿជាក់ ។ ដោយសារតែមូលហេតុទាំងនេះ ទើបធ្វើឲ្យប្រជាជនយល់ឃើញថា សុភមង្គលអាចកើតមានបាន លុះត្រាតែនាំគ្នាចុះចូលជាមួយរដ្ឋាភិបាល ។

សាន មានប្រសាសន៍ថា បើប្រៀបធៀបពីសម័យមុន និងសម័យបច្ចុប្បន្ន មានភាពខុសគ្នាឆ្ងាយ ព្រោះគាត់បានជួបជុំគ្រួសារ ប្រពន្ធ កូន មានផ្ទះរស់នៅសមរម្យ មានសម្ភារប្រើប្រាស់គ្រប់គ្រាន់ ចំណែកនៅសម័យមុន គាត់ដើរស្ពាយតែកាំភ្លើងប៉ុណ្ណោះ ។ ដូច្នេះ ចំពោះការរស់នៅរបស់គាត់ ក៏ដូចជាប្រជាជនដទៃទៀតនៅក្នុងស្រុកអន្លង់វែងនាពេលបច្ចុប្បន្ន ភាគច្រើនប្រកបមុខរបរធ្វើស្រែចម្ការ ដាំដំឡូង ស្វាយចាន់ទី ដែលមានឈ្មួញមកទិញដល់ទីកន្លែង ។ មូលហេតុទាំងនេះហើយបានធ្វើឲ្យជីវភាពរបស់គាត់ និងប្រជាជនរស់នៅអន្លង់វែងនេះ បានប្រសើរជាងមុនបន្ទាប់ពីសង្គ្រាមបានបញ្ចប់ ។

**សម ចាន់មុន្នី**



រូបថត ឆ្នាំ២០១៦ ៖ កសិករនៅក្នុងស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ កំពុងប្រមូលផលដំឡូងយកទៅលក់ឲ្យឈ្មួញ

# ព្រះអង្គ សួស សំបុត : សង្គ្រាមគឺជាអំពើបាប

នៅក្នុងវត្តមួយឈ្មោះ វត្តទួលប្រាសាទ អូរអង្គ្រែ ដែលស្ថិតនៅមិនឆ្ងាយប៉ុន្មានពីទីរួមស្រុកអន្លង់វែង ខ្ញុំមើលទៅហាក់មានសភាពស្ងប់ស្ងាត់ និងមានព្រះសង្ឃគង់នៅមិនដល់១០អង្គផង ។ នាងខ្ញុំបានសាកសួរព្រះតេជគុណមួយអង្គដែលកំពុងគង់នៅលើកុដិឈើមួយដែលមានសភាពចាស់ទៅហើយ ទាក់ទងទៅនឹងរឿងរ៉ាវដែលព្រះអង្គបានឆ្លងកាត់ក្នុងរបបខ្មែរក្រហម ។

ព្រះអង្គមានសង្ឃដីកាថា ព្រះអង្គនាម សួស សំបុត មានស្រុកកំណើតនៅក្នុងស្រុកឈូក ខេត្តកំពត ។ សព្វថ្ងៃព្រះអង្គនៅភូមិទួលប្រាសាទ ឃុំត្រពាំងតាវ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ ។ ព្រះអង្គកើតនៅឆ្នាំ១៩៤០ (នៅក្នុងសម័យតស៊ូរបស់ខ្មែរឥស្សរប្រឆាំងអាណានិគមបារាំង) រហូតដល់បច្ចុប្បន្ន ព្រះអង្គមានព្រះជន្ម៧៣ព្រះវស្សាហើយ ។ នៅក្នុងសម័យតស៊ូប្រឆាំងបារាំង ផ្ទះសម្បែង និងក្រុមគ្រួសារព្រះអង្គបានផ្លាស់ទៅរស់នៅដុំគ្នា និងប្តូរទីតាំងជាច្រើនកន្លែង ។ នៅឆ្នាំ១៩៥៤ ក្រោយពីព្រះបាទនរោត្តម សីហនុ បានទាមទារឯករាជ្យរួចមក ព្រះអង្គក៏បានវិលត្រឡប់មករស់នៅក្នុងស្រុកកំណើតជាមួយក្រុមគ្រួសារនៅក្នុងស្រុកឈូកវិញ ។ ឪពុកម្តាយរបស់ព្រះអង្គនៅសម័យនោះ បានប្រកបមុខរបរធ្វើស្រែចម្ការ នេសាទត្រី ចិញ្ចឹមមាន់ ទា ដើម្បីបរិភោគប្រចាំថ្ងៃ ព្រោះផ្សារនៅឆ្ងាយពីភូមិ ។ ក្រុមគ្រួសាររបស់ព្រះអង្គរស់នៅប្រកបដោយសុភមង្គល ទោះបីជាមិនមានប្រាក់ច្រើនដូចគេ រីឯជីវភាពក្នុងគ្រួសារក៏មិនលំបាកដែរ គឺអាចផ្គត់ផ្គង់ចិញ្ចឹមសមាជិកទាំងអស់បាន ។

ក្រោមការដឹកនាំរបស់ព្រះបាទនរោត្តម សីហនុ នៅក្នុងសម័យនោះធ្វើឲ្យប្រជាជនពេញចិត្តយ៉ាងខ្លាំង ព្រោះព្រះអង្គយល់ពីទុក្ខធុរៈរបស់ប្រជាជន ។ មកដល់ឆ្នាំ១៩៦២ ទើបព្រះអង្គសម្រេចចិត្តបួសជាព្រះសង្ឃ ក្នុងព្រះជន្ម២១ព្រះវស្សាដោយសារតែការធុញទ្រាន់នឹងការរស់នៅក្នុងផ្លូវលោកដែលគ្មានទ្រឹស្តីណាមួយល្អដែលអាចជឿជាក់បាន ព្រះអង្គឃើញតែការបោកប្រាស់កេងប្រវ័ញ្ច និងកាប់សម្លាប់គ្នាទៅវិញទៅមក ។ ជាក់ស្តែង ព្រះអង្គឃើញអ្នកដែលរស់នៅក្បែរផ្ទះព្រះអង្គសូម្បីតែដីមួយចបក៏មានការឈ្លោះប្រកែកគ្នា ហើយអ្នកដែលមានអំណាចមានប្រាក់បានឈ្នះ ហើយអ្នកដែលគ្មានអំណាចក៏ចាញ់ទើបធ្វើឲ្យព្រះអង្គសម្រេចចិត្តស្មៀកស្បង់ជីវរ ដើម្បីរួចផុតពីសេចក្តីទុក្ខទាំងនេះ ដោយពុំមានការបង្ខំ ឬរារាំងពីឪពុកម្តាយបងប្អូនឡើយ ។ ក្នុងពេលដែលព្រះអង្គនៅជាសង្ឃ ព្រះអង្គបាននិមន្តសិក្សារៀនសូត្រតាមវត្តនានា ។

រហូតមកដល់ឆ្នាំ១៩៦៩ ដោយសារព្រះអង្គមើលឃើញពីសភាពការណ៍មិនល្អ ហើយអ្នកដែលបានធ្វើការតស៊ូទាក់ទងរឿងនយោបាយត្រូវបានចាប់ខ្លួន និងយកទៅសម្លាប់នៅភូមិត្រពាំងក្រឡឹង ក្នុងខេត្តកំពង់ស្ពឺ ទើបព្រះអង្គសឹក ។ បន្ទាប់មកព្រះអង្គក៏សម្រេចចិត្តទៅធ្វើកម្មករនៅកំពង់សោម ។ ព្រះអង្គកាប់ឈើនៅម្តុំស្ទឹងហាវរួចជញ្ជូនមកដាក់គរលើផ្លូវ ដោយក្នុង១ថ្ងៃទទួលបានប្រាក់៨០រៀល ដើម្បីចិញ្ចឹមជីវភាពគ្រួសារ ។ ព្រះអង្គធ្វើការបានប្រហែលជាងមួយឆ្នាំក៏មានរដ្ឋប្រហារ ទើបព្រះអង្គត្រឡប់មកស្រុកកំណើតនៅឈូកវិញ ។

ក្រោយរដ្ឋប្រហារឆ្នាំ១៩៧០ សង្គ្រាមចាប់ផ្តើមផ្ទុះឡើង កងទ័ពវៀតណាមបានចូលមកប្រទេសកម្ពុជាដោយពាក់ស្លាកព្រះបាទនរោត្តមសីហនុ ហើយឃោសនាឲ្យប្រជាជនចូលរួមតស៊ូប្រឆាំងអាមេរិកាំង ដើម្បីជួយរំដោះកម្ពុជាចេញពីរបប លន់ នល់ ។ វៀតណាមបានប្រមូលប្រជាជនដែលចង់ធ្វើទាហានដើម្បីប្រឆាំងជាមួយ លន់ នល់ ។ វៀតណាមបានប្រកាសប្រាប់ប្រជាជនដែលគោរពស្រលាញ់ខ្លួនត្រូវនាំគ្នារត់ចូលព្រៃម៉ាគី ដោយឡែកព្រះអង្គមិនបានចូលរួមទេ ។ ព្រះអង្គបានតាំងចិត្តរួចហើយថា ព្រះអង្គស៊ូស្លាប់នៅស្រុកភូមិ ហើយក៏មិនច្បាំង កាប់សម្លាប់ បង្ហូរឈាមគ្នាដែរ ដោយសារព្រះអង្គធ្លាប់បួស និងកាន់ធម៌អាថ៌ ។ ព្រះអង្គគិតថា ប្រសិនបើកើតសង្គ្រាម នឹងនាំឲ្យមានការកាប់សម្លាប់ បង្ហូរឈាម ដែលជាអំពើបាបដូច្នេះព្រះអង្គសម្រេចចិត្តមិនធ្វើទាហានឡើយ ។

ស្របពេលនោះ ឪពុកម្ដាយព្រះអង្គមើលឃើញព្រះអង្គជាមនុស្សមានការភ័យខ្លាចសង្គ្រាមក៏ផ្សំផ្គុំព្រះអង្គឲ្យរៀបការក្នុងវ័យ៣០ឆ្នាំ ដើម្បីជៀសផុតពីការចូលយោធា ។ ព្រះអង្គរៀបការប្រពន្ធដែលជាអ្នកភូមិជាមួយគ្នាឈ្មោះ គង់ ណុង អាយុ៣៨ឆ្នាំ ។ ព្រះអង្គ និង ណុង ធ្លាប់ស្គាល់គ្នាពីមុនមក ដោយសារ ណុង ធ្លាប់មកធ្វើបុណ្យនៅវត្តដែលព្រះអង្គធ្លាប់បួសរៀន ប៉ុន្តែព្រះអង្គ និង ណុង មិនដែលចាប់ចិត្តស្រលាញ់គ្នាទេ ។ ទោះបីជាពិធីរៀបការនេះហាក់មានការបង្ខំបន្តិច តែព្រះអង្គក៏ពេញចិត្តនឹងការរៀបចំរបស់ឪពុកម្ដាយដែរ ព្រោះព្រះអង្គអាចរួចផុតពីការចូលធ្វើយោធា ហើយបានរស់នៅជួបជុំជាមួយក្រុមគ្រួសារ ។ នៅក្នុងអំឡុងព្រះអង្គកំពុងរៀបអាពាហ៍ពិពាហ៍ ក៏ជាពេលដែលកំពុងមានសង្គ្រាមជាមួយ លន់ នល់ ដែរ ហើយក៏គ្មានភ្ញៀវណាហ៊ានមកចូលរួមដែរ ។ ក្រោយរៀបការរួច ព្រះអង្គរស់នៅជាមួយក្រុមគ្រួសារដោយមានដីស្រែចម្ការបន្តិចបន្តួចសម្រាប់ដាំដុះ ហើយទោះបីជាមិនបានលក់ដូរក៏ដោយ តែគ្រួសាររបស់ព្រះអង្គរស់នៅដោយសុភមង្គល មានផ្ទះសម្បែង និងអាចផ្គត់ផ្គង់ជីវភាពគ្រប់គ្រាន់ ។ មួយរយៈក្រោយមក ព្រះអង្គត្រូវបានចាត់តាំងឲ្យធ្វើការងារខាងសេដ្ឋកិច្ចប្រចាំស្រុកឈូក តែព្រះអង្គធ្វើបានប្រមាណ២ខែប៉ុណ្ណោះក៏សម្រេចចិត្តឈប់ ដោយសារខ្លាចមានអ្នកគំគួនវាយសម្លាប់ ។

នៅឆ្នាំ១៩៧២ ព្រះអង្គត្រូវបានអង្គការចាត់តាំងឲ្យធ្វើជាងឈើ និងសែងលាមកយកទៅឲ្យប្រជាជននៅតាមកងលាយជាមួយផេះដើម្បីធ្វើជីដាក់ដាំដំណាំ ។ រហូតមកឆ្នាំ១៩៧៥ របស់របរប្រើប្រាស់ទាំងអស់ត្រូវអង្គការប្រមូលដាក់ជាសម្បត្តិសមូហភាព និងដាក់ឲ្យប្រើប្រាស់រួមគ្នា សូម្បីតែដីធ្លី ហើយផ្ទះសម្បែងក៏ត្រូវបានខ្មែរក្រហមរុះរើគ្មានសល់អ្វីដែរ ។ ប្រជាជនត្រូវរស់នៅរួមគ្នា សូម្បីតែស្លាបព្រាមួយក៏មិនហ៊ានទុកដែរ ព្រោះនៅពេលអង្គការរកឃើញនឹងចោទថាខ្មាំង និងយកទៅសម្លាប់ចោលមិនខាន ។

រហូតមកដល់ឆ្នាំ ១៩៧៧ អង្គការបំបែកប្រជាជនចេញជាកងចល័ត ហើយឪពុកម្ដាយត្រូវបានដាក់ឲ្យរស់នៅដាច់ដោយឡែកពីកូន ។ អង្គការបានយកក្មេងៗទៅដាក់នៅក្នុងមណ្ឌលកុមារ ចំណែកព្រះអង្គត្រូវអង្គការចាត់តាំងឲ្យធ្វើការនៅខាងសិប្បកម្ម ហើយឆ្លៀតពេលទំនេរត្រូវទៅលើកភ្លឺស្រែថែមទៀត ។ យូរៗម្ដងទើប ព្រះអង្គបានមកជួបប្រពន្ធម្ដង ព្រោះប្រពន្ធព្រះអង្គ ត្រូវអង្គការចាត់តាំងឲ្យទៅដកស្ទូងនៅតាមតំបន់ផ្សេងៗ ។

អង្គការបានរឹតបន្តឹងសីលធម៌ ទាំងការនិយាយស្តី ទំនាក់ទំនងជាមួយនារី គឺត្រូវតែហាមឃាត់ ។ រាល់ការសុំច្បាប់ទាល់តែធ្វើកិច្ចការចប់សព្វគ្រប់ហើយ ទើបអាចមកជួបក្រុមគ្រួសារបានដែលយូរបំផុតត្រឹមតែមួយថ្ងៃប៉ុណ្ណោះ ។ ក្រោយមក អង្គការបានចាត់តាំងព្រះអង្គឲ្យឡើងត្នោត ហើយព្រះអង្គក៏រងគ្រោះធ្លាក់បាក់ដៃបាក់ឆ្អឹងខ្នង និងបាក់ធ្មេញ ។ ព្រះអង្គបានដេកព្យាបាលនៅផ្ទះអស់រយៈពេលជាច្រើនថ្ងៃ តែក៏គ្មានខ្មែរក្រហមមកសួររកព្រះអង្គដែរ ។

រហូតដល់បែកឆ្នាំ១៩៧៩ មានមិត្តភក្តិព្រះអង្គម្នាក់ដែលបានទៅរៀនសូត្រនៅហាណូយបានត្រឡប់មកវិញ បានហៅព្រះអង្គឲ្យចូលធ្វើជាគ្រូបង្រៀននៅសាលាបឋមសិក្សាស្រុកឈូក ។ ព្រះអង្គបង្រៀនកូនចៅ និងសិស្សរហូតចប់ថ្នាក់ និងចេញប្រកបការងារគ្រប់គ្នា ទើបព្រះអង្គលាឈប់ពីបង្រៀននៅឆ្នាំ១៩៩៨ ។ ក្រោយមក ព្រះអង្គក៏ចូលបួសម្ដងទៀត ហើយក៏និមន្តមកគង់នៅវត្ត ក្នុងស្រុកអន្លង់វែងនេះ ។ ព្រះអង្គមានគោលបំណងចង់តាមរកប្អូនដែលបានបាត់ខ្លួននៅក្នុងរបប លន់ នល់ ដែរ ។

របបខ្មែរក្រហម បានធ្វើឲ្យព្រះអង្គមានការឈឺចាប់ ព្រោះសាច់ញាតិព្រះអង្គត្រូវបានខ្មែរក្រហមធ្វើបាប និងបំបែក ។ មានរឿងជាច្រើនទៀតដែលអង្គមិនអាចរៀបរាប់បាន ព្រោះជាអតីតកាលដែលកន្លងផុតជាយូរមកហើយដែលប្រជាជនកម្ពុជាបានជួបប្រទះ ។ ចុងក្រោយ ព្រះអង្គសូមឲ្យប្រទេសមានសុខសន្តិភាព គ្មានសង្គ្រាម គ្មានការគាបសង្កត់ដូចមុនទៀត ។ **ផាន់ ម៉ារ៉ាឌី**

# អានទស្សនាវដ្ដីតាមគេហទំព័រ

ទស្សនាវដ្ដីស្វែងរកការពិតទាំងអស់ត្រូវបានផ្សព្វផ្សាយតាមគេហទំព័ររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។ អ្នកអានអាចរកបានតាមៈ http://d.dccam.org/Projects/Magazines/Magazine_Searching.htm • ព័ត៌មានបន្ថែម សូមទាក់ទង សោម ប៊ុនថន ទូរស័ព្ទលេខ ០ ១២ ៩៩៦ ៧៥ ០ ឬ ០២៣ ២១១ ៨៧៥ ។

# ទេព សៀក : កម្មាភិបាលពេទ្យព-១ តំបន់២៣ ភូមិភាគបូព៌ា

*ទេព សៀក អាយុ៦៦ឆ្នាំ មានស្រុកកំណើតនៅភូមិព្រៃរលួស ឃុំចន្ទ្រី ស្រុករមាសហែក ខេត្តស្វាយរៀង។ សៀក មានបងប្អូន៣នាក់(ស្លាប់ម្នាក់ជំនាន់សង្គ្រាម៥ឆ្នាំ១៩៧០-១៩៧៥) ហើយសព្វថ្ងៃនៅសល់២នាក់គឺ បងស្រី និងសៀកខ្លួនឯង។ សៀក មានកូន៥នាក់ ស្រី២នាក់ ប្រុស៣នាក់។ កាលពីនៅក្មេង សៀក រៀនដល់ថ្នាក់ទី៥ "ចាស់" នៅអនុវិទ្យាល័យ៩ វិច្ឆិកា ១៩៥៣ នៅរមាសហែក ដល់ឆ្នាំ១៩៧០ មានសង្គ្រាមក៏ឈប់រៀន។ បន្ទាប់ពីឈប់រៀន សៀក ស្ម័គ្រចិត្តសិក្សាផ្នែកវិជ្ជាពេទ្យជាមួយកងទ័ពវៀតណាម ដែលចូលមកជួយកងទ័ពខ្មែរក្រហមនៅក្នុងភូមិរបស់សៀក នៅចុងឆ្នាំ១៩៧០។ វិជ្ជាពេទ្យដែលសៀកបានរៀនគឺពេទ្យបឋមដើម្បីជួយសង្គ្រោះកងទ័ពរបួសនៅលើសមរភូមិ។ កាលដែល សៀក រៀនពេទ្យនេះក៏បានរួមចំណែកក្នុងការថែទាំសុខភាពក្រុមគ្រួសារ និងខ្លួនឯងនៅខណៈពេលប្រទេសជាតិកំពុងមានសង្គ្រាម។ នៅពេល សៀក កំពុងរៀនពេទ្យនោះក៏មានការទម្លាក់គ្រាប់បែក និងមានទាហានខាងវៀតកុង ចូលមក និងបាញ់ផ្លោងមកខាងផ្សារចន្ទ្រី ធ្វើឲ្យមានមនុស្សស្លាប់ជាច្រើន។ បន្ទាប់មកទៀតក៏មានផ្ទុះគ្រាប់ស្លាប់មនុស្សជាច្រើន នៅភូមិបឹងវែង ដែលស្ថិតនៅក្បែរភូមិរបស់សៀក។ ដោយសារបងម្នាក់គាត់ធ្វើពេទ្យឲ្យខាងរំដោះ ហើយក៏ធ្លាប់បានបង្រៀនវិជ្ជាពេទ្យដល់ សៀក គាត់មានប្រពន្ធនៅភូមិបឹងវែងហ្នឹង នៅពេលខ្មែរក្រហមវ៉ៃគ្នានៅភូមិបឹងវែងចប់គាត់បានទៅសួរសុខទុក្ខក្រុមគ្រួសារគាត់នៅបឹងវែងស្លាប់រស់យ៉ាងណា ត្រឡប់មកវិញបានយកគ្រាប់៧២មកជាមួយ។ គាត់បានយកគ្រាប់៧២ មកបញ្ឈរចោលនៅក្រោមផ្ទះ ហើយប្រាប់ក្មេងៗថាកុំលេងគាត់ទុកថ្ងៃធ្វើស្នប់ ហើយគាត់ក៏ឡើងទៅសម្រាកលើផ្ទះបាត់។ ស្រាប់តែមានឈ្មោះ ធឿន*



*រូបថតឆ្នាំ២០១៦ : ទេព សៀក នៅផ្ទះរបស់គាត់ក្នុងសង្កាត់ព្រែកឯង ខណ្ឌច្បារអំពៅ ក្រុងភ្នំពេញ*

មករៀនពេទ្យដែរ មានស្រុកកំណើតនៅព្រៃវែង ។ ព្រោះតែធ្លាប់ឃើញគេបាញ់ ស្រាប់តែលើកកាន់អាមេហើយចុច ធឿន បានដាក់កាណុងបែមកចំបាតដៃរបស់ខ្លួនឯង ហើយពេលដែលបាញ់គឺរយៈដៃដាច់អស់ម្រាមដៃ២-៣ ហើយក្បាលគ្រាប់ធ្លាក់ចូលភក់ក្របី ។ ពេលដែល សៀក ឃើញ ធឿន ដាច់ដៃក៏រត់ទៅសុំសំឡី និងបង់មករុំរបួសឲ្យ ធឿន ។ គ្រាប់ដែល ធឿន បានបាញ់ទៅនោះមិនទាន់ផ្ទុះ តែពេលអ្នកស្រុករត់មកមើលច្រើន ស្រាប់តែគ្រាប់៧២នោះផ្ទុះឡើងធ្វើឲ្យអ្នកស្រុកស្លាប់អស់ជាច្រើននាក់ ។ ឆ្នាំ១៩៧៤ ពេលដែលធ្វើការនៅពេទ្យឃុំចន្រ្ទី សៀក ស្នើរៀបចំគ្រួសារ ហើយរួមរស់ជាមួយគ្នាបានកន្លះខែក៏ត្រូវផ្លាស់ទៅធ្វើការនៅពេទ្យព-១ តំបន់២៣ របស់ភូមិភាគបូព៌ា ។

ចុងឆ្នាំ១៩៧៤ ស្នាក់ការពេទ្យដែល សៀក ប្រចាំការនៅភូមិទួលសាលា សម្រាប់ទទួលអ្នកជំងឺដែលត្រូវរបួស ព្រោះកងទ័ពខ្មែរក្រហមប្រយុទ្ធជាមួយទាហាន លន់ នល់ នៅភូមិចក ក្នុងស្រុករំដួល ។ សៀក ប្រចាំការនៅពេទ្យតំបន់២៣ ហៅព-១ ។ នៅពេទ្យព-១ មានដុកទ័រជនជាតិវៀតណាមឈ្មោះ ទីផា ដែលធ្វើការជាមួយសៀក ។ គណៈគ្រប់គ្រងពេទ្យព-១ ឈ្មោះ សាម៉ុល, សារិត ។

សៀក ធ្វើការនៅព-១ បានមួយឆ្នាំក៏បែកខេត្តស្វាយរៀង ហើយខ្មែរក្រហមចាត់តាំង សៀក ឲ្យទៅធ្វើការនៅខេត្តស្វាយរៀងវិញ ។ នៅពេលដែលកងទ័ពបោសសំអាតមន្ទីរពេទ្យរួច ខ្មែរក្រហមចាត់តាំងឲ្យបុគ្គលិកពេទ្យទៅចាំទទួលអ្នកជំងឺដែលជាកងទ័ពខាងរំដោះ ឬអ្នកស្រុកឈឺ ។ សៀក នៅក្នុងពេទ្យព-១ គឺជាពេទ្យបឋម ហើយការងារគឺជួយព្យាបាលអ្នកជំងឺតាមការណែនាំរបស់ដុកទ័រ, លាងរបួស, ចាក់ថ្នាំ, ផ្សំថ្នាំគ្រាប់ឲ្យ អ្នកជំងឺ, មានសំអាតកន្លែងរបស់អ្នកជំងឺ, បោកខោអាវឲ្យអ្នកជំងឺ និងអនាម័យឲ្យអ្នកជំងឺ ព្រោះអ្នកជំងឺជំនាន់នោះអត់មានបងប្អូនទៅថែរក្សាទេ មានតែបុគ្គលិកពេទ្យប៉ុណ្ណោះ ។

ពេលដែលខ្មែរក្រហមជម្លៀសប្រជាជនចេញពីភ្នំពេញ គឺមានប្រជាជនមកច្រើន ។ ខណៈនោះ សៀក បានឃើញខ្មែរក្រហមធ្វើទារុណកម្មទាហាន លន់ នល់ បង្អត់អាហារ, ខ្វះថ្នាំសង្កូវ ហើយមានពេលមួយ សៀក បានដើរកាត់កន្លែងឃុំឃាំងទាហាន គេហៅថាធ្លុកក្នុងទីរួមខេត្តស្វាយរៀង សៀក បានឃើញខ្មែរក្រហមលែងទាហានឲ្យចេញមកក្រៅ ទាហានទាំងនោះវារបេះទៅត្រួយកំប្លោក ផ្កាកំប្លោកនៅជិតផ្លូវ សៀក បានឃើញអ្នកខ្លះធាក់រហាត់បញ្ចូលទឹកស្រែប្រាំង ហើយមើលទៅអ្នកទាំងនោះមានសភាពស្គមស្គាំង ។ ក្រោយមកមានការផ្លាស់ប្តូរអ្នកគ្រប់គ្រងដោយយកអ្នកមកពីខាងតំបន់២៤ ទៅត្រួតត្រាជំនួស ដែលប្រធានកាលហ្នឹងឈ្មោះ តាសក់ ចំណែកគណៈឃុំចាស់ត្រូវបានចាប់ខ្លួនយកទៅសម្លាប់ ។ រីឯភាគនិរតីគ្រាន់តែដាក់ទ័ពការពារព្រំដែនទេ ។

នៅដើមឆ្នាំ១៩៧៦ ដោយមានការហត់ពេក ព្រោះត្រូវមើលអ្នកជំងឺ២០០ នាក់តែឯង (មានប្តូរវេនដែរ តែវេនមួយថ្ងៃម្នាក់) ហើយការហូបចុកក៏តិចផងនោះ ។ សៀក បានប្តូរទៅខាងរកម្ហូបសម្រាប់ផ្គត់ផ្គង់អគ្គភាពពេទ្យវិញម្តង ។ សៀក ទៅរកត្រីនៅទន្លេវៃកូ, បឹងជីភូ, ខាងរមាសហែក និងទៅរករហូតដល់ឡូនេសាទតំបន់២៤ ដែលជាកន្លែងសម្បូរត្រី ។ សៀក នៅខាងនេសាទត្រីរហូតដល់ ១៩៧៩ និងជួយធ្វើស្រែនៅវត្តសាមគ្គី ដីស្រែប្រហែល១០ហិកតា ។ សៀក រកម្ហូប និងធ្វើស្រែរហូតដល់វៀតណាមវាយចូលតែម្តង ។

នៅចុងឆ្នាំ១៩៧៨ បងប្អូនរបស់ សៀក ពីរនាក់ត្រូវបានខ្មែរក្រហមជម្លៀសឲ្យទៅខេត្តពោធិ៍សាត់ ហើយបងម្នាក់បានស្លាប់នៅទីនោះ ។ គាត់ស្លាប់នៅពេលរត់កាត់ខ្សែត្រៀម ហើយត្រូវខ្មែរក្រហមបាញ់សម្លាប់ ។ ប្រពន្ធបានស្ទុះទៅឱបប្តី ហើយប្តីបានផ្តាំថា «ឯងនាំកូនយើងទាំងប្រាំមួយនាក់រត់ទៅមុខទៀតចុះ ទុកខ្ញុំនៅទីនេះចុះ ខ្ញុំមិនរស់ទេ!» ។ ខ្មែរក្រហមបាញ់ត្រូវចំស្លូត ចំណែកកូនតូច ម្នាក់ដែលប្តីឱបនោះសំណាងល្អមិនត្រូវ ហើយនៅរស់រហូតដល់សព្វថ្ងៃ ។

នៅពេលដែលកងទ័ពវៀតណាមចូលមកគឺមានការប្រយុទ្ធគ្នាដែលធ្វើឲ្យ សៀក មិនអាចនៅទីរួមខេត្តបាន គាត់ក៏មកឃ្វាលគោនៅស្រុកកំណើតជួបជុំជាមួយប្រពន្ធ ។ ពេលហ្នឹងសៀក និងប្រពន្ធកូនរត់មកដល់ខាងត្បូងទីរួមខេត្តព្រៃវែង ឮសូរថាភ្នំពេញបែកហើយមានយន្តហោះបោះគ្រាក់ក៏នាំគ្នារើសមើល ។ ក្រោយមក ឮវិទ្យុប្រកាសផ្សាយថាភ្នំពេញបែកហើយ សៀក និងប្រពន្ធនាំគ្នាវិលទៅស្រុកកំណើតវិញ ។ នៅឆ្នាំ១៩៨៥ សៀក ចូលបម្រើការជាបុគ្គលិកមណ្ឌលសុខភាពឃុំ ជួយការងារផ្នែកសុខភាពរហូតដល់ឆ្នាំ២០០៣ទើបឈប់ពីការងារ ។ **រី លក្ខិណា**

# ចាប់ពីរបបខ្មែរក្រហម ដល់ឧប្បត្តិហេតុ ហាំបាលី : អត្តសញ្ញាណជនជាតិចាម នៅក្នុងយុគសម័យសកលភាវូបនីយកម្ម

**(តចប់)**

## អត្តសញ្ញាណសេដ្ឋកិច្ច

អត្តសញ្ញាណសេដ្ឋកិច្ចគឺជាអត្តសញ្ញាណជាយរបស់ជនជាតិចាមមួយទៀត ដែលតែងតែផ្លាស់ប្តូរ ។ អត្តសញ្ញាណសេដ្ឋកិច្ចគឺជាអ្វីដែលជនជាតិចាមតែងតែព្យាយាមកសាង និងរក្សាឲ្យបាននូវភាពរីកចម្រើនមួយសម្រាប់សហគមន៍របស់ពួកគេ ។ ប៉ុន្តែអត្តសញ្ញាណសេដ្ឋកិច្ចរបស់ជនជាតិចាមតែងតែស្ថិតក្នុងការវិវត្តអត្តសញ្ញាណសេដ្ឋកិច្ចនេះមិនដែលពេញលេញនោះទេ ពីព្រោះស្ថានភាពសេដ្ឋកិច្ច នៅក្នុងប្រទេសកម្ពុជា និងជាសកល ក៏កំពុងតែផ្លាស់ប្តូរដែរ ។ វិធីសាស្ត្រកាលប្បវត្តិ ដែលបានប្រើប្រាស់នៅក្នុងសៀវភៅបានបង្ហាញថាអត្តសញ្ញាណសេដ្ឋកិច្ចរបស់ជនជាតិចាមបានផ្លាស់ប្តូរក្នុងរយៈពេលពីរផ្សេង ។ នាពេលបច្ចុប្បន្នជនជាតិចាមនៅតែកំពុងបង្កើតអត្តសញ្ញាណសេដ្ឋកិច្ចមួយ ដែលពួកគេយល់ថាអាចនឹងស័ក្តិសមជាមួយស្ថានភាពនយោបាយ និងសាសនារបស់ពួកគេនៅក្នុងប្រទេសកម្ពុជា ។

រយៈពេល៦០ឆ្នាំចុងក្រោយនេះ ប្រទេសកម្ពុជាឆ្លងកាត់របបនយោបាយជាច្រើន របបទាំងនោះមានប្រព័ន្ធសេដ្ឋកិច្ចខុសប្លែកពីគ្នា ។ នៅប្រទេសចម្ប៉ា ជនជាតិចាមធ្លាប់ជាអ្នកដើរកប៉ាល់សមុទ្រ ដែលធ្វើជំនួយពាសពេញអាស៊ីអាគ្នេយ៍ ។ ជនជាតិចាមត្រូវបានគេចាត់ទុកជាអ្នកមានទេពកោសល្យខាងផ្នែកយុទ្ធសាស្ត្រ ដូចជាមេទ័ព និងស្តេចចាមដ៏អស្ចារ្យ ឆេ បុង ង៉ា ដែលជាឧទាហរណ៍មួយនៃភាពប្រសព្វខាងផ្នែកយុទ្ធសាស្ត្រ ។ ដូចដែលបានបង្ហាញនៅក្នុងសៀវភៅនេះ នៅពេលជនជាតិចាមបានមកដល់ប្រទេសកម្ពុជា ពួកគេទទួលបានការស្វាគមន៍ពីស្តេចខ្មែរ ដោយសារតែចំណេះដឹងរបស់ពួកគេអំពីសង្គ្រាម ។ ពេលជនជាតិចាមទៅដល់ប្រទេសថៃ ពួកគេក៏ទទួលបានការស្វាគមន៍នៅទីនោះដែរ ពីព្រោះចាមបានផ្តល់ទ័ពជំនួយទៅជួយស្តេចថៃក្នុងសង្គ្រាមជាមួយភូមា ។ ជនជាតិចាមក៏បានទទួលជ័យជម្នះលើទីក្រុងអង្គរក្នុងឆ្នាំ១១៧៧ ដោយបញ្ជូនកងទ័ពរបស់ខ្លួនមកវាយប្រហារតាមរយៈទន្លេមេគង្គ ។

កេរ្តិ៍ឈ្មោះអ្នកចម្បាំងរបស់ចាម និងទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយគ្រួសាររាជវង្សខ្មែរត្រូវបានបញ្ចប់ បន្ទាប់ពីការមកដល់នៃជនជាតិបារាំង ដែលជាអ្នកបង្កើតស្ថេរភាពនៅក្នុងតំបន់ឥណ្ឌូចិន និងការពារប្រទេសកម្ពុជាពីការទន្ទ្រានរបស់ប្រទេសជិតខាង ។ ដូច្នេះ អត្តសញ្ញាណសេដ្ឋកិច្ចរបស់ជនជាតិចាមក៏ផ្លាស់ប្តូរដែរ ។ ក្នុងនាមជាអ្នកចម្បាំងសេដ្ឋកិច្ចរបស់ជនជាតិចាមមានលក្ខណៈប្រសើរជាងជនជាតិខ្មែរ ។ ប៉ុន្តែ នៅក្រោយការគ្រប់គ្រងរបស់អាណាព្យាបាល


សិស្សថ្នាក់បឋមសិក្សាជនជាតិចាម នៅឃុំស្វាយឃ្លាំង ស្រុកក្រូចឆ្មារ ខេត្តត្បូងឃ្មុំ

បារាំង ឋានៈរបស់ជនជាតិចាម នៅក្នុងឆាកនយោបាយកម្ពុជាបានធ្លាក់ចុះ ។ ជនជាតិចាមបានបដិសេធបញ្ជូនកូនចៅរបស់ខ្លួនទៅសាលាខ្មែរ ឬទទួលការអប់រំពីប្រព័ន្ធសិក្សាបែបវិទ្យាសាស្ត្រ ដោយមានការភ័យខ្លាចថាអត្តសញ្ញាណស្នូលរបស់ជនជាតិចាមអាចនឹងបាត់បង់នៅថ្ងៃណាមួយ ។ ជនជាតិចាមមិនអាចរក្សា និងពង្រឹងអត្តសញ្ញាណជាអ្នកចម្បាំងរបស់ពួកគេបានឡើយ នៅក្រោមការត្រួតត្រារបស់បារាំង ។ ការអាក់ខាន មិនបានបញ្ជូនកូនចៅឲ្យទទួលបានការអប់រំបែបវិទ្យាសាស្ត្រ ធ្វើឲ្យអ្នកសង្កេតការណ៍មួយចំនួនជឿជាក់ថា ការខ្វះខាតការអប់រំបែបវិទ្យាសាស្ត្រនៅក្នុងប្រព័ន្ធបារាំង ជាហេតុបណ្តាលឲ្យសេដ្ឋកិច្ចរបស់ចាមជួប ប្រទះឱភាព ។

បច្ចុប្បន្ន អ្នកសង្កេតការណ៍ជាច្រើនយល់ថា សេដ្ឋកិច្ចរបស់ជនជាតិចាមស្ថិតនៅថ្នាក់ទាបបំផុតនៃដំណើរសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា ប៉ុន្តែ សៀវភៅនេះបានបង្ហាញថា ស្ថានភាពសេដ្ឋកិច្ចរបស់ជនជាតិចាមមានលក្ខណៈប្រហាក់ប្រហែលនឹងជនជាតិខ្មែរដែរសព្វថ្ងៃ ។ ជនជាតិចាមភាគច្រើនរស់នៅក្នុងខេត្តកំពង់ចាម ដែលជាតំបន់កសិកម្មដ៏មានដីជាតិមួយ ។ ស្ថានភាពរស់នៅរបស់ប្រជាជនក្នុងខេត្តកំពង់ចាមប្រសើរជាងប្រជាជនដទៃទៀតក្នុងខេត្តដែលមិនសូវមានសក្តានុពលកសិកម្ម ។ ចាមមួយចំនួនតូចតែប៉ុណ្ណោះ រស់នៅក្នុងភូមិថ្មីៗដែលកំពុងតែអភិវឌ្ឍ ដូចជាភូមិនៅតាម ជាយក្រុង និងតំបន់ឆ្ការព្រៃ ។ ប៉ុន្តែចាមរស់នៅក្នុងភូមិទាំងនេះ ដោយសារតែខំស្វែងរកភាពចម្រើនខាងសេដ្ឋកិច្ច ។

ចាមកំពុងតែកសាងអត្តសញ្ញាណសេដ្ឋកិច្ចរបស់ពួកគេក្នុងរបៀបមួយ ដែលអាចសមប្រកបជាមួយអត្តសញ្ញាណសេដ្ឋកិច្ចខ្មែរ ។ ពីព្រោះ ជនជាតិចាមមិនបរិភោគសាច់ជ្រូក ពួកគេប្រគល់មុខរបរទាក់ទងសាច់ជ្រូកទៅឲ្យជនជាតិខ្មែរ និងចិន ។ ពួកគេប្រកបមុខរបរទាក់ទងនឹងត្រី ថែមទាំងបានបង្កើតភូមិនេសាទជាច្រើននៅតាមបណ្តោយបឹងទន្លេសាប ។ ជាប្រពៃណីខ្មែរតែងតែស្គាល់ចាមថាជាអ្នកនេសាទ ។ នៅក្នុងខេត្តកំពង់ចាម ចាមបានដាំដំណាំតាមរដូវកាលតាមបណ្តោយទន្លេមេគង្គ ដំណាំ ទាំងនោះមានដូចជាថ្នាំជក់ ស្រូវ សណ្តែក និងល្ង ។ ពួកគេក៏បានបង្កើតក្រុមហ៊ុន និងភោជនីយដ្ឋានទាក់ទងជាមួយសាសនាអ៊ីស្លាម ។ ឧទាហរណ៍ ពួកគេរៀបចំដំណើរទេសចរណ៍ទៅកាន់ប្រទេសមូស្លីម និងដំណើរធម្មយាត្រាទៅទីក្រុងម៉ាកាស រួមទាំងបើកភោជនីយដ្ឋាន ដែលមានលក់ម្ហូបអាហារជ្រះស្អាត ហាឡាល់មិនមានសាច់ជ្រូក ។ លើសពីនេះទៅទៀត ពួកគេក៏លក់ផលិតផលអ៊ីស្លាមមួយចំនួន ដូចជា សម្លៀកបំពាក់ស្ត្រី សៀវភៅសាសនា គ្រឿងទេសសំខាន់ទាំងឡាយសម្រាប់មូស្លីម និងផលិតផលនាំចេញនាំចូលរវាងប្រទេសកម្ពុជា និងប្រទេសម៉ាឡេស៊ី ក៏ដូចជាប្រទេសមូស្លីមដទៃទៀត ។ ជនជាតិចាមទាំងពីរភេទធ្វើដំណើរទៅកាន់ប្រទេសថៃ ម៉ាឡេស៊ី កូរ៉េខាងត្បូង និងបណ្តាប្រទេសនៅអាស៊ីខាងកើតដើម្បីរកការងារជាកម្មករ ។ ជនជាតិចាមនៅទីក្រុងរកបានការងារនៅបណ្តាស្ថានប័នមិនមែនមូស្លីម ដូចជារាជរដ្ឋាភិបាល អង្គការមិនរកប្រាក់ចំណេញ និងក្រុមហ៊ុនឯកជនដែលមានទំនាក់ទំនងជាសកលយ៉ាងទូលំទូលាយ ។ ចាមជាច្រើនបានបង្កើតអង្គការមិនមែនរាជរដ្ឋាភិបាល ដែលទទួលជំនួញហិរញ្ញវត្ថុពីវិញពិភពលោក ដើម្បីផ្តល់ជំនួយទៅជនជាតិចាមដទៃទៀត ។ ជាទម្លាប់ចាមទាំងនេះ ធ្វើដំណើររវាងប្រទេសមូស្លីម និងជុំវិញពិភពលោក ។

ឪពុកម្តាយចាមគិតថា ចំណេះវិជ្ជាជាមធ្យោបាយមួយដែលអាចធ្វើឲ្យស្ថានភាពសេដ្ឋកិច្ចរបស់កូនពួកគាត់ប្រសើរជាងមុន ដូច្នេះអត្តសញ្ញាណសេដ្ឋកិច្ចរបស់ពួកគេអាចកំណត់សាជាថ្មី ។ ពួកគេបានបញ្ជូនកូនទៅកាន់សាលាអប់រំបែបវិទ្យាសាស្ត្រ និងសាលាសាសនា ប្រសិនពួកគេអាចធ្វើទៅបាន ។ ដើម្បីបំពេញតម្រូវការនេះ ពេលខ្លះពួកគេបញ្ជូនកូនចៅពីទីក្រុងទៅជនបទ នៅទីនោះការអប់រំសាសនាអ៊ីស្លាមមានលក្ខណៈល្អប្រសើរ ។ មានការខ្វែងគំនិតគ្នាថាតើចាមគួរកំណត់អត្តសញ្ញាណ សេដ្ឋកិច្ចសម្រាប់កូនចៅរបស់ពួកគេយ៉ាងដូចម្តេច រួមទាំងប្រភេទអប់រំបែបណាដែលពួកគេគួរផ្តល់ឲ្យកូនចៅ ។ ចំពោះឪពុកម្តាយដែលយល់ថា ការអប់រំបែបវិទ្យាសាស្ត្រពុំមានសារសំខាន់សម្រាប់កូនស្រី ពួកគេគ្រាន់តែបញ្ជូនកូនស្រីទៅសាលាបឋមតែប៉ុណ្ណោះ ។ ឪពុកម្តាយខ្លះបញ្ជូនទាំងកូនស្រី និងកូនប្រុសទៅកាន់សាលាសាសនា ដោយមានសង្ឃឹមថាកូនរបស់ពួកគេនឹងអាចក្លាយជាគ្រូសាសនាដ៏ល្អ បន្ទាប់ពីបញ្ចប់ការសិក្សា ។ ផ្ទុយទៅវិញ ឪពុកម្តាយខ្លះបញ្ជូនកូនស្រី និងកូនប្រុសទៅសាកលវិទ្យាល័យក្នុងស្រុក និងក្រៅស្រុក ដើម្បីទទួលបានការអប់រំថ្នាក់ជាន់ខ្ពស់ និងបង្កើនសក្តានុពលសេដ្ឋកិច្ចរបស់ពួកគេ ។

**ការពាក់ព័ន្ធជាមួយអំពើភេរវកម្ម**

ភេរវកម្មគឺជាអ្វីដែលជនជាតិចាមព្យាយាមជៀសវាង ពីព្រោះពួកគេចង់បង្កើតអត្តសញ្ញាណ សន្តិភាព និងរួមរស់ជាមួយគ្នានៅក្នុងសង្គមខ្មែរ ក៏ដូចជាការព្យាយាមក្នុងការស្រោចស្រង់សាសនារបស់ខ្លួនក្នុងរបៀបគយើង ។ ដោយសារតែរបៀបស្រោចស្រង់សាសនាអ៊ីស្លាមរបស់ជនជាតិចាមមិនមានលក្ខណៈរៀបរយ ពួកគេត្រូវបានចោទប្រកាន់ថាមានការជាប់ពាក់ព័ន្ធជាមួយនឹងភេរវកម្ម ថ្វីបើមានភ័ស្តុតាងតិចតួចតែប៉ុណ្ណោះ ដែលបង្ហាញពីទំនាក់ទំនងរវាងចាមជាមួយភេរវកម្ម និងការផ្តល់ជំនួយទៅដល់ក្រុមភេរវកម្មទាំងក្នុងកម្ពុជា ហើយនិងប្រទេសដទៃទៀត ។ សម្រាប់ជនជាតិចាមអំពើភេរវកម្មគឺ ជាចំណុចអវិជ្ជមាននៃអត្តសញ្ញាណនិកាយរបស់ពួកគេ ។ វាគឺជាចំណុចដែលតែងតែភ្ជាប់ពួកគេទៅនឹងអំពើភេរវកម្ម ទោះបីព្យាយាមគេចវេះយ៉ាងណាក៏ដោយ ។

ហេតុអ្វីបានជាជនជាតិចាមតែងតែត្រូវបានចាត់ទុកថាមានការភ្ជាប់ពាក់ព័ន្ធជាមួយអំពើភេរវកម្ម ទោះបីជាមានភ័ស្តុតាងតិចតួចដែលស្របទៅតាមការចោទប្រកាន់នេះ? សៀវភៅនេះបានរកឃើញថា ហេតុផលមួយចំនួនអាចយកមកបកស្រាយបាន ។ ទីមួយគឺស្ថានភាពសង្គម និងសេដ្ឋកិច្ចរបស់ចាមក្នុងកម្ពុជា ជាទូទៅត្រូវបានយល់ថាស្ថិតក្នុងថ្នាក់ទាបបំផុតនៃសង្គមខ្មែរ ។ ពួកគេត្រូវបានគេចាត់ទុកថាជា អ្នកក្រពុំសូវមានតម្លៃ តែការជាពិតទៅ ពួកគេពេញចិត្តនឹងការដាក់បញ្ចូល និងសេរីភាពក្នុងការប្រតិបត្តិសាសនា ។ ភ័ស្តុតាងទាក់ទងនឹងការរើសអើងពូជសាសន៍ពីសំណាក់ជនជាតិខ្មែរក៏ពុំសូវមានដែរ ។ ទីពីរគឺប្រវត្តិជាប្រជាជនដែលគ្មានប្រទេសរបស់ជនជាតិចាម ធ្វើឲ្យពួកគេមើលទៅដូចជាមានភាពងាយស្រួលក្នុងការទទួលឥទ្ធិពលអាក្រក់របស់សាសនាអ៊ីស្លាម ។ ការសិក្សាពីប្រវត្តិសាស្ត្រចាមបានបង្ហាញថាជនជាតិចាមបានទទួលការស្វាគមន៍យ៉ាងកក់ក្តៅពីរាជរដ្ឋាភិបាលខ្មែរ ចាប់តាំងពីការមកដល់របស់ពួកគេជាលើកដំបូងនាសតវត្សទី១៥ ។ ចាមមិនដែលត្រូវបានគេចោទប្រកាន់ជាអ្នកធ្វើឲ្យមានការធ្លាក់អន់ខ្សោយនៃប្រទេសកម្ពុជានោះទេ ។ ជនជាតិចាមបានកសាងអត្តសញ្ញាណនយោបាយមួយ ដែលមានភាពស្មោះត្រង់ និងគាំទ្រអ្នកដឹកនាំខ្មែរ ។ ទីបីគឺការអវត្តមាននៃការអប់រំរបស់ជនជាតិចាម ដោយសារតែការបដិសេធមិនព្រមបញ្ជូនកូនចៅទៅសាលាអប់រំបែបវិទ្យាសាស្ត្រ ហើយកត្តានេះបានបណ្តាលឲ្យជនជាតិងាយស្រួលនឹងទទួលឥទ្ធិពលពីអំពើភេរវកម្ម ប៉ុន្តែការអះអាងបែបនេះមិនមែនជាការពិតនោះទេ ។ ទោះបីជាឪពុកម្តាយចាមមួយចំនួនបញ្ជូនកូនទៅរៀន ត្រឹមតែសាលាសាសនាកម្រិតនៃការអប់រំរបស់ជនជាតិចាមស្រដៀងគ្នាទៅនឹងជនជាតិខ្មែរដែរ ។ ទីបួនគឺការយល់ឃើញរបស់មនុស្សមួយចំនួនចំពោះបទពិសោធន៍របស់ចាមក្នុងរបបខ្មែរក្រហមថាបានបង្កើតបានជាការខឹងសម្បារជាមួយរាជរដ្ឋាភិបាលខ្មែរ និងប្រជាជនខ្មែរទាំងមូល ។ ផ្ទុយទៅវិញ ចាមបានប្រើប្រាស់បទពិសោធន៍ក្រោមរបបខ្មែរក្រហម ដើម្បីបង្កើតអត្តសញ្ញាណរបស់ខ្លួនរួមមួយជាមួយជនជាតិខ្មែរ ដោយប្រើប្រាស់អត្តសញ្ញាណជាជនរងគ្រោះដូចគ្នា ។

ប៉ុន្តែ របៀបដែលចាមប្រើប្រាស់សម្រាប់កសាងអត្តសញ្ញាណជាយរបស់ខ្លួនឯងឡើងវិញ បានភ្ជាប់ពួកគេទៅនឹងអំពើភេរវកម្មអ៊ីស្លាម ។ ការជាប់ពាក់ព័ន្ធកើតឡើង ដោយសារតែការទំនាក់ទំនងគ្មានរបៀបរៀបរយរបស់ចាមជាមួយក្រុមមូស្លីម ការស្រោចស្រង់សាសនារបស់ចាម ដែលនាំមកនូវមូលដ្ឋានគ្រឹះសាសនាអ៊ីស្លាមបែបនិយមជ្រុលចូលមកក្នុងកម្ពុជាការធ្វើទំនាក់ទំនងឆ្លងប្រទេសជាមួយមូស្លីមដទៃទៀតតម្រូវការនៃការអប់រំ និងជំនួយ រួមទាំងការស្វែងរកការគាំទ្រជាសកល ពីព្រោះជំនួយនៅក្នុងតំបន់នៅមានកម្រិតនៅឡើយ ទោះបីជាមានការអត់ឱន ការផ្តល់សេរីភាពក្នុងការប្រណិប័តន៍សាសនា និងការអនុញ្ញាតឲ្យចូលរួមក្នុងឆាកនយោបាយពីសំណាក់រាជរដ្ឋាភិបាលក៏ដោយ ។ លើសពីនេះទៅទៀត ការមិនផ្សព្វផ្សាយជំនឿសាសនារបស់ខ្លួនក្នុងសង្គមខ្មែរ និងការមិនចូលរួមនៅក្នុងសង្គមខ្មែររបស់ខ្មែរមូស្លីមក៏ជាបញ្ហាចោទដែរ ។ ក្រុមនិកាយមួយចំនួន ជាពិសេសក្រុមដាក់វ៉ះ មិនចូលរួមរាល់ការពិភាក្សាជាសាធារណៈជាមួយនឹងក្រុមនិកាយផ្សេងៗទៀត និងសាធារណជនខ្មែរ ។

សំណួរចុងក្រោយគឺថា តើករណីរបស់ហាំបាលីគឺជាការភាន់ច្រឡំឬទេ? ចម្លើយគឺមែនហើយ ការចោទប្រកាន់នេះគឺជាការភាន់ច្រឡំ ពីព្រោះជនជាតិចាមពុំមានបំណងទាក់ទងជាមួយហាំបាលីនោះទេ ។ ជនជាតិចាមមិនត្រូវបានធ្វើវិវឌ្ឍនិយម ទោះបីជាក្រុមមួយចំនួនក្នុងជនជាតិចាមបានក្លាយទៅជាអ្នកកាន់សាសនាយ៉ាងខ្ជាប់ខ្ជួនហួសហេតុ ។ **អេង កុកថាយ**

# សាក្សីធ្វើសក្ខីកម្មអំពីលើការបោសសម្អាតផ្ទៃក្នុង «គ្រប់គ្នា ខ្លាចគ្នាទៅវិញទៅមក»

បន្ទាប់ពីការឈប់សម្រាកអស់រយៈពេលជាង៥បីសប្តាហ៍មក អង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានបន្តសវនាការរបស់ខ្លួន និងបានស្តាប់សក្ខីកម្មសាក្សី 2-TCW-1005 ទាក់ទងនឹងការធ្វើបន្សុទ្ធកម្មផ្ទៃក្នុង ។ សហព្រះរាជអាជ្ញាបានចាប់ផ្តើមសួរដេញដោលសាក្សីរូបនេះអំពីវចនសម្ព័ន្ធគ្រប់គ្រង និងការចាប់ខ្លួន រួមទាំងអត្តន័យទង់បដិវត្តន៍ ។ សាក្សីរូបនេះ ដែលបានស្ថិតក្រោមការណែនាំការពារ ដោយសហចៅក្រមស៊ើបអង្កេត និងដូច្នេះហើយ ត្រូវបានប្រើឈ្មោះក្លែងក្លាយរបស់ខ្លួន បានធ្វើការជានីសារនៅក្នុងរបបខ្មែរក្រហម និងបានលើកឡើងអំពីបរិយាកាសនៃការមិនទុកចិត្តគ្នាក្នុងចំណោមកម្មាភិបាល ។

**បញ្ហាបឋម**

លោកប្រធានអង្គជំនុំជម្រះបានប្រកាសថា សក្ខីកម្មរបស់សាក្សី 2-CTW-1005 ត្រូវបានអង្គជំនុំជម្រះស្តាប់ឮ ។ លោកចៅក្រម យូ ឧត្តរា បានអវត្តមាន ដោយមូលហេតុផ្ទាល់ខ្លួន ហើយត្រូវបានជំនួសដោយ ចៅក្រម ធូ មុន្នី ។ គ្រប់ភាគីទាំងអស់មានវត្តមាន ។

មុនពេលចាប់ផ្តើមសក្ខីកម្មរបស់សាក្សី 2-CTW-1005 ការឆ្លើយតបទៅនឹងសំណើរបស់សហព្រះអាជ្ញាលេខ E319/48/1 និងសំណើរបស់ក្រុមមេធាវីការពារក្តី នួន ជា ស្នើឲ្យទទួលយកឯកសារមួយចំនួនត្រូវបានធ្វើឡើងនៅក្នុងអង្គជំនុំជម្រះ ។ គ្មានការជំទាស់ត្រូវបានលើកឡើង ដោយភាគីណាមួយឡើយ ប៉ុន្តែមេធាវីការពារក្តីឲ្យ ខៀវ សំផន លោកស្រី អានតា ហ្គីហ្សេ បានលើកឡើងថា លោកស្រីមិនអាចធ្វើការពន្យល់ទៅលើឯកសារនេះទេ ។ លោកសហព្រះរាជអាជ្ញាអន្តរជាតិ លោក វីល្លៀម ស្មីត បានស្នើសុំឲ្យដាក់អ៊ីទាំងអស់នេះអាចធ្វើទៅបានចំពោះក្រុមមេធាវីការពារក្តី ។

ដើម្បីការពារសាក្សី លោកប្រធានអង្គជំនុំជម្រះបានផ្តល់ការណែនាំឲ្យភាគីទាំងអស់ប្រើឈ្មោះក្លែងក្លាយរបស់សាក្សី ។ សាក្សីមិនអាចអានអក្សរបានទេ ដោយសារតែបញ្ហាភ្នែករបស់ខ្លួនក្នុងការបញ្ជាក់អត្តសញ្ញាណ ។ មេធាវី បានអានឯកសារ ដែលក្រោយ



សាក្សី រៀល សន ផ្តល់សក្ខីកម្មនៅមុខសាលាដំបូង នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ក្នុងសំណុំរឿង០០២/២ប្រឆាំងនឹងជនជាប់ចោទ នួន ជា និង ខៀវ សំផន (រូបថត ៖ អ.វ.ត.ត.ក)

មកត្រូវបានបញ្ជាក់ ឲ្យសាក្សីស្ដាប់ ។ បន្ទាប់មក តួនាទីត្រូវបានប្រគល់ឲ្យសហព្រះរាជអាជ្ញា ។

**ការចូលបដិវត្តន៍**

លោក ស្មិត បានសាកសួរទីកន្លែងកំណើតរបស់សាក្សី និងថាតើសាក្សីមានស្រុកកំណើតនៅត្រាំកក់ នៅតំបន់១៣ ។ សាក្សីបានបញ្ជាក់ថាដូច្នេះ ។ គាត់ក៏បានបញ្ជាក់បន្ថែមទៀតថា គាត់ត្រូវបានផ្ដល់ឱកាសឲ្យអានបទសម្ភាសន៍ដែលត្រូវបានធ្វើឡើងជាមួយគាត់ ដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ។

សាក្សី បានចូលរួមជាមួយខ្មែរក្រហមនៅថ្ងៃទី១៥ ខែមីនា ឆ្នាំ១៩៧៣ ។ គាត់អាចចាំកាលបរិច្ឆេទនេះបានច្បាស់ ពីព្រោះប្រវត្តិរូបរបស់គាត់ត្រូវបានធ្វើឡើងនៅពេលនោះ ។ សាក្សីអាចរំឭកសាច់រឿងនៅក្នុងប្រវត្តិរូបនេះ ។ បន្ទាប់ពីបានរស់នៅក្នុងព្រៃអស់រយៈកាល៣-៤ខែនៅជិតភ្នំមួយ ប្រវត្តិរូបរបស់គាត់ត្រូវបានធ្វើឡើង ។ គាត់ឈរជើងនៅអង្គរជ័យទី១ នៅក្នុងមន្ទីរ១០៦ ដែលជាមន្ទីរនីសារបស់តំបន់១៣ ។ តំបន់១៣នេះ ស្ថិតនៅក្នុងភូមិភាគនិរតី ។ មានតំបន់៤នៅក្នុងភូមិភាគនិរតីនេះ ។

បន្ទាប់មកលោក វីល្លៀម ស្មិត បានដំណើរការសាកសួរអំពីម្ដាយរបស់សាក្សីវិញម្ដង ។ សាក្សីបានពន្យល់ថា ម្ដាយរបស់គាត់បានចូលបដិវត្តន៍ នៅពេលគាត់នៅក្នុងភូមិកំណើត ។ ក្រោយឆ្នាំ១៩៧៥ ម្ដាយរបស់គាត់បានរស់នៅជាមួយគ្រួសារនៅគិរីវង្ស និងបានធ្វើការនៅក្នុងមន្ទីរ១៥០ ។

មន្ទីរ១០៥ ជាមន្ទីររបស់តំបន់ ផ្អែកតាមការយល់ដឹងរបស់សាក្សី ។ បន្ទាប់ពីធ្វើការនៅក្នុងមន្ទីរនេះ "សមមិត្តនារីអាចផ្លាស់ទៅធ្វើការនៅតំបន់ផ្សេងៗ ដើម្បីដឹកជញ្ជូនអ្នករងរបួស" ។ ស្ត្រីទាំងនោះក៏ត្រូវដឹកជញ្ជូនតាមកាណូត ដែលការងារនេះជាការចាត់តាំងរបស់កម្មាភិបាលថ្នាក់ស្រុក ។

**ទំនាក់ទំនងក្រុមគ្រួសារទៅកាន់កម្មាភិបាលជាន់ខ្ពស់**

បន្ទាប់ពីសាកសួរបន្ថែមពីក្រុមគ្រួសាររបស់សាក្សី លោក វីល្លៀម ស្មិត ចង់ដឹងថាតើឪពុករបស់គាត់(សាក្សី) បានស្លាប់ដោយរបៀបណា នៅឆ្នាំ១៩៧៦ ខណៈដែលគាត់បានបង្ហាញនៅក្នុងសេចក្ដីបញ្ជាក់បន្ថែមរបស់គាត់ ។ សាក្សី បានឆ្លើយថា ឪពុកគាត់បានចូលចលនាបក្សកុម្មុយនីស្តកម្ពុជា ហើយបានឮថា គាត់ (ឪពុកសាក្សី) ត្រូវបានចាប់ខ្លួន ។ ប៉ុន្តែសាក្សីមិនអាចរំឭកពីហេតុការណ៍នេះបានទេ ។ ឪពុកសាក្សី បានទៅដល់ភ្នំឱរ៉ាល់ ប៉ុន្តែសាក្សីមិនបានដឹងពីព័ត៌មានលម្អិតនៃការចាប់ខ្លួនឪពុកឡើយ ។ លោក ស្មិត ចង់ដឹងថា តើឪពុកគាត់ (សាក្សី) បានស្គាល់ សុន សេន ទេ ។ សាក្សីបានឆ្លើយថា "អ្នកទាំងពីរប្រហែលជាមិត្តភក្តិ តាំងពីចូលរួមចលនាតស៊ូជាមួយគ្នា ។ ក្រោយមក សុន សេន បានមានទំនាក់ទំនងជាមួយខ្ញុំរហូតដល់គាត់ (ឪពុកសាក្សី) ស្លាប់ ។

លោក វីល្លៀម ស្មិត អានការដកស្រង់ចេញពីបទសម្ភាសន៍របស់សាក្សី ដែលបានលើកឡើងថា គាត់មានជីវិតរស់សព្វថ្ងៃនេះ ពីព្រោះឪពុករបស់គាត់មាន "ទំនាក់ទំនងល្អ" ។ សាក្សីបានឆ្លើយថា "សុន សេន មានទំនាក់ទំនងជាមួយឪពុកខ្ញុំ" ហើយបន្ទាប់ពីខ្ញុំគ្មានឪពុកទៀត ខ្ញុំត្រូវបានសួរនាំពីប្រវត្តិរូបខ្ញុំ ហើយ សុន សេន បានចាប់ផ្ដើមដឹងថា "ខ្ញុំជាកូនរបស់ឪពុកខ្ញុំ ដូច្នេះខ្ញុំមានទំនាក់ទំនងជាមួយគាត់ (សុន សេន)" ។

សាក្សីបាននិយាយថា គាត់បានស្ម័គ្រចិត្តចូលចលនាបដិវត្តន៍ដោយមិនមានការបង្ខិតបង្ខំឡើយ ។ នៅពេលនោះ សាក្សីគឺជាក្មេងជំទង់ ។ គ្រូរបស់គាត់ នៅអង្គតាសោម បានចូលរួមបាតុកម្ម ប៉ុន្តែក្រោយមកត្រូវបានបាញ់ស្លាប់ ។ គាត់ (គ្រូរបស់សាក្សី) បានសម្រេចចិត្តចូលរួមបដិវត្តន៍ដើម្បីប្រយុទ្ធប្រឆាំងនឹងរបប លន់ នល់ ពីព្រោះតែអ៊ីចឹងហើយបានចូលរួមជាមួយមនុស្សចាស់ៗ ។ នៅក្នុងតំបន់១៣ មន្ទីរ១០៥ និងមន្ទីរ១៦០ ដែលជាអតីតមន្ទីរសម្រាប់ស្ត្រី ។ ចំណែកឯសាក្សីនៅក្នុងមន្ទីរ១៦០ ។ សាក្សី បានរំឭកថា តំបន់១៣ មានបែងចែកជា ស្រុកអង្គរជ័យ, ស្រុកត្រាំកក់, ស្រុកទ្រាំង, ស្រុកព្រៃកប្បាស, ស្រុកសំរោង និងស្រុកផ្សេងៗទៀត ។ លោក ស្មិត បានសួរថាតើស្រុកគីរីវង្ស ស្ថិតនៅក្នុងតំបន់១៣ ដែលសាក្សីបានបញ្ជាក់មុនហ្នឹង ។ វាស្ថិតនៅក្នុងស្រុក១០៩ នៃតំបន់១៣ ។

**ការងារជានីរសារ**

សាក្សី ធ្លាប់ធ្វើជានីរសារទៅតាមកាលវិភាគប្ដូរវេនគ្នា ។ ដូច្នេះ នីរសារមិននៅទីតាំងមួយកន្លែងនោះទេ ។ លោក ស្មិត បានសួរថាតើវាត្រឹមត្រូវដែរឬទេ ដែលថាគាត់ (សាក្សី) ជានីរសារមន្ទីរ១៦០ រហូតដល់ខែកញ្ញា ឆ្នាំ១៩៧៥ ហើយលោក ស្មិត ក៏ចង់ដឹង

ថាតើវាត្រឹមត្រូវទេ ដែលថាគាត់ធ្វើជានីរសាររអស់រយៈកាលពីរឆ្នាំកន្លះ ។ សាក្សី បានអះអាងត្រង់ចំណុចនេះ ។ ជាការពិត ត្រឹមត្រូវដូចការនិយាយខាងដើមមក ។ នៅក្នុងរយៈពេលពីរឆ្នាំហ្នឹង គាត់ស្ថិតនៅក្នុងតំបន់អង្គរជ័យដល់ក្រោយមកគាត់ត្រូវបានផ្លាស់កន្លែងផ្សេងទៀតនៃតំបន់អង្គរជ័យហ្នឹងដែរ ។ លោក ស្មីត បានសួរថាតើសាក្សីត្រូវបានផ្លាស់ទៅស្រុកគិរីវង្ស នៅខែមីនា ឆ្នាំ១៩៧៧ ។ សាក្សីកែតម្រូវដំណើររឿងនេះ ហើយបាននិយាយថា គាត់ក្រោយមកបានទៅក្រចេះ ។ គាត់បានផ្លាស់ទៅគិរីវង្សនៅខែកញ្ញា ឆ្នាំ១៩៧៥ ។

លោក ស្មីត ចង់ដឹងថាតើវាត្រឹមត្រូវទេ ដែលសាក្សីទៅនៅក្នុងស្រុកគិរីវង្ស ចាប់ពីខែកញ្ញា ឆ្នាំ១៩៧៥ រហូតដល់ខែមីនា ឆ្នាំ១៩៧៧ ។ សាក្សី បានឆ្លើយថា បើគាត់បាននិយាយអ៊ីចឹងនៅក្នុងសេចក្តីបញ្ជាក់របស់ខ្លួន ប្រាកដជាត្រឹមត្រូវហើយ ។

## រចនាសម្ព័ន្ធគ្រប់គ្រង

ងាកទៅមើលរចនាសម្ព័ន្ធគ្រប់គ្រងតំបន់ លោក ស្មីត បានសាកសួរថាតើអ្នកណាគ្រប់គ្រងតំបន់១៣ នៅពេលសាក្សីស្ថិតនៅក្នុងអង្គរជ័យ ។ សាក្សីបានឆ្លើយថា ឈ្មោះ សោម ជាប្រធានតំបន់១៣ ហើយឈ្មោះ ភឿ ពើម ជាអនុប្រធាន ។

លោក ស្មីត បានលើឡើងថា សាក្សីបាននិយាយអំពីតា មុត នៅក្នុងតំបន់១៣ ហើយបានសួរតើគាត់(តាមុត) មានតួនាទីអ្វីនៅក្នុងតំបន់នោះ? សាក្សីបានរៀបរាប់ថា ក្រោយមក គាត់បានផ្លាស់ទៅកងពលធំលេខ៣ ។

លោក ស្មីត បានសួរបន្ថែមទៀតថាតើមន្ទីររបស់សាក្សីស្ថិតនៅក្នុងស្រុកអង្គរជ័យនៅក្នុងឆ្នាំ១៩៧៥ សាក្សី បានឆ្លើយថា ពេលនោះគាត់បានផ្លាស់ទៅដីរមាស ហើយក្រោយមកបានផ្លាស់ទៅនៅក្បែរផ្លូវជាតិជិតស្រុកអង្គជ័យ ។ សាក្សីមិនអាចរំឭកដំណើររឿងទាំងអស់ នៅពេលរត់សំបុត្របានទេ ។ លោក ស្មីត បានសួរថាតើ តា សោម ជាលេខាតំបន់១៣នេះ ធ្លាប់បានផ្លាស់ចេញទេនៅពេលសាក្សីប្រចាំការនៅទីនោះ? សាក្សី បានលើកឡើងថា តា សោម ពេលហ្នឹងអត់មាន ព្រោះតា មុត គាត់ចេញទៅ មានតែតា សោម ។ ដល់ក្រោយមក ទើបប្តូរ តា សោម ។

«តាមអ្វីដែលខ្ញុំដឹង តាសោម ធ្លាក់ខ្លួនឈឺ ហើយត្រូវបានចាត់តាំងជាថ្មីឲ្យទៅភ្នំពេញ»

លោក ស្មីត បានសួរថាតើវាត្រឹមត្រូវដែរឬទេ ដែលថាតា សោម ក្រោយមកត្រូវបានជំនួសដោយតាជឿន ។ សាក្សី បានឆ្លើយថា គាត់មិនស្គាល់ឈ្មោះនេះទេ ។ លោក ស្មីត បានកែតម្រូវការអាន ហើយបានសួរថាតើសាក្សីស្គាល់ឈ្មោះ ជឿន ទេ និងបានអានឮៗ នូវសេចក្តីដកស្រង់ ដែលសំដៅទៅលើបុគ្គលម្នាក់នេះ ។ សេចក្តីដកស្រង់នេះបាននិយាយពីការចាប់ខ្លួនកម្មាភិបាល ។ សាក្សីបានបញ្ជាក់ពីចំណុចនេះ និងបាននិយាយថាបុគ្គលនេះត្រូវបានហៅ ជឿន ។ សាក្សីបានលើកឡើងថា បុគ្គលនេះបានឡើងជំនួសសោម និងបានធ្វើការជាមួយ វ៉ន វ៉េត ។

លោក ស្មីត បានលើកយកឯកសារមួយទាក់ទងអ្នកទោសដែលត្រូវបានឃុំខ្លួននៅមន្ទីរស-២១ ។ មុនពេលលើកបញ្ចាំងឯកសារនេះ ចំពោះសាក្សី លោក ស្មីត បានសួរថាតើសាក្សីធ្លាប់បានឮឈ្មោះមន្ទីរនេះទេ ។ សាក្សីបានបញ្ជាក់ត្រង់ចំណុចនេះ និងបាននិយាយថាធ្លាប់ឮពីមន្ទីរនេះដែរនៅក្នុងរបបខ្មែរក្រហម ។ គាត់ (សាក្សី) គ្រាន់តែដឹងថា នៅពេលនោះមន្ទីរស-២១ ជាមន្ទីររបស់រដ្ឋ និងបានបញ្ជាក់ថា មានតែកម្មាភិបាលថ្នាក់លើទេ ដែលបានជាប់ឃុំឃាំងនៅក្នុងមន្ទីរនេះ ហើយមិនមែនសម្រាប់ដាក់ឃុំកម្មាភិបាលថ្នាក់ក្រោមទេ ។ បន្ទាប់ពីរបបខ្មែរក្រហមដួលរលំ ទើបគាត់ (សាក្សី) បានដឹងថា បងប្អូនគាត់មួយចំនួនត្រូវបានជាប់ឃុំ និងស្លាប់នៅមន្ទីរស-២១ ខុទាហរណ៍ដូចជាពូរបស់គាត់ ។

## ភារកិច្ចនៅទីតាំងផ្សេងៗ

បន្ទាប់ពីសម្រាក លោកប្រធានអង្គជំនុំជម្រះបានប្រកាសថាអង្គជំនុំជម្រះមិនអាចចេញសេចក្តីសម្រេចលើសំណើសុំរបស់សហព្រះរាជអាជ្ញាអំពីឯកសារដោយផ្ទាល់របស់ក្រុមការពារក្តី នួន ជា លើសំណើសុំនេះបានទេ ។

លោក ស្មីត បានមកបន្តការសាកសួររបស់ខ្លួន ។ សហព្រះរាជអាជ្ញារងអន្តរជាតិបានលើកឡើងថា សាក្សី បាននិយាយមុននេះថា ខ្លួននៅស្រុកគិរីវង្ស រហូតដល់ខែមីនា ឆ្នាំ១៩៧៧ ហើយក្រោយមកទៅនៅខេត្តក្រចេះ ។ សហព្រះរាជអាជ្ញារងអន្តរជាតិ ក៏បានសួរអំពីការចាប់ខ្លួន តាសោម និងការចាប់ខ្លួនបន្តបន្ទាប់ទៀត នៅក្នុងតំបន់១៣ ដែលសាក្សីបានលើកឡើងនៅក្នុងសេចក្តីបញ្ជាក់របស់ខ្លួន ។ តើការចាប់ខ្លួននេះបានកើតឡើងនៅក្នុងឆ្នាំ១៩៧៧ឬ

ទេ? សាក្សី បានបញ្ជាក់ពីរឿងនេះ ពិតហើយ ។

«បន្ទាប់ពីខ្ញុំបានផ្លាស់ទៅខេត្តក្រចេះ សមាជិកនៃគណៈតំបន់ត្រូវបានគេចាប់ខ្លួន ។ មានការចាប់ខ្លួនជាបន្តបន្ទាប់»

បន្ទាប់មក លោក ស្មីត បានសួរថាតើ តា សោម ត្រូវបានចាប់ខ្លួនដោយសារតែជាប់ខ្សែខាងប្ដីរបស់យាយ យុត មែនដែរឬទេ ។ សាក្សី បានរំឭកថា តា សោម ត្រូវបានចាប់ខ្លួន បន្ទាប់ពីត្រូវបានផ្លាស់ទៅភ្នំពេញ ។ «តាមការពិត គាត់ (តា សោម) មិនត្រូវបានចាប់ខ្លួននៅក្នុងមូលដ្ឋានរបស់គាត់ទេ» តាម សោម មកពីភូមិភាគបូព៌ា ។ សាក្សី ក៏បានបន្ថែមទៀតថា យាយ យុត ឈ្មោះពេញ ប្រាក់ យុត ។ គាត់ត្រូវបានផ្លាស់ពីកំពតទៅកំពង់ចាម ។ ក្រោយមកយាយ យុត បានធ្វើជាអនុលេខាតំបន់កំពង់សៀម ។ នៅចុងឆ្នាំ ១៩៧៨ ប្ដីគាត់ (ប្ដីយាយ យុត) ត្រូវបានចាប់ខ្លួន និងត្រូវបញ្ជូនទៅភូមិភាគកណ្ដាល ។ មុនពេលកងទ័ពវៀតណាមមកដល់យាយ យុត ត្រូវបានផ្លាស់ទៅបាត់ដំបងបន្តទៀត ។ ប្ដីគាត់ត្រូវបានចាប់ខ្លួនដោយសារតែមានអ្នកនិយាយថា ប្ដីគាត់ជាអតីតនិស្សិត និងមានជាប់ពាក់ពន្ធ័ជាមួយភ្នាក់ងារ កា.ហ្សេ.បេ តាំងពីគាត់មកពីភូមិភាគបូព៌ាម្ល៉េះ ។ គាត់ត្រូវបានចាប់ខ្លួន និងកម្ទេចចោល បន្ទាប់ពីត្រូវបានផ្លាស់ទៅកំពត ។ ការសម្លាប់នេះ«ប្រហែលជាចុងឆ្នាំ១៩៧៨» មានការនិយាយថា តា សោម មានជំងឺសួត ហើយត្រូវបានបញ្ជូនទៅភ្នំពេញ ។ គាត់ត្រូវបានចាត់តាំងឲ្យទៅនៅក្រសួងការបរទេស ប៉ុន្តែក្រោយមក គាត់ត្រូវបានបញ្ឈប់ពីតំណែង ។ «គាត់ត្រូវបានសង្ស័យថា ជាប់ពាក់ព័ន្ធនឹងសកម្មភាពក្បត់»

លោក ស្មីត បានបង្ហាញពីបញ្ជីឈ្មោះអ្នកទោសមួយ ។ បញ្ជីនេះបានបង្ហាញឈ្មោះ សោម ជឿន ។ ពេលដែលឈ្មោះនោះបានបង្ហាញនៅលើកញ្ចក់កុំព្យូទ័រ ។ លោក កូប៉េ បានជំទាស់ ហើយនិយាយថា ឯកសារនេះមិនមែនជាឯកសារដែលមានស្រាប់ទេ ។ លើសពីនេះទៅទៀត សាក្សីបាននិយាយនៅក្នុងបទសម្ភាសន៍ថាគាត់នៅរស់រហូតដល់សព្វថ្ងៃនេះ ។ លោក ស្មីត និយាយថា ខាងភាគីសហមេធាវីជនជាប់ចោទកំពុងតែប្រើយុទ្ធសាស្ត្រនេះនៅក្នុងឱកាសជាច្រើន ។ គាត់បានចង់ដឹងបញ្ជាក់ថាតើ សោម ជឿន សំដៅទៅលើបុគ្គលម្នាក់ ឬពីរនាក់ដែលផ្សេងគ្នាដូចបានរៀបរាប់ខាងលើមក ។ បន្ទាប់ពីសង្ខេបទៅលើសេចក្ដីបញ្ជាក់នោះ លោកប្រធានអង្គជំនុំជម្រះបាននិយាយថា ការជំទាស់នេះ អត់មានប្រសិទ្ធភាព ។ នៅក្នុងបញ្ជីឈ្មោះនេះ បានបង្ហាញថាគាត់ជាអនុលេខាស្រុកអង្គរជ័យនឹងស្រុកទ្រាំង មុនពេលគាត់ទៅកាន់តួនាទីនៅតំបន់១៣ ភូមិភាគនិរតី និងបន្ទាប់មកកាន់មន្ទីរសេដ្ឋកិច្ច មុនពេលគាត់ត្រូវបានចាប់ខ្លួន ។ វាបានបង្ហាញថា គាត់ត្រូវបានសម្លាប់នៅថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៧៨ ។

សាក្សីបានបញ្ជាក់ថា នេះជាបុគ្គលឈ្មោះតា សោម ដែលគាត់ (សាក្សី) បានលើកបង្ហាញពីមុនមក ។ គាត់បានឮថា សោម ត្រូវបានចាប់ខ្លួន ដោយសារតែគាត់មាន«ជាប់ពាក់ព័ន្ធខ្សែក្បត់» វន វ៉ែត ត្រូវបានចាប់ខ្លួន បន្ទាប់ពីគ្រឿងម៉ាស៊ីនមួយនៅក្នុងរោងចក្របានខូច ។

បន្ទាប់មកលោក ស្មីត បានសួរថាហេតុអ្វីបានជាសាក្សីចាកចេញពីអង្គរជ័យទៅនៅគិរីវង្ស ។ នៅគិរីវង្សមាននីរសារប្រហែលពី២០ ទៅ៣០នាក់ ។ សាក្សី បានបញ្ជាក់ថា គាត់ត្រូវបានបញ្ជូនឲ្យទៅធ្វើជានីរសារ ពីព្រោះគាត់មានបទពិសោធខាងហ្នឹង ។ លោក ស្មីត បានសួរពីតួនាទីរបស់ តា គុម ហើយនឹងតា ទិត នៅក្នុងស្រុកគិរីវង្ស ។ សាក្សីបានឆ្លើយថា តា ទិត ជាសមាជិកគណៈស្រុកគិរីវង្ស ប៉ុន្តែគាត់ក៏មានជាប់ពាក់ព័ន្ធជាមួយតំបន់ដែរ ។ គាត់ (តា ទិត) បានចូលរួមប្រជុំនៅថ្នាក់ស្រុក និងបានអង្គុយនៅក្បែរតា សោម ។ តាទិត ជាកម្មាភិបាលថ្នាក់ខ្ពស់ បើប្រៀបធៀបជាមួយហ្នឹង តា គុម ។ មន្ទីររបស់សាក្សី កាលពីមុនហ្នឹងស្ថិតនៅភូមិស្លា ដែលនៅជិតព្រំដែនវៀតណាម ដែលស្ថិតនៅក្នុងស្រុកតែមួយ តែវានៅដាច់ពីគ្នា ។ គាត់បានប៉ាន់ស្មានមានចម្ងាយប្រមាណ១៥គីឡូម៉ែត្រ ។ មន្ទីររបស់តាគុម គឺនៅពោធិ៍ព្រឹក្ស ចំណែកឯមន្ទីរតាទិតនៅកន្លែងផ្សេង ប្រហែលជារំលង២ឃុំ ដែលស្ថិតនៅចន្លោះពីមន្ទីររបស់អ្នកទាំងពីរ និងមន្ទីររបស់សាក្សី ។ មានឃុំសង្កាត់មួយចំនួននៅចន្លោះមន្ទីរសាក្សី និងមន្ទីរតាទិត និងតា គុម ។ សាក្សី បានប៉ាន់ប្រមាណថា ចម្ងាយរវាងភូមិស្លា និងមន្ទីររបស់អ្នកទាំងពីរនេះគឺ «មានចម្ងាយជិតចជាង ២០គីឡូម៉ែត្រ»

## សត្រូវរបស់បក្សកុម្មុយនីស្តកម្ពុជា

បន្ទាប់មកទៀតលោក ស្មីត បានចូលទៅប្រធានបទបន្ទាប់របស់ខ្លួន ។ ស្មីត បានសួរអំពីការប្រជុំដែលសត្រូវបក្សកុម្មុយនីស្តកម្ពុជានៅក្នុងសេចក្ដីដកស្រង់ត្រូវបានពិភាក្សា និងអាន ។ សាក្សីបាន

រៀបរាប់ថា អ្នកទាំងនោះពិភាក្សាគ្នាពីភ្នាក់ងារ “កា.ហ្វេ.បេ ហើយនឹងភ្នាក់ងារ សេ.អ៊ី.អា” ប៉ុន្តែមិនបានលើកពីការអត់ឃ្លានរបស់ប្រជាជនទេ ស្មីត បានសួរអំពីការបោសសំអាតភ្នាក់ងារ កា.ហ្វេ.បេ និងសេ.អ៊ី.អា ។ បញ្ហានេះមិនត្រូវបានលើកឡើងជាញឹកញាប់នៅក្នុងអង្គប្រជុំកងទ័ពទេ តាំងពីការប្រជុំទាំងនេះផ្តោតទៅលើយុទ្ធសាស្ត្រការពារព្រំដែន ។ លោក ស្មីត បានសួរថា ហេតុអ្វីបានជាសាក្សីត្រូវបានបង្រៀនអំពីអត្ថន័យនៃទង់បដិវត្តន៍នៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ។ សាក្សីបាននិយាយថា កម្មាភិបាលជាន់ខ្ពស់បានប្រើប្រាស់ទស្សនាវដ្តី ដើម្បីបង្រៀនក្នុងវគ្គសិក្សាដល់កងទ័ពទាំងនោះនៅក្នុងអំឡុងឆ្នាំ១៩៧៧ ។

“វាគ្រាន់តែជាការណែនាំតឹងរ៉ឹងតែប៉ុណ្ណោះ ដែលថាគ្មានអ្នកណាជឿជាក់លើគ្នាទៅវិញទៅមកនោះទេ” មនុស្សមានការភ័យខ្លាចចំពោះអត្ថន័យទង់បដិវត្តន៍ ។ “យើងគួរតែហ៊ានលះបង់ខ្លួនរបស់យើងដើម្បីបក្ស” សាក្សីបានពន្យល់ថា ការហ៊ានលះបង់នេះគឺពីព្រោះតែអត្ថន័យនៃទង់បដិវត្តន៍ និងដើម្បីបក្សតែមួយ ។ “គ្រប់គ្នាមានការភ័យខ្លាចគ្នាទៅវិញទៅមក គ្រប់គ្នាមិនមានការទុកចិត្តគ្នាទៅវិញទៅមក” គាត់ (សាក្សី) ជាយុវជនជំនាន់ក្រោយរបស់បក្ស ពីព្រោះទើបតែក្លាយជាសមាជិកបក្សនៅអាយុ២៥ឆ្នាំ នៅពេលគាត់មានអាយុ១៩ឆ្នាំ ។

លោក ស្មីត ចង់ដឹងពីអ្វីដែលសាក្សីយល់ឃើញពីអត្ថន័យរបស់ទស្សនាវដ្តីនោះ ពេលដែលទស្សនាវដ្តីបានលើកឡើងថា “យើងនឹងមិនអត់ឱនឲ្យអ្នកណាទាំងអស់ ដែលធ្វើប្រព្រឹត្តខុសឆ្គងចំពោះវិន័យ នៃបក្ស” សាក្សីបានបកស្រាយលើបញ្ហានេះ ដោយលើឡើងថា អង្គការត្រូវតែកម្ចាត់រាល់សត្រូវទាំងអស់ចោល ។ អ្នកខ្លះមិនមានជំហរដាច់ខាតនៅការធ្វើបន្សុទ្ធកម្មនេះទេ ។ នៅពេលលោក ស្មីត បានបានសួរថាតើ គាត់ (សាក្សី) បានមានន័យថា តើអ្នកទាំងនោះ “មិនត្រូវបានត្រៀមខ្លួនរួចជាស្រេច ដើម្បីសម្លាប់អ្នកដទៃ” លោក កូប៉េ បានជំទាស់ ហើយនិយាយថា នេះជាសំណួរនាំមុខ ពីព្រោះជាទូទៅ “ការធ្វើបន្សុទ្ធកម្ម ដែលយើងបានបង្កើតមិនមែនជាការសម្លាប់ទេ” តែវាមានន័យថា “ការអប់រំ” លោក ស្មីត រៀបចំតាំងសំណួរសាជាថ្មីម្តងទៀត ។ សាក្សី បានពន្យល់ថា កម្មាភិបាលត្រូវតែស្មោះត្រង់ជាមួយបក្ស ហើយថាវាពិបាកយល់ថាតើអ្នកណាត្រូវតែបោសសំអាត ។ “និយាយពីការបោសសម្អាតនៅក្នុងបក្សគឺមិនច្បាស់ទេ” គាត់និយាយទៀតថា សមាជិករបស់បក្សកុម្មុយនិស្តកម្ពុជា នឹងត្រូវបានស្រាវជ្រាវពីប្រវត្តិរូបរបស់ខ្លួននៅតាមភូមិកំណើត ។ ការបោសសម្អាតនេះ នឹងត្រូវបានអនុវត្តចាប់ពីតួនាទីនៅក្នុងបក្ស ។ មានតែកម្មាភិបាលជាន់ខ្ពស់ទេ ដែលដឹងថាអ្នកណាជាសត្រូវរបស់បក្ស ។

មកដល់ចំណុចនេះ លោកប្រធានអង្គជំនុំជម្រះប្រកាសផ្អាកសវនាការសម្រាប់អាហារថ្ងៃត្រង់ ។

បន្ទាប់ពីសម្រាក លោក ស្មីត បានសួរថាតើកម្មាភិបាលបក្សកុម្មុយនិស្តកម្ពុជាមានការភិតភ័យចំពោះគ្នាទៅវិញទៅមកដែរឬទេ ហើយមានការព្រួយបារម្ភថា កម្មាភិបាលមួយចំនួននឹងរាយការណ៍ពីគ្នាទៅវិញទៅមកដែរឬទេផ្អែកតាមអ្វីដែលលោកឃើញ លោកពុ “ដែលទាក់ទងជាមួយគោលនយោបាយមួយចំនួនចំពោះខ្មាំង” លោក កូប៉េ បានជំទាស់ទៅនឹងសំណួរបែបនេះ និងបានពន្យល់ថា សំណួរនេះនាំឲ្យមានការសន្និដ្ឋាន ។ លោក ស្មីត បានបញ្ជាក់សំណួរនេះ ។ សាក្សីបានពន្យល់ថា កម្មាភិបាលនៅខេត្តក្រចេះ និងមានភាពភ័យខ្លាចចំពោះកម្មាភិបាលភូមិភាគនិរតី បើសិនកម្មាភិបាលក្រចេះត្រូវបានចាប់ខ្លួន ។ សាក្សីបានបញ្ជាក់ថា គាត់មិនទុកចិត្តកម្មាភិបាលមូលដ្ឋានទេ នៅពេលត្រូវបានបញ្ជូនទៅកាន់តំបន់ផ្សេងទៀត ។ កម្មាភិបាលនៅក្នុងខេត្តក្រចេះបានចោទប្រកាន់គាត់ (សាក្សី) ពីការមិនសកម្មក្នុងការប្រយុទ្ធជាមួយវៀតណាម ។ នៅចុងឆ្នាំ១៩៧៨ ស្ថានភាពកាន់តែមានភាពតានតឹង ។ នៅត្រង់ចំណុចនេះ វៀតណាមបានកំពុងប្រយុទ្ធជាមួយខ្មែរក្រហម ។ កម្មាភិបាលផ្សេងទៀតមកពីតំបន់ផ្សេងៗ មិនមានការមិនការទុកចិត្តគ្នាទៅវិញទៅមកនោះទេ ។

## ការប្រជុំនានា

នៅក្នុងកិច្ចប្រជុំនានា អ្នកចូលរួមប្រជុំបាន “ទិះតៀនគ្នាឲ្យបំពេញការកិច្ចរបស់ខ្លួន” ឧទាហរណ៍អ្នកទាំងនោះ និងមានការពិភាក្សាថាតើសាក្សីត្រូវការប្រើសាំងអស់ប៉ុន្មាន និងត្រូវការវេលាប៉ុន្មាន ក្នុងការបញ្ជូនសំបុត្រ ។

លោក ស្មីត បានអានសម្រង់របស់សាក្សីដែលក្នុងនោះ សាក្សីបាននិយាយពីកិច្ចប្រជុំស្វ័យទិះតៀន ។ លោក ស្មីត ចង់ដឹង

ថាអ្នកណាត្រូវបានសម្គាល់ជាសត្រូវរបស់បក្សកុម្មុយនីស្ត ។ សាក្សីបានបន្ថែមប្រាប់ថា "កងទ័ពខ្លួនឯងផ្ទាល់បានបង្កើតព្រឹត្តិការណ៍នៅក្នុងជួរកងទ័ពរបស់ខ្លួនឯង ដូច្នេះព្រឹត្តិការណ៍ទាំងនេះមានផលប៉ះពាល់ដល់កងទ័ពផ្សេងទៀត" ខៀវ ជាប្រធានតំបន់១៣ ហើយបានបាត់ខ្លួន ។ សាក្សី ជួនកាលបានលើកបាយឲ្យ ខៀវ ប៉ុន្តែមិនបានដឹងថាមានរឿងអ្វីបានកើតឡើងដល់គាត់ជាបន្តបន្ទាប់នោះទេ ដូចដែលគាត់មិនបានដឹងថា តើមានអ្វីបានកើតឡើងចំពោះមនុស្សទូទៅ "នៅលើដី" នោះដែរ ។

សាក្សីបានទៅលេងស្រុករបស់គាត់ម្តង ប្រហែលជានៅក្នុងឆ្នាំ១៩៧៨ នៅពេលគាត់បានឃើញខ្មែរកម្ពុជាក្រោមបានចូលធ្វើកងទ័ព ។ សាក្សីបានទៅសួរសុខទុក្ខម្តាយរបស់គាត់នៅក្នុងមន្ទីរពេទ្យគិរីវង្សម្តង ។

លោក ស្មីត បាននិយាយថា សាក្សីបានចង្អុលបង្ហាញនៅក្នុងបទសម្ភាសន៍របស់ខ្លួនថា មានការទំនាក់ទំនងជាមួយ កា.ហ្សេ.បេ និងបានសួរថាហេតុអ្វីបានជាសាក្សីនិយាយប្រាប់បែបនេះ ។ សាក្សីបាននិយាយថា គាត់មិនយល់សំណួរ ។

លោក ស្មីត បន្ទាប់មក បានសួរថាតើប្រជាជនថ្មីត្រូវបានគេចាត់ទុកថាជាប់ពាក់ព័ន្ធជាមួយខ្មែរខ្មាំង ដោយសារតែប្រជាជនទាំងនោះមកពីទីក្រុង ហើយធ្លាប់បានគាំទ្ររបបមូលធននិយម និងគំនិតលោកខាងលិច ។ សាក្សី បានឆ្លើយថាគាត់អាច "យល់បានខ្លះៗ" ។ កម្មាភិបាលថ្នាក់ខេត្ត ស្រុក និងឃុំ នឹងបែងចែកប្រជាជនទៅតាមប្រភេទ ដូចជាពួកមូលធន ពួកកា.ហ្សេ.បេ ។ ចំណុចនេះត្រូវបានលើកយកមកពិភាក្សានៅក្នុងកិច្ចប្រជុំ ។ "មិនយូរទេ យើងបានពុតៗគ្នា ទៅវិញទៅមក និងមិនមានការជឿទុកចិត្តទៀតទេ ហើយប្រជាជនទាំងនោះដែរត្រូវបានគេចាត់ទុកនៅក្នុងប្រភេទខាងលើនេះ" លោកស្មីត បន្ទាប់មកបានសួរអំពីវាសនាប្រជាជនទាំងនោះ ដែលត្រូវបានជាប់ខ្សែពាក់ព័ន្ធទៅនឹងវៀតណាម តើមានអ្វីកើតឡើងចំពោះអ្នកទាំងនោះ? សាក្សីបានឆ្លើយថា ប្រសិនបើរឿងនេះកើតឡើង គឺបញ្ហានេះគឺ "គ្រោះថ្នាក់ដល់ខ្លួនហើយ" ប្រជាជនទាំងនោះនឹងលែងទទួលបានការទុកចិត្តពីថ្នាក់ឃុំ និងស្រុក ហើយមានមួយចំនួននឹងបានបាត់ខ្លួន ។

សាក្សីបានរៀនរាប់ថា ម្តាយមីងរបស់គាត់ មានប្តីជាជនជាតិចាម និងនៅតែមានអារម្មណ៍ខឹងនឹងខ្ញុំ ប្រជាជនដែលស្ថិតនៅក្នុងប្រភេទទាំងនេះ ក៏និងគ្រោះថ្នាក់ដូចគ្នា ។ លោកស្មីត ចង់ដឹងថាតើត្រូវបានដាក់នៅក្នុងក្រុមប្រភេទទាំងនេះនឹងមានន័យថា "ត្រូវបានគេសម្លាប់" សាក្សីឆ្លើយថាគាត់មិនបានឃើញស្ថានភាពផ្ទាល់នោះទេ ចាប់តាំងពីគាត់ "មិនបានចូលរួមជាមួយប្រជាជនទូទៅ" សាក្សីគ្រាន់តែឮថា ប្រជាជនបានស្លាប់នៅពេលដែលសាក្សីត្រឡប់មកពីសមរភូមិជារៀងរាល់ពេលឥឡូវនេះ និងរាល់ពេលនោះ ។ នៅពេលដែលលោក ស្មីត បានសួរសាក្សីបន្ថែមទៀតនៅលើស្ថានភាពនៅក្នុងគិរីវង្ស និងបានសួរថាតើមានចំណុចមន្ទីរសន្តិសុខនៅក្នុងតំបន់នេះ ។ លោក កូប៉េ បានថ្លែងគាត់ជាថ្មីម្តងទៀត និងបាននិយាយថា ការសួរបែបនេះបានទៅហួសពីវិសាលភាពនៃការជំនុំជម្រះក្តីនេះ ។ លោក ស្មីត បានឆ្លើយតបថា ជាទូទៅ វាទាក់ទងទៅនឹងការជឿទុកចិត្តរបស់សាក្សី ការធ្វើបន្សុទ្ធកម្ម និងស្ថានភាពសត្រូវ ។ តាមការដឹងផ្ទាល់របស់សាក្សី ប្រជាជនត្រូវបានឃុំខ្លួននៅវត្ត ។

លោក ស្មីត បានសួរសាក្សីបន្ថែមទៀតថា តើសាក្សីធ្លាប់ឮមន្ទីរសន្តិសុខមួយនៅក្រាំងតាចាន់ ដែលគាត់បានបដិសេធន៍មុន ។

**ទាហាន លន់ នល់ និងមន្ត្រីរាជការ**

សួរអំពីទាហានលន់ នល់ និងមន្ត្រីរាជការ សាក្សី បានរៀបរាប់ថា ប្រជាជនត្រូវបានបែកប្រភេទផ្សេងៗគ្នា ដូចជាប្រជាជនថ្មី ។

បន្ទាប់ពីសាក្សីបានចាកចេញទៅខេត្តក្រចេះ គាត់បានឮថាមានការចាប់ខ្លួនកម្មាភិបាលនៅក្នុងស្រុកគិរីវង្ស ។ នេះបានជំរុញឲ្យលោក ស្មីត សួរបន្តទៀតថាតើមូលហេតុអ្វីបានជាតា គុម ត្រូវបានចាប់ខ្លួន ។ គាត់បានឆ្លើយថាគាត់មិនបានដឹងថាហេតុអ្វីឲ្យពិតប្រាកដនោះទេ ។

លោក ស្មីត បានលើកឡើងដល់ចម្លើយរបស់សាក្សី ។ សាក្សីមិនអាចផ្តល់សេចក្តីលម្អិតបន្ថែមទៀតនោះទេ ប៉ុន្តែបានរក្សាជំហរលើសេចក្តីថ្លែងការណ៍ពីមុនរបស់ខ្លួន ។

បន្ទាប់មកលោក ស្មីត បាននិយាយថា គាត់បាននិយាយអំពីមនុស្សម្នាក់ដែលគេហៅថាតា គុម ដែលទៅសិក្សានៅប្រទេសវៀតណាម "ក្នុងអំឡុងពេលសង្គ្រាម" និងថាគាត់ត្រូវបានគេដកចេញពីតំណែងរបស់គាត់ ដោយសារតាម៉ុក ក៏ព្រោះតែគាត់មានការទាក់ទងជាមួយនឹងវៀតណាម ។ សាក្សីបានបញ្ជាក់ថា តាណាម

រស់នៅក្នុងស្រុកគិរីវង្ស ។ គាត់គឺជាមេបញ្ជាការកងទ័ពនៃតំបន់១៣ និងប្រពន្ធរបស់គាត់គេហៅថា គឿន ។

## ការបោសសម្អាតវណ្ណៈ

លោកស្មិត ចង់ដឹងថា គាត់មានន័យយ៉ាងម៉េច នៅពេលដែលគាត់បាននិយាយនៅក្នុងបទសម្ភាសន៍របស់លោកថា តាណាម “មិនត្រូវបានបោសសម្អាតទេ” ។ គាត់បានឆ្លើយថា តាណាម ទៅនៅស្រុកគិរីវង្ស ជាមួយប្រពន្ធរបស់គាត់ ។ ក្រោយមក តាណាម “បោសសម្អាត” ទៅជាមួយតា តុម ។

បន្ទាប់មកលោក ស្មិត បានសួរអំពីទង់បដិវត្តន៍ ដែលក្នុងនោះវាត្រូវបានគេនិយាយថា អង្គការ“គ្រប់គ្រងដើម្បីបោសសម្អាត” ខ្មាំងសត្រូវក្នុងបក្សនេះ ។ សាក្សីបាននិយាយថា វាមានន័យថាដើម្បីសម្លាប់ ប៉ុន្តែមិនអាចផ្តល់សេចក្តីលម្អិតបន្ថែមទៀត ។

លោក ស្មិត បានបង្ហាញឯកសារយោងមួយចំនួន និងបានសួរថាហេតុអ្វីបានជា តាម៉ុក បញ្ជូនកម្មាភិបាលពីភូមិភាគនិរតីទៅឲ្យធ្វើការនៅតាមភូមិភាគផ្សេងៗទៀតនៅក្នុងប្រទេសកម្ពុជា ។ សាក្សីបានឆ្លើយថា គាត់មិនបានដឹងលម្អិតទេ ។

លោក ស្មិត បានអានដកស្រង់ឯកសារដែលក្នុងនោះលោកបាននិយាយថាប្រជាជនទៅ“ការផ្លាស់ប្តូរមុខតំណែង” ដោយសារតែសកម្មភាពរបស់ជនក្បត់ ។ ដោយបានឮការការដកស្រង់ សាក្សីបាននិយាយថា ឥឡូវនេះលោកអាចយល់ពីបញ្ហានេះ“មានកម្មាភិបាលត្រូវបានគេធ្វើបន្សុទ្ធកម្ម ពីព្រោះកម្មាភិបាលទាំងនោះ មិនជឿទុកចិត្តគ្នាទៅវិញទៅមក” ។ កម្មាភិបាលពីភូមិភាគនិរតីទៅភូមិភាគពាយ័ព្យ ហើយអ្នកពាយ័ព្យទៅភូមិភាគនិរតីវិញ គាត់បាននិយាយថា ទៅវិញទៅមក ។

## តា ម៉ុក

លោក ស្មិត ចង់ដឹងថាហេតុអ្វីបានជា តាសោម នឹងមិនហ៊ានជំទាស់ជាមួយតាម៉ុក ។ សាក្សីបានឆ្លើយថា គាត់ជាអ្នក “រស់នៅជិតគាត់” ។ បានរៀបរាប់ថា នៅពេលណា “តា” និយាយហើយ តាសោមនឹងមិនហ៊ានតវ៉ាទេ ។ “ខ្ញុំជាអ្នកនាំសារ តែខ្ញុំនៅខាងក្រៅកិច្ចប្រជុំនេះ ។ ខ្ញុំអាចឮនៃការពិភាក្សានេះ” ។ តាម៉ុក គឺមានអនុភាព និងអ្វីដែលសាក្សីបានដឹងថា “ប្រជាជនស្រឡាញ់គាត់ ហើយកងទ័ពក៏ស្រឡាញ់ និងចូលចិត្តគាត់ដែរ” ។

## សាក្សីមិនបានដឹងអំពីការបញ្ជាឲ្យសម្លាប់ ពី តាម៉ុក

ស្មិត បានសួរថា តើគាត់បានដឹងពីសិទ្ធិអំណាចនៃគណៈអចិន្ត្រៃយ៍ភូមិភាគក្នុងការកម្ទេចនៅខាងក្នុង និងខាងក្រៅជួរបក្សពីថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៦ ។ សាក្សីបាននិយាយថា បញ្ហានេះលោកមិនបានដឹង ហើយសេចក្តីសម្រេចរបស់ថ្នាក់លើគាត់មិនបានដឹងទេ ។ នៅចំណុចនេះ លោកប្រធានអង្គជំនុំជម្រះសម្រេចផ្អាកសវនាការសម្រាប់ការសម្រាក ។

## ការគ្រប់គ្រងនៃសេចក្តីសម្រេចផ្ទាល់មាត់

បន្ទាប់ពីសម្រាក លោកប្រធានបានលើកឡើងអំពីការគ្រប់គ្រង ឬសេចក្តីសម្រេចផ្ទាល់មាត់ៈ

១) ទាក់ទងទៅនឹងសំណូមពរក្រុមមេធាវីរបស់ នួន ជា ដែលបានដាក់ឯកសារ ។ ឯកសារនោះបានដាក់ហើយនឹងផ្តល់លេខឯកសារ E3/10639

២) ការស្នើដាក់ឯកសារមួយទាក់ទងនឹងប្រវត្តិរូប និងអត្ថបទមួយដែលសរសេរដោយ Henri Locard ។ ឯកសារនោះ ត្រូវបានដាក់ ។

៣) ការស្នើរបស់សហព្រះរាជអាជ្ញា បានដាក់ជាជំពូក១ នៃសៀវភៅ ។ ឯកសារដែលស្នើនោះបានផ្តល់ហើយ ។ ចុះលេខ E3/10640 ។

៤) ការរំឭកចំពោះការដាក់ស្នើ បានដាក់តាំងពីលោក Michael Vickery បានមកផ្តល់សក្ខីកម្មនៅតុលាការ ។

## កម្មាភិបាលដែលត្រូវបញ្ជូនមកភ្នំពេញ

មេធាវីជនជាប់ចោទ ខៀវ សំផន បានកត់សម្គាល់ថា មានឯកសារមួយមានចំណារ ។ មានការពិភាក្សាមួយចំនួនអំពីឯកសារមួយដែលត្រូវបានដាក់ហើយ និងការយល់ច្រឡំខ្លះអំពីការស្នើសុំដោយសហព្រះរាជអាជ្ញា ។ លោកប្រធានចៅក្រមបានប្រកាសថា ឯកសារនេះដែលត្រូវបានអនុញ្ញាត ។

នៅវគ្គនេះ ត្រូវបានប្រគល់ឲ្យសហព្រះរាជអាជ្ញា ដើម្បីបន្តការសួរដេញដោលរបស់ខ្លួន ។ សាក្សីបាននិយាយថា គាត់គឺជាអនុប្រធានមន្ទីរកងពល១១៧ នៅក្រចេះ ។ ការិយាល័យមន្ទីរកងពលមានទីតាំងនៅក្បែរស្ពានក្រគរ ។ ទីតាំងនេះគឺធ្លាប់ប្រើជាកន្លែងឃ្លាំងសម្រាប់ទុករំសេវ ។ គាត់ទទួលខុសត្រូវខាងការទូរលេខ និង

*អ្នកផ្តល់ព័ត៌មានទៅសមរភូមិ ។ នៅពេលនោះ «វៀតណាមមានការប្រយុទ្ធប្រឆាំងយ៉ាងខ្លាំងមកលើយើង» ។*

*មន្ទីរតំបន់៥០៥ នៅក្រចេះ ដែលមាន មឿន និង ខុន ។ ទោះជាយ៉ាងណា គាត់មិនបានដឹងច្បាស់អំពីទីតាំងនេះទេ ។ មេបញ្ជាការរបស់កងពល១១៧ គឺឈ្មោះ លាង និងម៉ុង ។ លាង គឺជាអ្នកទីពីរ ។ អ្នកទីមួយ គឺ រ៉ុម ហើយអ្នកទីបី គឺម៉ុង ។ គាត់បានបញ្ជាក់អំពីសេចក្តីថ្លែងការណ៍របស់លោក ស្មីត ដែលបានអានថា មានកម្មាភិបាលថ្មីមកជំនួសកម្មាភិបាលចាស់ ហើយអ្នកណាដែលត្រូវបញ្ជូនទៅភ្នំពេញ «នៅពេលដែលស្ថានភាពនេះកាន់តែខ្លាំង» មុត បានមកដល់ទីតាំងរបស់កងពល ។*

*លោក ស្មីត បានសួរបន្ថែមថា តើគាត់បានចងចាំទេថាពេលដែលមេដឹកនាំជាន់ខ្ពស់ត្រូវបានគេហៅទៅភ្នំពេញតាមយន្តហោះនោះ ។ សាក្សីបានឆ្លើយថា គាត់បានឃើញសំបុត្រនោះតែម្តង ។ គាត់ត្រូវបានគេប្រាប់ថា យន្តហោះមួយនឹងមកដល់ ហើយគាត់បានឃើញសំបុត្រប្រកាសនេះ ។ មានកងវរសេនាធំពីរនាក់ កងពលធំពីរនាក់ ហើយនិង«មនុស្សពាក់ព័ន្ធមួយចំនួន» ផ្សេងទៀតបានមកពីភ្នំពេញដោយយន្តហោះនោះ ។ គាត់បានអានសំបុត្រមួយរបស់មេបញ្ជាការកងពលនេះ ។ គាត់បានទៅជួប មុត ដើម្បីអានសំបុត្រនោះ ។ បន្ទាប់ពីការមកដល់ អ្នកទាំងនោះមិនបានវិលត្រឡប់ទៅកន្លែងដើមរបស់ខ្លួនវិញទេ ។ ផុន បានជំនួសកន្លែង មឿន ហើយ ប៉ុក ជំនួសកន្លែង យាង ។*

*តាមរយៈព្រឹត្តិការណ៍មួយ គឺថាមេដឹកនាំរបស់គាត់ ត្រូវបានគេចាត់ទុកជាជនក្បត់ ។*

*បន្ទាប់មក លោក ស្មីត ចង់ដឹងថា ហេតុអ្វីបានជាសំបុត្រនោះបានផ្ញើមកពីមន្ទីរ ម-៧០ ។ គាត់និយាយថា អ្នកទាំងនោះបានដឹងច្បាស់ថា នេះជារបស់មន្ទីរម-៨៧០ តាំងពីអ្នកទាំងនោះឃើញការសរសេរនេះ ។ ដោយមានមិនមានបិទតែម ឬសញ្ញាសម្គាល់អ្វីទេ ។ រ៉ុម ជាទូទៅគាត់ទទួលតែសារ ។ អ្នកទទួលនេះត្រូវបានបញ្ជាក់យ៉ាងច្បាស់ ។*

*ចំណែក នឹម «គាត់ត្រូវបានចូលរួមនៅក្នុងសមរភូមិ ហើយគាត់មកមិនទាន់ ដើម្បីធ្វើដំណើរទៅភ្នំពេញ» ។*

*លោក ស្មីត បានសួរថា តើនៅក្នុងសំបុត្រនោះ បាននិយាយអំពីហេតុផលអ្វីខ្លះ? ថាតើហេតុអ្វីបានគាត់ទៅភ្នំពេញ ។ សាក្សីបានឆ្លើយថា គាត់មិនដឹងទេ ។ កងទ័ព របួសក៏ត្រូវបញ្ជូនតាមយន្តហោះពីរតនគិរី ទៅមណ្ឌលគិរី ។ ប្រជាជនដែលចេញពីថ្នាក់ដឹកនាំកងពល និងថ្នាក់ដឹកនាំផ្សេងៗក៏ត្រូវបានអញ្ជើញទៅតាមយន្តហោះដែរ ។*

*គាត់បានដឹកគណៈប្រតិភូចំនួន៤ទៅ៥ឡាន ។ គណៈប្រតិភូទាំងនោះបានទៅដល់កន្លែងផ្សេងៗ ហើយឡានបានទៅដល់ព្រលានប្រជាជនមួយចំនួនបាននៅកន្លែងនេះ ហើយប្រជាជនខ្លះទៀតបានដើរចូលទៅក្នុងព្រលាន ។ បន្ទាប់ពីនោះមក គាត់បានទៅមណ្ឌលគិរី ។ ពេលគាត់ត្រឡប់មកវិញ គាត់បានឮថា ថ្នាក់ដឹកនាំតំបន់ហើយនឹងកងពលត្រូវបានចាប់ខ្លួន ។*

*លោក ស្មីត បានសួរថា តើលេខាតំបន់៥០៥ ឈ្មោះ មឿន ត្រូវបានជិះយន្តហោះទៅនៅថ្ងៃនេះដែរ? សាក្សីបានឆ្លើយថា គាត់បានដឹងតែរ៉ុម ។ លាង បានមកដល់មុន ហើយបន្ទាប់មកទើប រ៉ុម នេះ ។ លាង មកដោយជិះកាណូត ។ គាត់មិនបានឃើញ លាង មកជិះយន្តហោះទេ ។ លាង ទៅតាមកាណូត ។ គាត់ទៅតាមកាណូតដឹកទាហានដែលត្រូវរបួសស្រាលច្រើន ។ គាត់មិនបានឃើញ លាង នៅលើយន្តហោះនោះទេ ។ លោក ស្មីត បានសួរថា ហេតុអ្វីបានជា រ៉ុម មកព្រលានយន្តហោះជាមួយគាត់ ហើយសាក្សីបានបន្ថែមថា យាង ដែលជាមិត្តភក្តិរបស់ រ៉ុម ក៏មកជាមួយដែរ ឈិន ហៅ ផន ដែលជាលេខាស្រុកឈ្នួល ក៏មកជាមួយដែរ ។ មឿន ក៏បានមកជាមួយអ្នកទាំងនោះដែរ ហើយនៅក្នុងថ្ងៃនោះគឺមានក្បួនមកទទួលអ្នកថ្មីនោះ ។*

*នៅពេលលោក ស្មីត បានសួរថា ចុះ ខុន យ៉ាងម៉េចដែរ ខុនគឺជាគណៈកម្មការអចិន្ត្រៃយ៍នៅតំបន់នោះក៏មកទីនេះដែរ? សាក្សីបានរៀបរាប់ថា គាត់ដឹកអ្នកទាំងនោះមកទីនេះទាំងអស់ រួមទាំងនីរសារផង ។ នៅពេលដែលគាត់ដាក់អ្នកដំណើរចុះអស់ហើយ គាត់បានបើកឡាននៅជុំវិញហ្នឹងម្តងទៀត ។ គាត់មិនឃើញឈ្មោះ នី ទេ ប៉ុន្តែអ្នកខ្លះហៅថា នឹម ។ សហព្រះរាជអាជ្ញាជាតិបានបញ្ជាក់ថា បុគ្គលនោះឈ្មោះថា ស្វាយ ញ៉ុង ដែលសាក្សីមិនបានរំឭកឈ្មោះគាត់ ។*

*លោកប្រធានបានប្រកាសផ្អាកសវនាការនេះ ហើយនឹងបន្តនៅថ្ងៃស្អែកទី២៦ ខែកក្កដាឆ្នាំ២០១៦ នៅម៉ោង៩ព្រឹក ហើយសាក្សីនេះនឹងបន្តការផ្តល់សក្ខីកម្មទៀត ។* **អាលីស មើហ្គើរ**

# ទូរថភ្លើងប្រាប់ពីអតីតកាល និងបច្ចុប្បន្នកាល



រូបថតដោយៈ ផេង ពង្សរ៉ាស៊ី នៅលើរថភ្លើងពីភ្នំពេញឆ្ពោះទៅខេត្តព្រះសីហនុ

ផ្តើមចេញពីការចង់ដឹងពីដំណឹងបាត់ខ្លួនអ៊ុំប្រុសម្នាក់ក្នុងរបបខ្មែរក្រហម ខ្ញុំបាន និងកំពុងធ្វើការនៅមជ្ឈមណ្ឌលឯកសារកម្ពុជាអស់រយៈពេលជិត២០ឆ្នាំ ។ បច្ចុប្បន្ននេះ ខ្ញុំកំពុងបម្រើការជាអ្នកអប់រំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យនៅកម្ពុជា ។ ការអប់រំនេះ ផ្តោតសំខាន់ទៅលើការកសាងសន្តិភាព ការផ្សះផ្សា ការព្យាបាលរបួសផ្លូវចិត្ត និងការទប់ស្កាត់អំពើប្រល័យពូជសាសន៍ជាលើកទី២ ។ ជាមួយនឹងការបង្ហាត់បង្រៀនអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ខ្ញុំតែងតែពន្យល់យ៉ាងក្បោះក្បាយពីព្រឹត្តិការណ៍នីមួយៗដែលបានកើតមាននៅក្នុងរបបខ្មែរក្រហម ។ ក្នុងនោះ ព្រឹត្តិការណ៍មិននឹកស្មានដល់ជាលើកដំបូង ដែលប្រជាជនកម្ពុជាភាគច្រើនបានជួបប្រទះ គឺការជម្លៀសអ្នកទីក្រុងចេញទៅធ្វើស្រែនៅតាមជនបទ នាថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ។

ប្រជាជនកម្ពុជាក្នុងទីក្រុងភ្នំពេញប្រមាណ២លាននាក់ សុទ្ធតែត្រូវខ្មែរក្រហមបោកប្រាស់តាមវិធីសាស្ត្រផ្សេងៗគ្នា ដើម្បីជម្លៀសអ្នកទាំងនោះចេញពីទីក្រុងភ្នំពេញ ។ ឧទាហរណ៍ៈ យោធាខ្មែរក្រហមបានបង្ខំឲ្យប្រជាជនចាកចេញពីទីក្រុងភ្នំពេញក្នុងថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ ក្រោមហេតុផលថា អាមេរិកាំងនឹងមកទម្លាក់គ្រាប់បែកទៀត ។ ចំណែកឯ អៀង សារី ជាឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការបរទេសបានពន្យល់ថា ការជម្លៀសប្រជាជនចេញពីទីក្រុង គឺដោយសារភាពកង្វះខាតសម្ភារ និងមធ្យោបាយដឹកជញ្ជូនក្នុងការនាំយកស្បៀងអាហារមកកាន់ទីក្រុង ។ ផ្ទុយទៅវិញ ប៉ុល ពត ជានាយករដ្ឋមន្ត្រីនៃកម្ពុជាប្រជាធិបតេយ្យ បានប្រាប់ពីមូលហេតុនៃការជម្លៀសប្រជាជនក្នុងនៅក្នុងដំណើរទស្សនកិច្ចរបស់ខ្លួនទៅកាន់ប្រទេសចិន កាលពីខែតុលា ឆ្នាំ១៩៧៧ថា មូលហេតុនៃការជម្លៀសប្រជាជន គឺដើម្បីបំបែកក្រុមចារកម្មរបស់ខ្មាំង ។ ព្រឹត្តិការណ៍ជម្លៀសជាថ្មីម្តងទៀត បានកើតឡើង៥ខែបន្ទាប់ពីថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ ។ លើកនេះ ប្រជាជនរាប់ម៉ឺននាក់ត្រូវបានបង្ខំឲ្យចាកចេញពីស្រុកកំណើតតាមមធ្យោបាយផ្សេងៗគ្នា ក្នុងនោះការចាកចេញតាមមធ្យោបាយរថភ្លើង ត្រូវបានកត់សម្គាល់ថា បានធ្វើឡើងសម្រាប់ប្រជាជនកម្ពុជាភាគច្រើនបំផុត ។

ក្នុងអំឡុងឆ្នាំ១៩៩៥-១៩៩៦ ខ្ញុំឧស្សាហ៍ធ្វើដំណើរកាត់តាមចំណតរថភ្លើងក្រុងភ្នំពេញ ។ ប៉ុន្តែខ្ញុំមិនបានដឹងរឿងរ៉ាវអ្វីទាំងអស់ដែលបានកើតឡើងចំពោះទូរថភ្លើងទាំងនោះ ។ ក្រោយមក នៅពេលដែលខ្ញុំបានដឹង និងបង្រៀនសិស្សានុសិស្ស និងគ្រូបង្រៀនពីការជម្លៀសដោយបង្ខំតាមរថភ្លើង ខ្ញុំនៅតែបានឆ្លៀតពេលវេលាសូម្បីតែបន្តិច ដើម្បីឈៀងចូលទៅមើល ឬថត ឬអង្គុយនៅលើទូរថភ្លើងទាំងនោះដដែល ។ ការពិត ទូរថភ្លើងដែលបន្សល់ទុកតាំងពីមុនរបបសង្គមរាស្ត្រនិយម មានប្រវត្តិរឿងរ៉ាវច្រើនដែលត្រូវបានកត់ត្រាទុកជាប្រវត្តិសាស្ត្ររបស់ប្រទេសកម្ពុជា ។ តាំងពីមានទូរថភ្លើងទាំងនេះនៅក្នុងប្រទេសកម្ពុជាមក មានប្រជាជនមិនតិចនាក់ទេ ដែលពេញចិត្ត ស្អប់ ខ្លាចរអារ សប្បាយរីករាយ និងតក់ស្លុត ដោយសារតែទូរថភ្លើងទាំងនោះ ។

ក្នុងរបបសង្គមរាស្ត្រនិយម ខ្សែរថភ្លើងទាំងអស់ទទួលបានការពេញនិយមពីសំណាក់ប្រជាជនគ្រប់ស្រទាប់វណ្ណៈ ។ ការធ្វើដំណើរយ៉ាងពេញនិយមតាមរថភ្លើងនាពេលនោះ បានផ្តល់នូវភាពងាយស្រួល មានសុវត្ថិភាព និងបន្ធូរបន្ថយការចំណាយរបស់ប្រជាជន ។ មិនដូចនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យឡើយ ខ្សែរថភ្លើងដដែលនេះ ដើរតួនាទីយ៉ាងសំខាន់ក្នុងការដឹកជញ្ជូនប្រជាជនកម្ពុជា

រាប់ម៉ឺននាក់ចេញពីទីក្រុង និងទីប្រជុំជនឆ្ពោះទៅកាន់តំបន់ដែលគ្មាននរណាម្នាក់នៅក្នុងរថភ្លើងមិនបានដឹងទាល់តែសោះថាតើខ្លួនត្រូវទៅកាន់គោលដៅណាមួយឲ្យប្រាកដ ។ ម្យ៉ាងវិញទៀត គ្មានអ្នកដំណើរណាម្នាក់ទទួលបាននូវការពេញចិត្តពេញថ្លើមក្នុងការធ្វើដំណើរតាមរថភ្លើងនេះឡើយ ព្រោះគិតថាខ្លួនប្រហែលជាមិនបានវិលត្រឡប់មកកាន់ស្រុកកំណើតវិញឡើយ ។ ក្នុងអំឡុងទសវត្សរ៍ឆ្នាំ១៩៨០ និង១៩៩០ ការធ្វើដំណើរតាមរថភ្លើងតែងទទួលរងនូវការគំរាមកំហែងជាដរាបពីសំណាក់ទ័ពព្រៃខ្មែរក្រហម ។ ក្នុងខែកក្កដា ឆ្នាំ១៩៩៤ កម្លាំងទ័ពព្រៃខ្មែរក្រហម បានពួនស្ទាក់វាយខ្សែរថភ្លើងនៅចំណុចប្រមាណ១០គីឡូម៉ែត្រភាគខាងកើតទីក្រុងកំពត និងបានសម្លាប់អ្នកដំណើរជនជាតិខ្មែរចំនួន១៣នាក់ ព្រមទាំងបានចាប់ខ្លួនជនបរទេសចំនួន៣នាក់ ហើយបានសម្លាប់ជនបរទេសទាំងនោះចោលក្នុងរយៈពេល២ខែក្រោយមក ។ មិនត្រឹមតែប៉ុណ្ណោះ ប្រជាជនរាប់រយពាន់នាក់ទៀត បានស្លាប់ដោយសារតែអំពើប្លន់រថភ្លើង ជាពិសេសអ្នករកស៊ីជួញដូរទំនិញពីខេត្តបាត់ដំបង បន្ទាយមានជ័យមកកាន់ភ្នំពេញ ។ ព្រឹត្តិការណ៍ទាំងអម្បាលមាណនេះ បានធ្វើឲ្យប្រជាជនកម្ពុជាបាក់ស្បាត និងខ្លាចរអារ ចំពោះការធ្វើដំណើរតាមខ្សែរថភ្លើង ហើយក៏មិនចង់រំឭកពីប្រវត្តិរឿងរ៉ាវទាំងអស់ប្រាប់ដល់កូនចៅជំនាន់ក្រោយឲ្យបានដឹងដែរ ។

ដោយសារហេតុផលនេះហើយ ទើបក្មេងៗជំនាន់ក្រោយដែលបានទទួលការសិក្សានៅក្រៅប្រទេស ហាក់មានអំណួតថា ខ្លួនបានធ្វើដំណើរទៅណាមកណាតាមខ្សែរថភ្លើង ហើយថាការធ្វើដំណើរនេះពិតជាអស្ចារ្យក្នុងបទពិសោធន៍នៃជីវិតរបស់ខ្លួន ដែលមានភ័ព្វវាសនាបានជិះនៅលើរថភ្លើងស្រុកគេ ។ ផ្ទុយទៅវិញ អ្នកទាំងនោះប្រហែលមិនបានគិតដល់ថា ប្រទេសរបស់ខ្លួនក៏មានរថភ្លើងដូចគេដែរ ហើយប្រហែលជាមិនធ្លាប់ធ្វើដំណើរតាមរថភ្លើងក្នុងប្រទេសខ្លួនឯងទាល់តែសោះ ។

ក្នុងពេលជាមួយគ្នានេះដែរ ជនបរទេសដែលជាភ្ញៀវទេសចរណ៍មកទស្សនាប្រទេសកម្ពុជា បានស្វះស្វែងរកគ្រប់វិធីធ្វើយ៉ាងណាបានទៅធ្វើដំណើរកម្សាន្តនៅលើផ្លូវរថភ្លើងតាមឧបករណ៍ច្នៃប្រឌិតរបស់ខ្មែរដែលភាសាអ្នកភូមិហៅថា "ណូរី" ព្រោះអ្នកទាំងនោះចង់ភ្លក់រសជាតិនៃការធ្វើដំណើរកម្សាន្តតាមផ្លូវដែកនៅកម្ពុជា និងគយគន់មើលជាតិធម្មជាតិបៃតងនៅតាមសងខាងផ្លូវដែក ។ មិនត្រឹមតែភ្ញៀវទេសចរណ៍បរទេសប៉ុណ្ណោះទេ ប្រជាកសិករដែលរស់



រូបថត ឆ្នាំ២០១៦ ៖ រថភ្លើងដឹកអ្នកដំណើរចេញពីក្រុងភ្នំពេញ មកឈប់រយៈពេល១៥នាទី នៅចំណតរថភ្លើងខេត្តតាកែវ ក្នុងដំណើរឆ្ពោះទៅខេត្តព្រះសីហនុ

នៅតាមបណ្តោយផ្លូវរថភ្លើងមួយចំនួន បានប្រើប្រាស់ឧបករណ៍កែច្នៃនេះ ដើម្បីសម្រួលដល់ការធ្វើដំណើរទៅកាន់គោលដៅរបស់ខ្លួន និងជាឧបករណ៍សម្រាប់ជួលជិះទៀតផង ។

បន្ទាប់ពីរយៈពេលជាង៣០ឆ្នាំក្រោយរបបខ្មែរក្រហម និងសង្គ្រាមរ៉ាំរ៉ៃនៅកម្ពុជា ប្រវត្តិសាស្ត្រនេះត្រូវបានរំឭកឡើងវិញ ។ ទូររថភ្លើង និងផ្លូវដែក ត្រូវបានជួសជុលដាក់ឲ្យប្រើប្រាស់ជាធម្មតា និងជាផ្លូវការ ។ ប្រមុខរាជរដ្ឋាភិបាលកម្ពុជា សម្តេច ហ៊ុន សែន បានមានប្រសាសន៍ក្នុងកម្មវិធីសម្ពោធដាក់ឲ្យប្រើប្រាស់ខ្សែរថភ្លើងកម្ពុជាឡើងវិញថា «ដោយសារតែប្រទេសរបស់យើងមានសន្តិភាពពេញលេញ យើងមានឱកាសក្នុងការស្តាបនាហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូនរបស់យើងឡើងវិញ»

ស្របពេលនេះដែរ អង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជា បានដំណើរការរឿងក្តីកាត់ទោសមេដឹកនាំកំពូល២រូបគឺ នួន ជា និង ខៀវ សំផន ពីបទឧក្រិដ្ឋមួយចំនួន ដែលរាប់បញ្ចូលទាំងការជម្លៀសប្រជាជនកម្ពុជារាប់ម៉ឺននាក់ដោយបង្ខំពីទីក្រុង និងទីប្រជុំជនទៅកាន់តំបន់ដាច់ស្រយាល ដែលបង្កឲ្យមានការស្លាប់ និរាស្ត្រ ព្រាត់ប្រាស់ ធ្វើការហួសកម្លាំង រងទារុណកម្ម និងកាប់សម្លាប់ឥតត្រាប្រណីមកលើប្រជាជនកម្ពុជាអស់រាប់សែននាក់ ក្រោមការគ្រប់គ្រងរបស់ខ្លួន ។ ដំណើរការព្រមគ្នាមួយទៀត គឺការដាក់តាំងពិព័រណ៍ចល័តស្តីអំពី «ការជម្លៀសដោយបង្ខំ» របស់មជ្ឈមណ្ឌលឯកសារកម្ពុជា នៅតាមបណ្តាខេត្ត-ក្រុងមួយចំនួនក្នុងទូទាំងប្រទេស ។ កិច្ចការទាំងអស់នេះ សុទ្ធតែផ្តើមចេញពីខ្សែរថភ្លើងតែមួយរបស់កម្ពុជា ។ ដើម្បីជាបទពិសោធន៍ក្នុងជីវិត ក្នុងនាមជាអ្នកបណ្តុះបណ្តាលពីប្រវត្តិសាស្ត្រខ្មែរក្រហម ជាពិសេសបង្រៀនផ្ទាល់ពីការជម្លៀសដោយបង្ខំតាមរថភ្លើង ក៏ដូចជាការមើលឃើញ និងធ្វើដំណើរដោយផ្ទាល់តាមរថភ្លើងនាពេលបច្ចុប្បន្ន ខ្ញុំបានធ្វើដំណើរជាមួយមិត្តរួមការងារទាំងអស់នៃមជ្ឈមណ្ឌលឯកសារកម្ពុជាតាមរថភ្លើង ដើម្បីចូលរួមប្រជុំបូកសរុបការងារប្រចាំឆ្នាំនៅខេត្តព្រះសីហនុ នាថ្ងៃទី៦ ខែសីហា ឆ្នាំ២០១៦ ។ អង្គុយលើរថភ្លើងទាំងអារម្មណ៍រំភើប ខ្ញុំបានសម្លឹងមើលអ្នកដំណើរនៅជុំវិញខ្លួន និងទេសភាពដ៏ត្រកាលនៅសងខាងផ្លូវរថភ្លើង ។ អង្គុយបណ្តើរ និងស្តាប់បទចម្រៀងតាមទូរស័ព្ទបណ្តើរ ខ្ញុំបានគិតដល់អតីតកាលក្នុងរបបខ្មែរក្រហម និងបានរំឭកឡើងវិញនូវមេរៀនដែលខ្ញុំបានបង្រៀនសិស្ស និងគ្រូបង្រៀនពីជំពូកស្តីពី «ការជម្លៀសដោយបង្ខំ» ក្នុងរបបខ្មែរក្រហម ។ ខ្ញុំនឹកគិតដល់រូបថតមួយសន្លឹកដែលបង្ហាញឲ្យឃើញពីទឹកមុខម៉ឺងម៉ាត់ញញឹមញញែមរបស់មេដឹកនាំកំពូលខ្មែរក្រហមប៉ុន្មាននាក់ដែលបានជិះលើរថភ្លើង ហើយត្រូវបានថតទុកជាអនុស្សាវរីយ៍ ។ រូបថតនេះ កំពុងស្ថិតនៅក្នុងបណ្ណសារដ្ឋានរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា នាពេលបច្ចុប្បន្ននេះ ហើយត្រូវបានប្រើប្រាស់ដើម្បីជាប្រយោជន៍ជាតិ និងសង្គមទាំងមូល ។ ភ្លាមៗនោះដែរ ខ្ញុំបានបង្កើតសំណួរក្នុងគំនិតថា តើហេតុអ្វីមេដឹកនាំកំពូលៗទាំងនោះបញ្ជូនប្រជាជនខ្លួនឯងតាមរថភ្លើងទៅសម្លាប់យ៉ាងដូច្នេះ? ហើយ ហេតុអ្វីបានជាការធ្វើដំណើរតាមរថភ្លើងរបស់ខ្លួន មិនត្រូវបានសម្លាប់ដូចប្រជាជន?

ពីរបីម៉ោងក្រោយមក ការធ្វើដំណើររបស់ខ្ញុំបានមកដល់ទឹកដីខេត្តកំពត ។ នៅសងខាងផ្លូវ សម្បូរទៅដោយធម្មជាតិខៀវស្រងាត់ និងភ្នំហ៊ុំព័ទ្ធជុំវិញ ។ ដល់ត្រឹមនេះ ខ្ញុំនឹកឃើញពីការសម្លាប់ប្រជាជនស្លូតត្រង់១៣នាក់ និងជនបរទេស៣នាក់កាលពីឆ្នាំ១៩៩៤ ក្នុងពេលដែលប្រទេសកម្ពុជាមិនទាន់ទទួលបានសុខសន្តិភាពនៅឡើយ ។ ព្រឹត្តិការណ៍នេះ បានធ្វើឲ្យខ្ញុំស្វែងយល់កាន់តែស្កាល់ច្បាស់ពីអំពើឃោរឃៅរបស់ខ្មែរក្រហម ។ ផ្ទុយគ្នាស្រឡះពីឆ្នាំ១៩៩៤ អ្នកដំណើរទាំងអស់រួមទាំងខ្ញុំផង បានធ្វើដំណើរដោយគ្មានការព្រួយបារម្ភអ្វីទាំងអស់ ។ នេះប្រហែលមកពីអ្នកដំណើរទាំងនោះមិនបានដឹងពីរឿងរ៉ាវដែលបានកើតឡើងសម្រាប់ការធ្វើដំណើរតាមរថភ្លើងនាពេលនោះឡើយហើយមើលទៅ ឬមួយក៏រឿងរ៉ាវទាំងនេះត្រូវបានបំភ្លេចចោល? ទោះជាយ៉ាងដូច្នេះក្តី ប្រជាជនវ័យចំណាស់ៗដែលរស់នៅក្នុងខេត្តកំពត ប្រហែលជាមិនអាចបំភ្លេចរឿងរ៉ាវទាំងនេះបានឡើយ ។ ក្រឡេកមកមើលក្មេងៗដែលកើតក្រោយរបបខ្មែរក្រហមវិញ ម្នាក់ៗបានប្រើប្រាស់គ្រប់មធ្យោបាយក្នុងការផ្តិតយករូបភាពខ្លួនឯង មិត្តភក្តិ ក្រុមគ្រួសារ និងទេសភាពយ៉ាងរំភើយ ។ មកដល់ចំណត អ្នកទាំងនោះនៅតែបន្តថតរូបខាងក្រៅរថភ្លើងទៀត និងបានទិញរបស់របរជាច្រើនដើម្បីបម្រុងទុកសម្រាប់ដំណើរដ៏វែងឆ្ងាយទៀត ។ សកម្មភាពដូចគ្នានេះ បានធ្វើឡើងម្តងទៀតនៅពេលដែលរថភ្លើងបានទៅដល់ចំណតចុងក្រោយឯខេត្តព្រះសីហនុ ។ ចុះពី

លើរថភ្លើងជាមួយទឹកមុខរីករាយ អ្នកដំណើរទាំងអស់បានបន្តដំណើររបស់ខ្លួនតាមមធ្យោបាយរៀងខ្លួន ។ ខ្លះជិះរថយន្តផ្ទាល់ខ្លួនដែលបានសណ្ដោងពីក្រោយរថភ្លើង ។ ខ្លះជិះរថយន្តក្រុង ។ ខ្លះជិះរថយន្តឈ្នួល និងម៉ូតូជាដើម ។ មិនដូចក្នុងរបបខ្មែរក្រហមឡើយ ប្រជាជនជម្លៀសទាំងអស់ត្រូវបង្ខំឲ្យចុះពីលើរថភ្លើងជាមួយទឹកមុខស្រងូតស្រងាត់ និងព្រួយបារម្ភ រួចបន្តដំណើរតាមរទេះគោ ឬដើរថ្មើរជើងទៅកាន់កន្លែងដែលខ្មែរក្រហមបានកំណត់ទុក ។ អ្នកទាំងនោះ ភាគច្រើនមិនបានវិលត្រឡប់មកកាន់ទីក្រុង ឬស្រុកកំណើតវិញឡើយ ហើយក៏បាត់ដំណឹងរហូតមកដល់បច្ចុប្បន្ន ។

តាំងពីលើរថភ្លើងរហូតមកដល់ចំណត ខ្ញុំបានធ្វើដំណើរអស់រយៈពេលជាង៧ម៉ោង ។ ក្នុងរយៈពេលនេះ ខ្ញុំបានស្វែងយល់ពីភាពខុសគ្នាមួយចំនួនរវាងដំណើរតាមរថភ្លើងកាលពីក្នុងរបបខ្មែរក្រហម និងពេលបច្ចុប្បន្ន ។

**ក្នុងរបបខ្មែរក្រហមៈ**

១) ប្រជាជនកម្ពុជាត្រូវបានបង្ខំ សម្លុត និងគំរាមសម្លាប់ឲ្យឡើងរថភ្លើង ដើម្បីបន្តដំណើរទៅកាន់គោលដៅ ។

២) អ្នកដំណើរទាំងអស់ មិនបានដឹងគោលដៅថាខ្លួនត្រូវទៅកាន់ទីណាឡើយ ។

៣) អ្នកដំណើរមានការភ័យខ្លាច និងមិនហ៊ានជជែកគ្នាក្នុងទូរថភ្លើង ។

៤) អ្នកដំណើរណែនណាន់តាន់តាប់ បានធ្វើដំណើរទាំងយប់ទាំងថ្ងៃ និងមិនមានសេរីភាពក្នុងស្ថានភាពឈរ ។

៥) រស់មួយថ្ងៃសម្រាប់មួយថ្ងៃ ។

**ពេលបច្ចុប្បន្នៈ**

១) ការធ្វើដំណើររបស់អ្នកដំណើរ គឺអាស្រ័យទៅលើចំណង់ចំណូលចិត្តរបស់ខ្លួន ។

២) អ្នកធ្វើដំណើរ គឺជាអ្នកកំណត់គោលដៅខ្លួនឯងយ៉ាងច្បាស់លាស់មុននឹងធ្វើដំណើរ ។

៣) អ្នកធ្វើដំណើរប្រកបដោយទឹកមុខស្រស់ស្រាយ និងមានសេរីភាពពេញលេញក្នុងការជជែកកម្សាន្ត ។ ខ្ញុំសង្កេតឃើញក្មេងជំទង់ៗជាច្រើននាក់ បានបង្កភាពសប្បាយរីករាយដល់ក្រុមខ្លួន និងទទួលការសាទរពីអ្នកដំណើរឯទៀត តាមរយៈការប្រគុំបទចម្រៀង និងភ្លេងបែបសម័យទំនើបនៅក្នុងទូរថភ្លើង ពេលកំពុងធ្វើដំណើរ ។ អ្នកដំណើរខ្លះបរិភោគចំណីអាហារ និងថតរូបទុកជាអនុស្សាវរីយ៍ទៀតផង ។

៤) អ្នកធ្វើដំណើរមានទំនុកចិត្តខ្ពស់ចំពោះសុវត្ថិភាពផ្ទាល់ខ្លួន និងក្រុមគ្រួសារ ។

៥) អ្នកធ្វើដំណើរមានចម្រុះពូជសាសន៍ ។

ថ្វីត្បិតតែការរៀបរាប់ខាងលើនេះបង្ហាញឲ្យឃើញពីភាពផ្លាស់ប្ដូរច្រើនសន្ធឹកសន្ធាប់ ប៉ុន្តែទូរថភ្លើង ផ្លូវដែក ចំណតរថភ្លើង និងទេសភាពខៀវស្រងាត់ដ៏គួរឲ្យគយគន់នៅសងខាងផ្លូវ គឺមិនត្រូវបានផ្លាស់ប្ដូរឡើយ ។ នេះមិនមែនមានន័យថា ប្រវត្តិសាស្ត្រប្រំដែលនិងសាទៅសាមកនោះទេ ប៉ុន្តែនេះជាការវិវត្តទៅមុខនៃប្រវត្តិសាស្ត្ររបស់កម្ពុជា ។ ខ្ញុំយល់ឃើញថា ទូរថភ្លើងចាស់ៗដែលបន្សល់ទុកតាំងពីមុនសម័យសង្គមរាស្ត្រនិយម ហើយត្រូវបានជួសជុលប្រើប្រាស់ឡើងវិញ ពិតជាធ្វើឲ្យប្រជាជនកម្ពុជាបន្តរក្សាការចងចាំដែលមិនអាចបំភ្លេចបាននូវរឿងរ៉ាវ និងប្រវត្តិនៃការប្រើប្រាស់ទូរថភ្លើងតាមរបត់នយោបាយផ្សេងគ្នារបស់មេដឹកនាំប្រទេសម្នាក់ៗ ។ ម៉្យាងទៀត ទូរថភ្លើងទាំងនេះ បានបន្សល់ទុកជាភ័ស្តុតាងជាក់ស្ដែងមួយសម្រាប់កូនខ្មែរជំនាន់ក្រោយ ឲ្យបន្តសិក្សាស្វែងយល់ឲ្យស៊ីជម្រៅពីការប្រើប្រាស់ឧបករណ៍មួយដោយខុសគោលដៅដែលនាំឲ្យជីវិតមនុស្សរាប់ម៉ឺននាក់បាត់បង់ ស្របពេលដែលការបង្កើតទូរថភ្លើងទាំងនេះមកគឺដើម្បីជួយសម្រួលដល់ទុកលំបាករបស់ប្រជាជន ។ បន្ថែមពីនេះទៀត ទូរថភ្លើងនេះបានធ្វើឲ្យប្រជាជនកម្ពុជាគ្រប់គ្នា ជាពិសេសអ្នកដែលរស់រានមានជីវិតបន្ទាប់ពីរបបខ្មែរក្រហម ចងចាំក្នុងចិត្តឥតបំភ្លេចបាននូវព្រឹត្តិការណ៍ជាប្រវត្តិសាស្ត្រដែលបានកើតមានលើប្រទេសកម្ពុជានារបបខ្មែរក្រហម ។

សរុបសេចក្ដីទៅ ការប្រើប្រាស់ឧបករណ៍ឥតវិញ្ញាណដូចជាការប្រើប្រាស់ទូរថភ្លើង និងផ្លូវដែកជាឧទាហរណ៍ស្រាប់នេះ សម្រាប់សម្លាប់មនុស្ស ឬ ជួយសម្រួលដល់ជីវភាពរបស់មនុស្ស គឺអាស្រ័យលើប្រមុខដឹកនាំប្រទេសជាអ្នកកំណត់ ។ ជាអាទិ៍ការរើបឡើងវិញនៃវិស័យគមនាគមន៍នៅកម្ពុជា គឺជាសញ្ញាបង្ហាញប្រាប់ពីការអភិវឌ្ឍទៅមុខសន្សឹមៗ ដែលឆ្ពោះទៅរកវិស័យគមនាគមន៍ជឿនលឿនលើពិភពលោក ។ **ផេង ពង្សរ៉ាស៊ី**

# លើកទី១សម្រាប់ខ្ញុំ បន្ទាប់ពីរយៈពេលជាង៤៩ឆ្នាំ




មានមនុស្សជាច្រើនបានស្គាល់ពីរថភ្លើងនៅប្រទេសកម្ពុជា ដែលបើកដំណើរការដំបូងចាប់តាំងពីសម័យអាណានិគមបារាំងមកម្ល៉េះ តែពីមុនមកក៏មានអ្នកដែលមិនធ្លាប់ជិះរថភ្លើងនេះដែរ រួមទាំងរូបខ្ញុំ ដោយសារមានការយល់ឃើញផ្សេងគ្នាថា អ្នកខ្លះយល់ឃើញថារថភ្លើងចាស់ពេក រថភ្លើងមានល្បឿនយឺត ដូច្នេះត្រូវចំណាយពេលវេលាយូរ ហើយផ្លូវរថភ្លើងមិនមានសុវត្ថិភាពជាដើម ។

ខ្ញុំជាបុគ្គលិកមជ្ឈមណ្ឌលឯកសារមួយរូប ហើយបច្ចុប្បន្នមានអាយុ៤៩ឆ្នាំ ។ ថ្មីៗនេះ ខ្ញុំទើបតែសាកល្បងជិះរថភ្លើងដែលបានកែលម្អ និងដាក់ឲ្យដំណើរការឡើងវិញដោយក្រុមហ៊ុនរ៉ូយ៉ាល់គ្រុបរបស់ ឧកញ៉ា គិត ម៉េង បន្ទាប់ពីផ្អាកដំណើរការដឹកជញ្ជូនភ្ញៀវអស់រយៈពេលជាច្រើនឆ្នាំកន្លងមក ។ នេះជាឱកាសលើកទីមួយ ហើយសម្រាប់ខ្ញុំដែលបានជិះរថភ្លើងកម្សាន្តជាមួយក្រុមការងារមជ្ឈមណ្ឌលឯកសារកម្ពុជាដែលមានសមាជិកសរុបជាង៤០នាក់ បន្ទាប់ពីយើងបានបំពេញការងារមមាញឹកក្នុងអំឡុងពេលជិតមួយឆ្នាំកន្លងមក ។ ដំណើរកម្សាន្តនេះក៏ជាផ្នែកមួយបង្កឲ្យមានភាពស្និទ្ធស្នាល ស្គាល់ចិត្ត ដែលអាចជំរុញឲ្យការងារទទួលបានជោគជ័យ និងបន្តទៅមុខវែងឆ្ងាយទៀត ។

យើងចេញដំណើរពីស្ថានីយរថភ្លើងភ្នំពេញនៅវេលាម៉ោង ៧ព្រឹក ឆ្ពោះទៅតំបន់ទេសចរណ៍សមុទ្រនៃខេត្តព្រះសីហនុ ដោយឆ្លងកាត់ខេត្តតាកែវ និងកំពត ។ បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាមួយចំនួនបានអង្គុយលាយឡំជាមួយអ្នកដំណើរផ្សេងទៀតដោយទឹកចិត្តសប្បាយរីករាយ ។

នៅក្នុងទូរថភ្លើងពិសេស ដែលខ្ញុំអង្គុយ ខ្ញុំសង្កេតឃើញកៅអីពូកស្បែកពណ៌ប្រផេះ និងមានម៉ាស៊ីនត្រជាក់ ។ ចំណែកនៅក្នុងទូរថភ្លើងធម្មតា ខ្ញុំក៏សង្កេតឃើញមានលក់អាហារ និងភេជ្ជៈសម្រាប់អ្នកដំណើរពេលព្រឹកផងដែរ ។

សម្លឹងមើលពីរថភ្លើង ខ្ញុំឃើញភូមិ ផ្ទះរបស់ប្រជាជន និងវាលស្រែពណ៌បៃតងស្រស់នៅតាមបណ្តោយផ្លូវ ។ យើងជិះឆ្លងកាត់ព្រៃ កាត់ជើងភ្នំ គួរជាទីគយគន់ ។ ការធ្វើដំណើរតាមរថភ្លើងធ្វើឲ្យខ្ញុំមានអារម្មណ៍សប្បាយរីករាយ ដោយសារតាមផ្លូវរថភ្លើងមានសភាពស្ងប់ស្ងាត់ គ្មានចរាចរណ៍ខ្វាត់ខ្វែងដូចផ្លូវរថយន្តដែលខ្ញុំសង្កេតឃើញមានគ្រោះថ្នាក់ចរាចរណ៍បង្កឡើងជារឿយៗ ។

ទោះបីខ្ញុំបានជិះរថភ្លើងដែលមានភាពទាន់សម័យនៅពេលនេះ ដោយមិនប្រៀបធៀបជាមួយរថភ្លើងប្រទេសជឿនលឿនដទៃក៏ដោយ ក៏ខ្ញុំមិនភ្លេចពីអតីតកាល និងប្រវត្តិជូរចត់តាមផ្លូវរថភ្លើងរបស់កម្ពុជាក្នុងអំឡុងរបបខ្មែរក្រហមដែរ ។ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ប្រជាជនភាគច្រើនត្រូវខ្មែរក្រហមជម្លៀសតាមផ្លូវរថភ្លើងសំដៅទៅភូមិភាគពាយ័ព្យ រួមមាន ខេត្តពោធិ៍សាត់ និងខេត្តបាត់ដំបង ដើម្បីធ្វើការងាររលត់ដំ ។ គ្រួសារប្រជាជនកម្ពុជាស្ទួតត្រង់រាប់រយពាន់នាក់បានបែកខ្ញែក និងស្លាប់ តាមរយៈការជម្លៀសនេះ រួមទាំងគ្រួសារខ្ញុំដែរ ។

នៅអំឡុងឆ្នាំ១៩៧៩ ពេលខ្ញុំមានអាយុប្រហែលជា១១ឆ្នាំ ខ្ញុំបានស្តាប់រឿងរ៉ាវជាច្រើនពីអ៊ំស្រីរបស់ខ្ញុំឈ្មោះ ឡៃ ដែលនៅរស់រានមានជីវិតហើយត្រឡប់មកស្រុកកំណើតនៅភូមិយកបាត ឃុំក្បាលកោះ ស្រុកកៀនស្វាយ ខេត្តកណ្តាល ។

អ៊ំ ឡៃ បានរៀបរាប់ថា គ្រួសារយាយរបស់ខ្ញុំកាលពីជំនាន់សង្គមរាស្ត្រនិយមរស់នៅទីក្រុងភ្នំពេញ ។ យាយរបស់ខ្ញុំបង្កើតឈ្មោះ រ៉ុន និងជីតាខ្ញុំឈ្មោះ តាស៊ុយ ។ យាយតាខ្ញុំមានកូនស្រីម្នាក់

ឈ្មោះ អ៊ុយ សារ៉ុម ក្រោយមកត្រូវលោកសេនាប្រមុខលោក លន់ នល់ សុំយកធ្វើជាកូនចិញ្ចឹម និងចាត់ឲ្យជីតាខ្ញុំម្នាក់ទៀតឈ្មោះ ហួត និងប្រពន្ធឈ្មោះយាយ លាន ជាអ្នកមើលថែទាំ កូនគាត់បង្កើត (ឈ្មោះ គុជ និង ពេជ្រ) ឲ្យមើលថែទាំ សារ៉ុម បន្ថែមទៀត ។

នៅឆ្នាំ១៩៧៥ ពេលខ្មែរក្រហមបានឡើងកាន់អំណាច ក្រុមគ្រួសារយាយរបស់ខ្ញុំបានចាកចេញពីទីក្រុងភ្នំពេញត្រឡប់មករស់នៅស្រុកកំណើតនៅខេត្តកណ្ដាលវិញ ។ នៅដើមខែកក្កដា ឆ្នាំ១៩៧៥ ពេលដែលប្រជាជនចាប់ផ្ដើមខ្វះខាតអាហារ ខ្មែរក្រហមក៏បានឃោសនារកគ្រួសារស្ម័គ្រចិត្តឲ្យមកចុះឈ្មោះនៅសាលាឃុំ ដើម្បីទៅរស់នៅភូមិភាគពាយ័ព្យដែលជាតំបន់សម្បូរស្រូវអង្ករ ។ កាលនោះយាយរបស់ខ្ញុំមិនចង់ចាកចេញពីស្រុកកំណើតទេ តែគាត់គិតថាបើគាត់ និងគ្រួសារបន្តរស់នៅទីនេះទៀតក៏គង់នឹងស្លាប់ដដែល ព្រោះមិនយូរមិនឆាប់ខ្មែរក្រហមនឹងស៊ើបដឹងពីប្រវត្តិគាត់មិនខាន ។ យាយតាខ្ញុំ រួមជាមួយកូនចៅ និងសាច់ញាតិចំនួន១២នាក់ទៀត បាននាំគ្នាទៅចុះឈ្មោះដើម្បីចាកចេញ ។

ខ្មែរក្រហមបាននាំគ្រួសារយាយខ្ញុំឡើងរថយន្ត រួចបន្តធ្វើដំណើរទៅចំណតភ្លើងរថភ្លើងភ្នំពេញ ។ អ៊ឹ ឡៃ បានបន្តថា មានមនុស្សក្មេង-ចាស់ អ្នកជំងឺ កកកុញនៅលើទូរថភ្លើង ហើយគាត់ត្រូវជិះប្រជ្រៀតគ្នាទំរាំធ្វើដំណើរទៅដល់គោលដៅ ។ រថភ្លើងសម័យខ្មែរក្រហមប្រើថាមពលអុសដុតយកចំហាយ និងមានល្បឿនយឺតៗ ។ នៅលើទូរថភ្លើងនីមួយៗ មានយោធាខ្មែរក្រហមតូចៗស្ពាយកាំភ្លើងជាប់នៅដៃដើម្បីការពារ ។ អ្នកជម្លៀសភាគច្រើនបានខ្វាយខ្វល់ក្នុងចិត្ត ព្រោះមិនដឹងថាអង្គការបញ្ជូនទៅតំបន់ណា និងមានរឿងអ្វីកើតឡើងបន្ទាប់មក? គ្រួសារអ្នកជម្លៀសខ្លះមិននិយាយស្ដីអ្វីទាំងអស់ ចំណែកគ្រួសារខ្លះទៀតបានសួរនាំគ្នាពីស្រុកកំណើត ។ រថភ្លើងបានទៅឈប់នៅខេត្តពោធិ៍សាត់ ក្រុមគ្រួសារយាយខ្ញុំបាននាំគ្នាចុះ ហើយអង្គការក៏បានចែកអង្ករឲ្យដាំបាយហូប ។ បន្ទាប់មក មានយោធាខ្មែរក្រហម និងប្រជាជនមូលដ្ឋាន បានបររទេះមកទទួលប្រជាជនថ្មីទាំងអស់យកទៅដាក់នៅតាមស្រុកភូមិដែលអង្គការថ្នាក់លើបានបែងចែក ។

យាយតាខ្ញុំ និងកូនចៅគាត់បានទៅរស់ទៅស្រុកកណ្ដៀង ខេត្តពោធិ៍សាត់ ។ ពេលទៅដល់ដំបូង អង្គការបានរៀបចំគ្រួសារយាយខ្ញុំឲ្យស្នាក់នៅ និងធ្វើការងាររួមជាមួយប្រជាជនមូលដ្ឋាន និងហូបបាយរួមនៅតាមសហករណ៍ដោយមិនមានការខ្វះខាតឡើយ ។នៅពាក់កណ្ដាលឆ្នាំ១៩៧៦ អង្គការបានតាមដាន និងស្រាវជ្រាវរកមន្ត្រីរាជការជំនាន់ លន់ នល់ យកទៅរៀនសូត្រជាបន្តបន្ទាប់ ។ ប្ដីអ៊ឹ ឡៃ ឈ្មោះ ថាប់ ត្រូវអង្គការហៅយកទៅរៀនសូត្រ ដោយសារគាត់មិនបានលាក់ប្រវត្តិរូបជាអតីតមន្ត្រីបម្រើការនៅសាលាស្រុកកៀនស្វាយ ។ ក្រោយមក អង្គការបានយកគាត់ទៅដាក់គុក និងសម្លាប់ចោល ។ ចំណែកយាយរបស់ខ្ញុំចាប់ផ្ដើមមានជំងឺ និងស្លាប់នៅលើផ្ទះដោយសារគ្មានអាហារបរិភោគ ។ កូនយាយខ្ញុំ ឈ្មោះ អ៊ុយ សារ៉ែន និង អ៊ុយ សាយ ត្រូវខ្មែរក្រហមយកទៅសម្លាប់ចោល ដោយស៊ើបដឹងថា គាត់ទាំងពីរនាក់ធ្វើជាប៉ូលីសជំនាន់ លន់ នល់ ។

នៅឆ្នាំ១៩៧៧ កូនយាយខ្ញុំមួយគ្រួសារទៀតឈ្មោះ អ៊ុយ សារឿន និងកូនប្រសារឈ្មោះ ឡេង ត្រូវអង្គការស៊ើបដឹងថាជាមន្ត្រីរាជការជំនាន់ លន់ នល់ ក៏ត្រូវបានចាប់ខ្លួន និងយកទៅសម្លាប់ចោលដែរ ។ អ៊ឹ ឡៃ បានរៀបរាប់ថា នៅសល់កូនរបស់ សារឿន ម្នាក់ឈ្មោះ អ៊ុយ ភារម្យ នៅរស់នៅឆ្នាំ១៩៧៩ តែក្រោយមកក៏បាត់ដំណឹងដោយមិនដឹងរត់ទៅតាមអ្នកណា ព្រោះឪពុកម្ដាយត្រូវខ្មែរក្រហមសម្លាប់ចោលអស់ ។ ភារម្យ នៅពេលនោះមានអាយុប្រហែល៨ឆ្នាំ ហើយក៏មិនស្គាល់ស្រុកកំណើតដែរ ។ អ៊ឹ ឡៃ មានការសោកស្ដាយរហូតមកដល់សព្វថ្ងៃនៅពេលនឹកឃើញក្មួយម្ដងៗ ដោយសារគាត់មិនបានឃាត់ក្មួយ ។

ក្រោយរបបខ្មែរក្រហម គ្រួសារយាយខ្ញុំដែលខ្មែរក្រហមជម្លៀសទៅខេត្តពោធិ៍សាត់ចំនួន១២នាក់តាមរថភ្លើង ត្រូវបានសម្លាប់ និងស្លាប់ដោយសារការបង្អត់អាហារ ហើយចុងបញ្ចប់នៅសល់តែបីនាក់ប៉ុណ្ណោះត្រឡប់មកស្រុកកំណើតវិញ ។

នៅពេលជិះរថភ្លើងនេះ បានធ្វើឲ្យខ្ញុំនឹកឃើញពីរឿងរ៉ាវជាច្រើនដែលកើតឡើងចំពោះក្រុមគ្រួសារខ្ញុំក្នុងអំឡុងរបបខ្មែរក្រហម ។ រឿងរ៉ាវទាំងនេះបានកន្លងផុតទៅជាច្រើនទសវត្សរ៍មកហើយ តែនៅតែដក់ជាប់នៅក្នុងចិត្តខ្ញុំ និងក្រុមគ្រួសារដែលនៅរស់រានមានជីវិតពីរបបនេះ ។

**សុខ ខណ្ណៈ**

# ៣ថ្ងៃ ប្រែជា ៣ឆ្នាំ

*"សូមបងប្អូនចេញពីផ្ទះរយៈពេល៣ថ្ងៃ ដើម្បីងាយស្រួលរៀបចំសណ្តាប់ធ្នាប់ក្នុងទីក្រុង បងប្អូនមិនបាច់យករបស់ទ្រព្យទៅជាមួយទេ ព្រោះបីថ្ងៃក្រោយបងប្អូននឹងបានត្រឡប់មកផ្ទះវិញហើយ" ។*

នេះជាការប្រកាសរបស់យោធាខ្មែរក្រហម បន្ទាប់ពីទទួលបានជ័យជម្នះទាំងស្រុងលើរបបលន់ នល់ ។ ជាក្មេងស្រីម្នាក់ដែលមានអាយុ៩ឆ្នាំ នៅពេលដែលខ្មែរក្រហមចូលកាន់កាប់ប្រទេសនៅថ្ងៃ១៧ មេសា ឆ្នាំ ១៩៧៥ ម្តាយរបស់ខ្ញុំ អ៊ុក មុំ និងក្រុមគ្រួសារត្រូវបានខ្មែរក្រហមជម្លៀសចេញពីទីរួមខេត្តព្រៃវែងទៅកាន់ភូមិចេក ឃុំពាមរោង ស្រុកស្វាយអន្ទរ ដែលស្ថិតនៅក្នុងខេត្តព្រៃវែងដដែល ។

ប្រជាជនថ្មី ឬប្រជាជន១៧មេសា គឺជាពាក្យដែលខ្មែរក្រហម


ម្តាយរបស់ សេរីរតនា

ប្រើសំដៅលើប្រជាជនជម្លៀសក្រោយថ្ងៃ១៧ មេសា ១៩៧៥ ។ អ្នកជម្លៀសថ្មីទាំងអស់ តែងតែត្រូវទទួលការមាក់ងាយ ធ្វើបាបពីសំណាក់អ្នកមូលដ្ឋានចាស់ ។ អ្នកមូលដ្ឋានចាស់បានចាត់ទុកអ្នកជម្លៀសទាំងអស់ ជាខ្មាំងដែលត្រូវតែតាមដាន និងលត់ដំឲ្យបានខ្លាំងក្លា ។ ដំណាលប្រាប់ខ្ញុំដោយទឹកភ្នែករលីងរលោង ម្តាយខ្ញុំរម្លឹកពីកុមារភាពរបស់គាត់ឡើងវិញ ពីការលំបាក និងអត់ឃ្លានដែលគាត់ និងគ្រួសារបានជួបប្រទះក្នុងរបបខ្មែរក្រហម ។

ពេលទៅដល់ភូមិចេកដំបូង អង្គការបានបំបែកគ្រួសារម្តាយខ្ញុំឲ្យទៅធ្វើការនៅកន្លែងផ្សេងៗពីគ្នា ។ យាយតារបស់ខ្ញុំ ត្រូវបានអង្គការចាត់តាំងឲ្យដឹកព្រែក ហេតុនេះ ម្តាយខ្ញុំ និងបងប្អូន៦នាក់ត្រូវរស់នៅឆ្ងាយពីឪពុកម្តាយរហូត ។ ជាកូនប្រជាជនថ្មី ម្តាយខ្ញុំត្រូវបានអង្គការចាត់តាំងឲ្យចូលធ្វើការនៅកងកុមារ ដោយឲ្យរើសអាចម៍គោ និងឲ្យបាយជ្រូក ។ ទោះបីជាកុមារក៏ដោយ ក៏ម្តាយខ្ញុំធ្វើការគ្មានពេលសម្រាកដែរ ។ ពីមួយថ្ងៃទៅមួយថ្ងៃ ការងាររបស់គាត់កាន់តែច្រើន និងលំបាកឡើង ប៉ុន្តែរបបអាហារដែលទទួលបានគឺមិនសមល្មមនឹងកម្លាំងពលកម្មរបស់គាត់នោះទេ ។ ដើម្បីបំពេញនូវសេចក្តីស្រេកឃ្លាន ពេលដាក់បាយជ្រូក ម្តាយខ្ញុំ តែងតែលួចបាយជ្រូកហូប និងពេលខ្លះ គាត់ និងបងប្អូនទាំង៦ លួចចាប់កណ្តុរតាមវាលស្រែមកធ្វើម្ហូបថែមទៀតផង ។

សម្លឹងមកកាន់ខ្ញុំ គាត់បានរំឭកពីហេតុការណ៍មួយដែលបានកើតឡើងចំពោះគាត់ ហើយសឹងតែធ្វើឲ្យគាត់បាត់បង់ជីវិតទៀតផង ។ នៅយប់មួយ គាត់ត្រូវបានអង្គការហៅ ដោយប្រាប់ថា "ទៅកសាង" ដោយសារតែគាត់ធ្វេសប្រហែសធ្វើឲ្យជ្រូកបាក់ជើង ។ ម្តាយខ្ញុំទៅជាមួយឈ្លបខ្មែរក្រហម ទាំងគាត់មិនដឹងថា "កសាង" នោះ ជាអ្វីផង ។ ពេលទៅដល់កន្លែងប្រជុំ មិត្តប្រធានអង្គប្រជុំបានក្រោកឡើង និយាយគំហកដាក់ម្តាយខ្ញុំខ្លាំងៗថា "មិត្តដឹងថា ក្បាលរបស់មិត្ត គឺអង្គការជាអ្នកសង្គ្រោះមកទេ បើអង្គការមិនសង្គ្រោះទេ ម៉្លេះមិត្តត្រូវពួកសក្តិភូមិ លន់ នល់ សម្លាប់ចោលអស់

ហើយ អ៊ីចឹងមិត្តត្រូវដឹងគុណអង្គការទៅ!» ។ បន្ទាប់មក មិត្តប្រធានក៏ឲ្យម្ដាយខ្ញុំក្រោកឡើងប្ដេជ្ញាថា «ខ្ញុំសូមប្ដេជ្ញាថា ឈប់ឲ្យមានរឿងដូចនេះ កើតឡើងទៀតហើយ និងមិនឲ្យអង្គការខកចិត្តទៅ!» ។ នេះចាត់ទុកជាសំណាងណាស់ ដែលអង្គការលើកលែងទោសឲ្យ និងគ្រាន់តែប្រជុំកសាងកំហុស ប្រហែលអាចមកពីគាត់នៅក្មេងពេក ទើបអង្គការមិនប្រកាន់ទោស ។

រឿងរ៉ាវជាច្រើនដែលម្ដាយរបស់ខ្ញុំមិនអាចរៀបរាប់អស់ពីរបបខ្មែរក្រហមនេះ ដោយសារតែ តែគាត់មានអារម្មណ៍កាន់តែឈឺចាប់នៅពេលដែលរំឭកពីរបបនេះឡើងវិញ ។ ប៉ុន្តែទោះបីជាគាត់មិនអាចប្រាប់ឲ្យអស់សេចក្ដី ក៏គាត់តែងតែដំណាលប្រាប់ជារឿយៗ នៅពេលគាត់នឹកឃើញម្ដងៗ និងតែងតែដាស់តឿនឲ្យកូនៗយល់ពីការលំបាកដែលគាត់ធ្លាប់បានឆ្លងកាត់ ។

ក្រោយរបបខ្មែរក្រហមដួលរលំ ម្ដាយរបស់ខ្ញុំបានបាត់បង់បងប្អូនចំនួន៣នាក់ (ប្រុសពីរនាក់ និងស្រីម្នាក់) ។ បងប្រុសទី១បានស្លាប់ដោយសារអត់អាហារ និងពីរនាក់ទៀតស្លាប់ដោយសារជំងឺ គ្មានថ្នាំព្យាបាល ។

បន្ទាប់ពីរស់នៅឆ្លងកាត់ការឈឺចាប់ពេញមួយរបបនេះ ម្ដាយរបស់ខ្ញុំមិនដែលបណ្ដោយឲ្យជីវិតបន្តធ្លាក់ចុះនោះទេ ។ ទោះបីជាគ្រួសារក្រីក្រក៏ដោយ ប៉ុន្តែការតស៊ូព្យាយាម ទើបធ្វើឲ្យគាត់ក្លាយជាគ្រូពេទ្យរហូតដល់សព្វថ្ងៃ ។

គ្មាននរណាម្នាក់មិនចង់បំភ្លេចនោះទេ ប៉ុន្តែការឈឺចាប់ធ្វើឲ្យមនុស្សមិនអាចបំភ្លេចបាន ។ សម្រាប់អ្នកដែលធ្លាប់ឆ្លងកាត់របបខ្មែរក្រហម តែងតែចង់ឲ្យកូនចៅជំនាន់ក្រោយយល់ពីរឿងរ៉ាវរបស់គាត់ មិនថាតែម្ដាយរបស់ខ្ញុំ សូម្បីតែតាយាយរបស់ខ្ញុំ ក៏តែងតែរំឭកប្រាប់ជារឿយៗដែរ ។

ដូច្នេះខ្ញុំយល់ថា សម្រាប់ខ្ញុំជាអ្នកជំនាន់ក្រោយមិនអាចជួយអ្វីបាន ប៉ុន្តែការស្ដាប់ និងការសួរនាំពីជីវិតគាត់នារបបនោះ អាចជាផ្នែកមួយសម្រាលការឈឺចាប់ និងដើម្បីឲ្យគាត់មានអារម្មណ៍ថាកូនរបស់គាត់ខ្វាយខ្វល់ និងយល់ពីទុក្ខលំបាករបស់គាត់ បើទោះបីជាមិនអាចកែប្រែអ្វីបានទាំងស្រុងក៏ដោយ ។ **ធួន សេរីរតនា**



ម្ដាយរបស់ សេរីរតនា និងក្រុមគ្រួសារ

# ពូរបស់ខ្ញុំក្នុងសម័យខ្មែរក្រហម

ពូរបស់ខ្ញុំមានស្រុកកំណើតនៅខេត្តតាកែវ ។ គាត់រៀនដល់ថ្នាក់ទី៧ នៅពេលមានអាយុ១៧ឆ្នាំ តែគាត់បានសម្រេចចិត្តឈប់រៀន រួចហើយត្រឡប់មកធ្វើស្រែចម្ការវិញ ។ ក្រោយរដ្ឋប្រហារថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ ផ្ទះពូរបស់ខ្ញុំ បានស្ថិតក្នុងតំបន់រំដោះ ។ ពេលនោះ ខ្មែរក្រហមបានជ្រើសរើសគាត់ឲ្យចូលយោធាដើម្បីប្រយុទ្ធប្រឆាំងនឹងរបប លន់ នល់ ។ ខ្មែរក្រហមថែមទាំងបានប្រកាសថា ការតស៊ូប្រយុទ្ធនេះ គឺដើម្បីដណ្តើមអំណាចថ្វាយសម្តេច ព្រះនរោត្តម សីហនុ វិញ ។

ដោយសារភ័យខ្លាចការវាយប្រយុទ្ធគ្នា ពូរបស់ខ្ញុំបានបដិសេធមិនចូលធ្វើយោធាតាមការជ្រើសរើស ដូច្នេះហើយទើបខ្មែរក្រហម បានចាត់គាត់ឲ្យគាត់នៅធ្វើស្រែចម្ការក្នុងភូមិដដែល ។ មួយរយៈក្រោយមក ខ្មែរក្រហមបានចាត់តាំងពូរបស់ខ្ញុំឲ្យទៅលើកទំនប់ និងជីកប្រឡាយ នៅក្បែរៗភូមិ ។

នៅអំឡុងពេលនោះ ការវាយប្រយុទ្ធរវាងខ្មែរក្រហម និងកងទ័ព លន់ នល់ កើតមានឡើងជាបន្តបន្ទាប់ ដូច្នេះខ្មែរក្រហមក៏បន្តកេណ្ឌយោធាបន្ថែមទៀត ហើយពូរបស់ខ្ញុំក៏មានឈ្មោះចូលយោធាខ្មែរក្រហមដែរ ។ ប៉ុន្តែគាត់បានបដិសេធជាលើកទីពីរ ដោយសុខចិត្តនៅធ្វើការងារលំបាកៗតាមការចាត់របស់ខ្មែរក្រហម ។ សង្រ្គាមបានបន្តសម្លាប់ជីវិតយោធាខ្មែរក្រហមជាច្រើន ដូច្នេះហើយពូរបស់ខ្ញុំមិនអាចគេចវេសដូចពេលមុនបានទេ ទោះបីជាគាត់មិនចង់ទៅប្រយុទ្ធក៏ដោយ គឺខ្មែរក្រហមបានបញ្ជូនគាត់ឲ្យទៅសមរភូមិ ដើម្បីយកសាកសពយុទ្ធជនដែលបានពលីជីវិតលើសមរភូមិ ស្ថិត



រូបទីប្រាំរាប់ពីឆ្វេង ៖ ពូរបស់ ធា ស្រ៊ុន រួមជាមួយសាច់ញាតិក្នុងពិធីបុណ្យ នៅទសវត្សរ៍ ឆ្នាំ១៩៨០

ក្នុងខេត្តតាកែវ ។ នេះជាលើកទីមួយហើយដែលពូខ្ញុំបានមកធ្វើការងារបែបនេះ គឺគាត់បានទទួលភារកិច្ចយកសាកសពមកកប់នាពេលយប់ ។ ចំណែកពេលថ្ងៃ ខ្មែរក្រហមបានចាត់តាំងគាត់ឲ្យទៅកើបលាមកពីបន្ទន់នៅតាមផ្ទះប្រជាជនមកលាយជាមួយផេះ រួចយកទៅហាលថ្ងៃ ដើម្បីធ្វើជីដាក់ស្រែ ។

មកដល់ឆ្នាំ១៩៧៥ សង្គ្រាមត្រូវបានបញ្ចប់ ខ្មែរក្រហមបានកាន់កាប់ទីក្រុងភ្នំពេញនាថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ។ ខ្មែរក្រហមបានប្រាប់ពូរបស់ខ្ញុំឲ្យត្រឡប់មកផ្ទះវិញ ព្រោះសង្គ្រាមបានចប់ហើយ ។ គ្រាន់តែឮដូចច្នេះ ក្នុងចិត្តរបស់គាត់សប្បាយយ៉ាងខ្លាំង រួចហើយគាត់ក៏ធ្វើដំណើរត្រឡប់មកផ្ទះវិញ ។

មកដល់ច្រកផ្លូវចូល ពូរបស់ខ្ញុំឃើញមនុស្សជាច្រើនឈរផ្តុំគ្នានៅមុខផ្ទះ និងខាងក្រោមផ្ទះ ។ ពេលនោះ មេភូមិបានដើរមកប្រាប់គាត់ថា ផ្ទះគាត់ត្រូវបានអង្គការយកធ្វើរោងបាយសម្រាប់សហករណ៍ហើយ ។ ពូរបស់ខ្ញុំក៏បានដើរតម្រង់ទៅរកឪពុកម្តាយគាត់ដែលកំពុងឈរជាមួយហ្វូងមនុស្សអ៊ូអរនៅមុខផ្ទះ ។ ឪពុកពូរបស់ខ្ញុំបានប្រាប់ពូខ្ញុំថា គ្រួសារយើងនឹងត្រូវជម្លៀសចេញទៅនៅតំបន់ផ្សេងជាមួយនឹងប្រជាជនថ្មី ព្រោះអង្គការសម្គាល់ឃើញគ្រួសារយើងមិនបានបម្រើអង្គការអស់ពីចិត្តពីថ្លើមនោះទេ ។ ឮដូចនេះ ពូរបស់ខ្ញុំបាននឹកឃើញមូលហេតុ ដែលគាត់មិនព្រមចូលធ្វើយោធាតាមការជ្រើសរើសរបស់អង្គការពីមុនមក ។

លុះព្រឹកស្អែក ពូរបស់ខ្ញុំបានដើរជាមួយឪពុកម្តាយ និងបងប្អូន សំដៅទៅកាន់ស្ថានីយរថភ្លើងខេត្តតាកែវ រួចហើយឡើងជិះរថភ្លើងទាំងចិត្តមិនស្ងប់ ព្រោះមិនដឹងថាខ្មែរក្រហមដឹកយកទៅសម្លាប់ឬយ៉ាងណានោះទេ ។ ពូរបស់ខ្ញុំបានអង្គុយមើលមុខឪពុកគាត់ទាំងទឹកមុខស្រងូតស្រងាត់ ។

ពូរបស់ខ្ញុំធ្វើដំណើរតាមរថភ្លើងអស់មួយយប់ ទើបអ្នកបើកឈប់រថភ្លើងសម្រាកនាពេលព្រឹកព្រលឹម ។ ពេលក្រោកពីដំណេក ពូខ្ញុំមើលតាមបង្អួចរថភ្លើងឃើញពន្លឺព្រះអាទិត្យទើបនឹងរះ និងឃើញតំបន់មួយយ៉ាងស្អាតដែលគាត់មិនធ្លាប់ឃើញពីមុនមក ។ អ្នកដំណើរដែលអង្គុយក្បែរគាត់បានជជែកគ្នាថា នេះហើយទីក្រុងភ្នំពេញ ។ គ្រាន់តែឮប៉ុណ្ណឹង ពូរបស់ខ្ញុំមានអារម្មណ៍អរសប្បាយដែលបានឃើញទីក្រុងភ្នំពេញជាលើកដំបូង ។

កំពុងអង្គុយគយគន់ទីក្រុង គាត់ឃើញឡានយោធាប្រាំគ្រឿង បើកមកកាន់រថភ្លើងដែលកំពុងឈប់ស្ងៀម ។ គ្រាន់តែឡានមកជិតដល់ ក្លិននំបុ័ងដែលទើបចេញពីឡថ្មីៗ បានភាយកាត់ច្រមុះរបស់គាត់ ស្របពេលគាត់កំពុងឃ្លានអាហារពេលព្រឹក ។ ភ្លាមៗនោះ ខ្មែរក្រហមបានលើកនំបុ័ងដាក់ទៅក្នុងទូរថភ្លើងទាំងអស់ ហើយរថភ្លើងក៏បានបន្តដំណើរទៅមុខទៀត ដោយអ្នកប្រជាជនជម្លៀសដែលជិះនៅលើទូរថភ្លើងមិនបានទទួលនំបុ័ងនោះសម្រាប់អាហារពេលព្រឹកទេ ។

រថភ្លើងបានធ្វើដំណើរអស់រយៈពេលមួយយប់ពីរថ្ងៃ ទើបទៅដល់គោលដៅ ។ ពូរបស់ខ្ញុំ និងគ្រួសារបាននាំគ្នាចុះពីរថភ្លើង ហើយឪពុកពូរបស់ខ្ញុំក៏ប្រាប់សមាជិកគ្រួសារទាំងអស់ថា នេះជាខេត្តបាត់ដំបង ។ នៅទីនោះ មានខ្មែរក្រហមមួយក្រុមចាំទទួលអ្នកជម្លៀសដែលជិះលើរថភ្លើង រួមទាំងគ្រួសារពូខ្ញុំដែរ ដើម្បីទៅស្នាក់នៅផ្ទះមួយនៅក្បែរនោះ ។

ពូរបស់ខ្ញុំស្នាក់នៅក្នុងផ្ទះនោះមួយយប់ លុះព្រឹកឡើង គាត់បានឃើញគោយន្តដប់គ្រឿងចតនៅពីមុខផ្ទះ ។ ខ្មែរក្រហមបានហៅអ្នកជម្លៀសមកថ្មីទាំងអស់ឡើងលើគោយន្ត រួចហើយបន្តដំណើរទៅមុខទៀត ។ នៅអំឡុងពេលធ្វើដំណើរ ពូរបស់ខ្ញុំមានអារម្មណ៍ថាកាន់តែឆ្ងាយពីភូមិ និងកាន់តែស្ងាត់ទៅៗ ។

ពេលរសៀលបន្តិច គ្រួសាររបស់ពូខ្ញុំបានទៅដល់កន្លែងមួយដែលគ្មានអ្វីទាំងអស់ គឺមានតែព្រៃប៉ុណ្ណោះនៅព័ទ្ធជុំវិញ ។ ខ្មែរក្រហមបានចាត់តាំងឲ្យអ្នកជម្លៀសទាំងអស់ឆ្ការព្រៃ និងកាប់ឈើដើម្បីយកមកសង់ផ្ទះសម្រាប់ស្នាក់នៅ ។

មួយខែក្រោយមក គ្រោងផ្ទះក៏បានសាងសង់រួចរាល់ គឺនៅចាំតែប្រក់ដំបូល និងបាំងជញ្ជាំងតែប៉ុណ្ណោះ ។ ផ្ទុយទៅវិញ ខ្មែរក្រហមបានជម្លៀសប្រជាជនថ្មីទាំងនេះឲ្យទៅរស់នៅភូមិក្បែរនោះវិញ ។ ទោះបីជាបានទៅរស់ក្នុងភូមិក៏ដោយ ក៏ពូខ្ញុំមិនបានរស់នៅជុំគ្រួសារគាត់ដែរគឺអង្គការបានចាត់តាំងគាត់ឲ្យទៅលើកទំនប់នៅអាងត្រពាំងថ្មជាមួយនឹងប្រជាជនថ្មីដទៃទៀត ។ ប៉ុន្តែ ដោយសារពូខ្ញុំមិនអាចទ្រាំទ្រការងារនៅទីនោះបាន ដូច្នេះគាត់ក៏លួចរត់មករស់នៅក្នុងភូមិជាមួយឪពុកម្តាយ និងធ្វើស្រែចម្ការនៅក្នុងភូមិរហូតដល់របបខ្មែរក្រហមដួលរលំ ។ **កែវ ធាស្រ៊ុន**

# រឿងរ៉ាវដែលខ្ញុំបានដឹងពីម្តាយខ្ញុំ

ពេលដែលខ្មែរក្រហមចូលមកទីក្រុងភ្នំពេញនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ បានជម្លៀសប្រជាជនចេញពីរាជធានីអស់គ្មានសល់ ។ ប្រជាជនស្លូតត្រង់ជាង២លាននាក់ត្រូវបានស្លាប់ដោយការអត់ឃ្លាន ការធ្វើការហួសកម្លាំង ជំងឺ និងសម្លាប់ ក្នុងរបបឃោរឃៅមួយនេះ ។ ប្រជាជនជាច្រើននាក់ត្រូវបាត់បង់បែកបាក់ពីក្រុមគ្រួសារ ដោយអ្នកខ្លះមិនទាំងប្រាកដថា អ្នកដែលបាត់ខ្លួននោះស្លាប់ឬរស់ទេ ។

នៅថ្ងៃជម្លៀសនោះដែរ ម្តាយរបស់ខ្ញុំមានអាយុទើបតែ៦ឆ្នាំប៉ុណ្ណោះ ។ គាត់ជាកូនច្បងក្នុងគ្រួសារ ដែលមានប្អូនស្រីបន្ទាប់ឈ្មោះ សុជាតិ ហៅ ជាតិ មានអាយុ៣ឆ្នាំ ហើយយាយរបស់ខ្ញុំក៏មានផ្ទៃពោះជិតគ្រប់ខែកូនបន្ទាប់ដែរ ។ នៅថ្ងៃទី១៩ ខែមេសា ឆ្នាំ១៩៧៥ ដែលជាថ្ងៃទីបីនៃថ្ងៃជម្លៀសនោះ ម្តាយមីងរបស់ខ្ញុំក៏បានចាប់កំណើត ។ សំណាងល្អ នៅពេលនោះ យាយរបស់ខ្ញុំបានជួបនឹងគ្រូពេទ្យឆ្មបម្នាក់ដែលបានជួយបង្កើតកូនឲ្យ ដោយមានប្រដាប់ប្រដារពេទ្យត្រឹមត្រូវ ។ ម្តាយមីងខ្ញុំបានកើតនៅមុំច្បារអំពៅ ទើបអ្នកគ្រប់គ្នាហៅឈ្មោះក្រៅគាត់ថា ពៅ និងឈ្មោះក្នុងបញ្ជីជាតិគឺ ជីវ៉ា ។

មុនថ្ងៃដែលខ្មែរក្រហមចូលមក ឪពុករបស់យាយខ្ញុំ (តាទួត) បានមកពីស្រុកស្អឹ ខេត្តកំពង់ចាម ដើម្បីមកលេងកូន និងចៅ ។ ចំណែកឯយាយទួតរបស់ខ្ញុំពុំបានមកភ្នំពេញតាមតាទួតទេ ដោយ


រូបទីមួយរាប់ពីស្តាំ មុនីកញ្ញា ជាមួយនឹងក្រុមគ្រួសារ

សារតែគាត់ត្រូវនៅមើលថែកូនប្រុសពៅរបស់គាត់ដែលមានជំងឺស្វិតដៃជើងនៅឯផ្ទះ ។ គួរឲ្យស្តាយ តាទួតពុំអាចវិលទៅស្រុកវិញបានដោយសារប្រទេសត្រូវខ្មែរក្រហមដណ្តើមគ្រប់គ្រងទាំងស្រុង ។

ពេលដែលខ្មែរក្រហមជម្លៀស តាទួត និងយាយតា ម្តាយខ្ញុំ និងប្អូនតូចៗ ព្រមទាំងសាច់ញាតិមួយចំនួនបានចាកចេញពីទីក្រុងភ្នំពេញឆ្ពោះទៅស្រុកស្អឹដោយថ្មើរជើង ។ គួរបញ្ជាក់ដែរថា ផ្ទះរបស់យាយទួតតាទួតនៅស្អឹកាលពីសង្គ្រាមគឺត្រូវបានបំផ្លាញទាំងស្រុងដោយការទម្លាក់គ្រាប់បែករបស់អាមេរិកាំង ។ ដូច្នេះ តាទួតក៏បានសាងសង់ផ្ទះតូចល្មមរស់នៅបន្តទៀត នៅស្រុកស្អឹដដែល ។

នៅតាមផ្លូវធ្វើដំណើរទៅស្រុកស្អឹ អ្នកទាំងអស់គ្នាត្រូវដើរជាក្រុមតូចៗ ដើម្បីងាយស្រួលជួយមើលគ្នា ព្រោះមានក្មេងៗច្រើន ។ ម្តាយរបស់ខ្ញុំដើរជាមួយតាទួត មីងជាតិ ដើរជាមួយតាខ្ញុំ និងមីងពៅដែលទើបនឹងកើត ត្រូវបែកគ្នាបីម្តងម្នាក់ ដោយសារតែយាយខ្ញុំមានសុខភាពខ្សោយផង ។

ទៅដល់ស្រុកស្អឹ ប្រជាជនត្រូវបែងចែកជាប្រជាជនថ្មី និងប្រជាជនចាស់ ។ ប្រជាជនថ្មី គឺជាប្រជាជនជម្លៀសចេញពីទីក្រុង ឯប្រជាជនចាស់គឺជាអ្នករស់នៅស្រុកភូមិផ្ទាល់ និងជាអ្នកដែលបានទំនុកបម្រុងដល់ខ្មែរក្រហម អំឡុងពេលតស៊ូបដិវត្តន៍ ។ ដោយសារតែតាទួតយាយទួតជាអ្នករស់នៅស្រុកស្អឹនេះ ទើបគ្រួសារម្តាយខ្ញុំដែលជម្លៀសទៅមិនសូវមានការលំបាក ឬធ្វើបាបពីសំណាក់ប្រជាជនមូលដ្ឋាននៅទីនោះ ។ ចំពោះប្រជាជនថ្មីផ្សេងទៀត ត្រូវខ្មែរក្រហមយកទៅធ្វើទារុណកម្ម និងសម្លាប់ ។

ចំពោះអ្នកថ្មី ខ្មែរក្រហមតែងតែស៊ើបសួរនាំពីប្រវត្តិគ្រួសារ និងការងារនៅរបបចាស់ ។ ជាក់ស្តែង ម្តាយខ្ញុំដែលមានវ័យទើបតែ៦ឆ្នាំ ដោយមិនទាន់ដឹងការរាក់ជ្រៅផង ត្រូវខ្មែរក្រហមសួរពីការងាររបស់ជីតាខ្ញុំថា «តើឪពុករបស់ឯងធ្វើអ្វីពីមុនមក?» ម្តាយខ្ញុំក៏ឆ្លើយប្រាប់ត្រង់ថា «ឪពុករបស់គាត់ធ្វើជាគ្រូពេទ្យ» ។ ក្រោយពីប្រាប់ហើយ ខ្មែរក្រហមក៏មិនបានដេញដោល ឬធ្វើទុក្ខបុកម្នេញអ្វី

ដល់គ្រួសារជីតាខ្ញុំដែរ ។

បន្ទាប់ពីដឹងប្រវត្តិរបស់ជីតាខ្ញុំរួចមក ខ្មែរក្រហមមានផែនការយកគាត់ទៅសម្លាប់បីដង ប៉ុន្តែដោយភ័ព្វសំណាង ជីតាខ្ញុំបានរួចផុតពីការប៉ុនប៉ងសម្លាប់នេះជាបន្តបន្ទាប់ ។ លើកទី១ ខ្មែរក្រហមបានមកហៅគាត់ឲ្យទៅឃ្វាលគោ ដោយដឹងពីឧបាយកលមួយនេះ ជីតាខ្ញុំបានរត់ទៅពួនឆ្ងាយពីភូមិ ។ ពេលនោះ កងឈ្លបបានស្វែងរកគាត់ តែមិនឃើញក៏ឈប់រកបន្តទៀត ។ លើកទីពីរ ខ្មែរក្រហមបានកុហកជីតាខ្ញុំឲ្យទៅធ្វើការនៅក្នុងព្រៃ ប៉ុន្តែ ដោយឈ្លបទាំងនោះមានចិត្តអាណិតដល់គាត់ ក៏បានទុកជីវិតឲ្យគាត់ ហើយឲ្យគាត់ធ្វើការនៅក្នុងព្រៃនោះបន្ត ។ លើកទីបី ខ្មែរក្រហមបានមកយកជីតាខ្ញុំជាមួយនឹងមនុស្សពីរនាក់ផ្សេងទៀត ដោយប្រាប់ថា យកទៅកសាង ។ អ្នកទាំងអស់គ្នាសុទ្ធតែដឹងថា ពាក្យថា “កសាង” គឺ “សម្លាប់” ទើបអ្នកទាំងពីរនាក់ដែលទៅជាមួយជីតាខ្ញុំនាំគ្នារត់គេចខ្លួន ហើយក៏មិនដឹងថាជីតាខ្ញុំគាត់ធ្វើយ៉ាងណាដែរ ទើបរួចខ្លួនត្រឡប់មកផ្ទះវិញបាន ។ អ្នកគ្រប់គ្នានៅក្នុងផ្ទះយំគ្រប់គ្នា ព្រោះដឹងថា ជីតាខ្ញុំលើកនេះ ពិតជាមិនអាចរួចខ្លួនទៀតឡើយ ។ យាយរបស់ខ្ញុំដែលទើបនឹងសម្រាលកូនម្នាក់ទៀត ឈ្មោះ សីហា ហៅ ទូច កំពុងតែយំស្រណោះដល់តា ក៏បានឮសំឡេងរបស់តា ហើយយាយស្ទើរតែមិនជឿថា តានៅរស់នោះទេ ។

ថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ប្រទេសកម្ពុជាត្រូវបានរំដោះពីរបបខ្មែរក្រហម ប្រជាជនម្នាក់ៗបានត្រឡប់ទៅរកស្រុកកំណើត ផ្ទះសម្បែង និងបងប្អូនញាតិមិត្តរបស់ខ្លួនវិញ ។ គ្រួសារម្តាយខ្ញុំបានត្រឡប់មកទីក្រុងភ្នំពេញវិញ នៅខែកញ្ញា ឆ្នាំ១៩៧៩ ។ អ្នកទាំងអស់គ្នាបានចាប់ផ្តើមជីវិត និងជីវភាពជាថ្មី ។ ជីតារបស់ខ្ញុំបានចូលរៀននយោបាយមជ្ឈិម (សកលវិទ្យាល័យភូមិន្ទភ្នំពេញបច្ចុប្បន្ន) ។ គាត់បានបន្តអាជីពជាគ្រូពេទ្យ រហូតដល់ឆ្នាំ១៩៩៧ ទើបចូលនិវត្តន៍ ។ ចំណែកយាយរបស់ខ្ញុំ ជាមេផ្ទះមើលថែកូនស្រីទាំងប្រាំ រួមទាំងម្តាយខ្ញុំផង ។ ចំពោះម្តាយ និងមីងខ្ញុំទាំងប្អូននាក់បានរៀនសូត្រចេះដឹង និងមានការងារធ្វើគ្រប់ៗគ្នា ។

ខ្ញុំជាចៅទីពីរក្នុងចំណោមចៅទាំងដប់នាក់របស់តាយាយ ។ គ្រួសាររបស់យើងជាគ្រួសារធំមួយរស់នៅយ៉ាងកក់ក្តៅ ។

**គុណាឧុឌ្ឍ មុនីកញ្ញនា**



ម្តាយរបស់ មុនីកញ្ញនា និងក្រុមគ្រួសារ

# ជីវិតតស៊ូរបស់ម្តាយខ្ញុំ

ពេលមុនពេលដែលរបបប៉ុល ពត មកដល់ម្តាយរបស់ខ្ញុំ ឡាំ សុវត្ថិ រស់នៅក្នុងភូមិខ្នាចរមាស ឃុំរោងជ្រៃ ស្រុកបាត់ដំបង ខេត្តបាត់ដំបង ដែលកាលនោះគាត់មានអាយុ១៦ឆ្នាំ ។ គាត់រស់នៅក្នុងគ្រួសារដែលមានបងប្អូន៧នាក់ ហើយគាត់ជាកូនទី៣ មានឪពុកជាទាហាន លន់ នល់ និងម្តាយជាអ្នកលក់ដូរបន្តិចបន្តួចគ្រាន់នឹងជួយសម្រួលជីវភាពគ្រួសារ ។ ក្នុងអំឡុងពេលនោះ គាត់រស់នៅជុំគ្នាជាមួយបងប្អូនដូចគ្រួសារដទៃ និងបានទទួលការសិក្សាដូចធម្មតាដែលគាត់រៀននៅក្នុងកម្រិតទី៤ (កម្រិតមធ្យមសិក្សាបច្ចុប្បន្ន) ។

នៅខែមករា ឆ្នាំ១៩៧៥ ម្តាយរបស់ខ្ញុំបានភៀសខ្លួនទៅរស់ក្នុងទីរួមខេត្ត ដោយបានសុំផ្ទះសាច់ញាតិខាងយាយរស់នៅ


កែវលីដែត និងម្តាយ

បណ្តោះអាសន្ន ព្រោះផ្ទះនៅឯស្រុកនោះទទួលការគំរាមកំហែងពីយោធាខ្មែរក្រហមខ្លាំងពេក ។ ផ្ទុយមកវិញនៅថ្ងៃទី២២ ខែមេសា គាត់បានត្រឡប់មកផ្ទះចាស់វិញ ដោយសារយោធាខ្មែរក្រហមចាប់ផ្តើមបណ្តេញប្រជាជនចេញពីទីរួមខេត្តទាំងអស់ ។ នៅពេលជាមួយគ្នានោះ មានយោធាខ្មែរក្រហមមកប្រាប់ឲ្យប្រជាជនចាកចេញពីទីរួមខេត្តប្រមាណ ៣ ឬ៤ថ្ងៃ ដើម្បីបោសសំអាត និងរៀបចំទីក្រុង ដែលទាហានទាំងនោះមានកាំភ្លើងជាប់តាមខ្លួន ។ យោធាទាំងនោះបានមកប្រាប់ប្រជាជនត្រឹមរយៈពេល៣ម៉ោង មុនពេលបណ្តេញប្រជាជនចេញ ។

នៅពេលចាកចេញគាត់ពុំបានយកអ្វីតាមខ្លួននោះទេ ក្រៅពីអង្ករបន្តិចបន្តួចគ្រាន់ទុកដាំបាយហូបក្នុងគ្រួសារ ។ ដំណើរនេះគឺធ្វើដំណើរដោយថ្មើរជើងអស់រយៈពេល៣យប់ ៣ថ្ងៃ ទើបដល់គោលដៅ ។ នៅពេលធ្វើដំណើរ ម្តាយរបស់ខ្ញុំត្រូវរើសអង្ករដែលប្រជាជនធ្វើជ្រុះតាមផ្លូវមកសន្សំទុកសម្រាប់ទុកដាំហូបពេលក្រោយ ។

ម្តាយរបស់ខ្ញុំធ្វើដំណើរអស់រយៈពេល៣ថ្ងៃ ហើយដោយសារនឿយហត់គាត់ក៏ទៅសុំស្នាក់នៅវត្តបានប្រហែល៥ថ្ងៃ យោធាក៏បានបណ្តេញទៅនៅក្នុងជំរំ ព្រោះផ្ទះចាស់ដែលធ្លាប់រស់នៅត្រូវដុតឆេះចោលទាំងអស់ ។ រស់នៅក្នុងជំរំដែលមានឈ្មោះថា ជំរំវល្លិយាវ រយៈពេលមួយខែទើបគ្រួសារគាត់ជុំគ្នា ហើយដើររកស្បៀវមកទុកប្រក់ខ្ទមនៅ ។ នៅពេលទៅដល់ភ្លាម ការងារដំបូងដែលអង្គការឲ្យគាត់ធ្វើ គឺពូនដីដាំដំឡូងជ្វាសម្រាប់ឧបត្ថម្ភដល់ការរស់នៅក្នុងជំរំបណ្តោះអាសន្ននោះ ។ ពេលកំពុងធ្វើការពុំមានអ្វីហូបទេក្រៅពីបបរប៉ុន្មានកំប៉ុងនឹងត្រកួន ស្លឹករុក្ខជាតិផ្សេងៗ ។ ម្តាយរបស់ខ្ញុំមិនចាំរយៈពេលរស់នៅជំរំទេ តែគាត់ដឹងថាត្រូវហូបរបស់នេះ រហូតទាល់តែដំឡូងចុះមើមដើម្បីយកមកលាយជាមួយបបរដើម្បីគាត់បន្ថយដើមល្ហុង និងចេកខ្លះ ។ ក្នុងមួយថ្ងៃប្រធានកងឲ្យគាត់ហូបតែ២ពេលប៉ុណ្ណោះហើយពេលហូប គឺមានអ្នកនៅចាំមើលជានិច្ច មិនមែនញាំសេរីបាននោះទេ ។ សម្រាប់ទឹកវិញ គឺគាត់ត្រូវដាំផឹកដោយខ្លួនឯង

ប៉ុន្តែដោយហេតុថាអង្គការមិនឲ្យមានផែ្សងចេញពីផ្ទះដូច្នេះហើយ ភាគច្រើនគាត់ដឹកទឹកឆៅជំនួសវិញ ។

ពេលនោះមានជំងឺគ្រុនចាញ់ គ្រុនឈាមកើតឡើង ដូច្នេះម្តាយរបស់ខ្ញុំត្រូវបង្ខំចិត្តយកមាសដែលមាននៅក្នុងខ្លួនបន្តិចបន្តួចទៅដូរយកថ្នាំមកព្យាបាល ប៉ុន្តែបន្ទាប់ពីចាយវាយអស់គ្មានអ្វីទៀត ក្រៅពីបុកស្លឹកស្តៅដាក់ដឹកនោះទេ ។

ជីវិតម្តាយរបស់ខ្ញុំពេលនោះគ្មានអ្វី ក្រៅពីភ្ញាក់ពីដេក ហូបបបររួមគ្នា មុនចូលដេកត្រូវប្រៀងបទបដិវត្តន៍ទាំងពោះទទេនោះទេ ។ របបអាហារនៅពេលគាត់កំពុងប្រូតគឺអង្គការឲ្យហូបតែបបរប៉ុណ្ណោះ ប៉ុន្តែនៅពេលប្រូតស្រូវបានខ្លះអង្គការចាប់ផ្តើមឲ្យហូបបាយ តែប្រែមកជាបបរវិញនៅពេលប្រូតហើយ ។

រហូតមកដល់ឆ្នាំ១៩៧៦ អង្គការចាប់បង្ខំម្តាយរបស់ខ្ញុំឲ្យរៀបការជាមួយអ្នកដែលមិនធ្លាប់ស្គាល់គ្នាពីមុនមក ដោយហេតុថា គាត់ធ្លាប់មានប្រវត្តិជាសិស្ស ហើយអ្នកដែលអង្គការឲ្យការជាមួយនោះមានប្រវត្តិជានិស្សិត ។ នៅពេលរៀបការនោះ ពុំមានពិធីតាមប្រពៃណីត្រឹមត្រូវនោះទេ គឺគ្រាន់តែឲ្យចាប់ដៃគ្នាហើយប្តេជ្ញានៅមុខគណៈអធិបតីថា « យើងទាំងពីរគោរព តាមអង្គការចាត់តាំងពីពេលនេះ បើថ្ងៃក្រោយក្បត់នឹងអង្គការមានតែកាំភ្លើងធ្វើជាសាក្សី » ។ ពេលដែលបានគ្នាជាប្តី ប្រពន្ធហើយគាត់ពុំបាននៅស្ថិតស្ថិរមួយកន្លែងនោះទេ គឺត្រូវផ្លាស់ប្តូរទីកន្លែងរហូតហើយក៏មិនបានដឹងថាពីមួយកន្លែងទៅមួយកន្លែងនៅរស់បានរយៈពេលប៉ុន្មានដែរ ។

នៅឆ្នាំ១៩៧៧ គាត់មានកូនមួយ ពេលនោះអង្គការឲ្យគាត់នៅមើលកូនទា ស្រាប់តែពេលនោះអង្គការបានចាប់ឪពុកទៅឃុំឃាំងដោយចោទថាជាខ្មាំងបង្កប់ខ្លួន ប៉ុន្តែសំណាងល្អមានប្រជាជនចាស់ស្គាល់ ទើបអង្គការព្រមដោះលែងមកវិញ ។ ប៉ុន្មានថ្ងៃក្រោយមក កងទ័ពវៀតណាមក៏ចូលមករំដោះ ហើយគាត់នឹងគ្រួសារក៏បានវិលត្រឡប់ទៅរស់នៅផ្ទះចាស់វិញបានប្រមាណជា៤ទៅ៥ខែក៏ត្រូវបានយោធាខ្មែរក្រហមមកកៀងចូលព្រៃវិញទៀត តែដោយសារគាត់ដឹងមុនបានរត់ចេញពីផ្ទះ ដោយមិនបានយកអ្វីតាមខ្លួនទាំងអស់ក្រៅពីខោអាវនៅជាប់នឹងខ្លួន ។

ម្តាយរបស់ខ្ញុំផ្លាស់ទីលំនៅពីកន្លែងមួយទៅកន្លែងមួយ ហើយនៅក្នុងឆ្នាំ១៩៨១ ប្តីរបស់គាត់បានមកទីក្រុងភ្នំពេញរកការងារធ្វើ ។ ១ឆ្នាំក្រោយមកគាត់ក៏មករស់នៅជាមួយឪពុកខ្ញុំ ប៉ុន្តែជីវភាពមិនងាយស្រួលដូចដែលបានគិតនោះទេ នៅពេលមកដល់ទីក្រុងគាត់បានសុំគេរស់នៅជាមួយមួយរយៈដោយជួយមើលផ្ទះឲ្យគេ ។ ក្រោយពីការសន្សំសំចៃ ម្តាយខ្ញុំ និងគ្រួសារមានលទ្ធភាពទិញផ្ទះតូចល្មម ព្រោះជីវភាពនៅខ្វះខាតនៅឡើយ ។

ការរស់នៅក្នុងទីលំនៅថ្មីនោះមានការលំបាកខ្លាំងព្រោះថាមានចោរច្រើនធ្វើឲ្យមានការភ័យខ្លាច ។ ម្យ៉ាងនាពេលនោះ ពុំមានផ្លូវថ្នល់ស្រួលនោះទេ នៅខាងមុខផ្ទះមានទឹកលិចជោគជាំ និងពិបាកក្នុងការមើលថែកូន ។ បន្ថែមពីលើនេះគឺជីវភាពដ៏លំបាក ខ្វះមុខខ្វះក្រោយ សឹងតែមិនអាចផ្គត់ផ្គង់ការរស់នៅរបស់កូនបាន ។

រហូតមកដល់ជំនាន់ អ៊ុនតាក់ (UNTAC) គ្រួសារក៏មានភាពល្អប្រសើរឡើងដោយប្តីរបស់គាត់ទទួលបានការងារសមរម្យមួយធ្វើនឹងមានចំណូលសមល្មមនឹងឲ្យកូនទៅរៀនបាន ។ ដោយទទួលបានការជ្រោមជ្រែងពីមិត្តជនជាតិបរទេសធ្វើការនៅកន្លែងជាមួយគ្នា ប្តីរបស់គាត់មានឱកាសច្រើនក្នុងការពង្រីកចំណេះដឹងនឹងបទពិសោធន៍ផ្សេងៗដែលជាគ្រឹះមកទល់សព្វថ្ងៃ ។

ដោយសារតែការតស៊ូយ៉ាងលំបាកពីមួយរបបទៅមួយរបបមកដល់សព្វថ្ងៃ ឪពុកម្តាយខ្ញុំទើបទទួលបានជីវភាពសមរម្យមួយ ប៉ុន្តែនៅតែមិនអាចប៉ះប៉ូវពេលវេលាដែលគាត់ទាំងពីរបានឆ្លងកាត់នោះទេ ។

ការតស៊ូរបស់ម្តាយខ្ញុំ ជាមូលហេតុមួយដែលក្មេងជំនាន់ក្រោយគួរយល់ដឹង ព្រោះក្មេងៗក្នុងជំនាន់នេះអាចចំណាយភាពយុវវ័យរបស់ខ្លួនធ្វើអ្វីដែលខ្លួនស្រលាញ់ ចំណែកគាត់វិញបានចំណាយភាពជាយុវវ័យនៅក្នុងសម័យកាលមួយដែលសូម្បីតែការសិក្សាក៏មិនអនុញ្ញាត ហើយត្រូវបែកពីគ្រួសារ និងត្រូវធ្វើការងារដោយបង្ខំ ។

ថ្វីបើ្បតែការរៀបរាប់របស់គាត់គឺជារឿងឈឺចាប់ក៏ពិតមែន ប៉ុន្តែវាជាការឈឺចាប់មួយដែលត្រូវរំលឹកឡើង ដើម្បីដាស់តឿនក្មេងជំនាន់ក្រោយឲ្យដឹងថាទំរាំមកដល់ថ្ងៃនេះ មានមនុស្សមិនតិចទេដែលបានបាត់បង់ជីវិត ហើយក៏ជាការអប់រំដើម្បីជៀសវាងការកើតឡើងរបបនេះម្តងទៀត ។

**ហ៊ុន កែវលីដែត**

# សៀវភៅរំឭកវិញ្ញាណក្ខន្ធអ្នកដែលបានស្លាប់
# នៅក្នុងរបបខ្មែរក្រហម










មជ្ឈមណ្ឌលឯកសារកម្ពុជា គ្រោងនឹងបោះពុម្ពផ្សាយនូវសៀវភៅមានកត់ត្រាឈ្មោះរបស់អ្នកដែលស្លាប់បាត់បង់ជីវិតនៅក្នុងរបបខ្មែរក្រហម ។ កន្លងមក មជ្ឈមណ្ឌលឯកសារកម្ពុជាបានចងក្រងនូវឈ្មោះអ្នកដែលស្លាប់ជាង១លាននាក់រួចមកហើយ ។ ប្រសិនបើលោកយាយ លោកតា អ៊ំ ពូ មីង ប្រាថ្នាចង់ឲ្យឈ្មោះសមាជិកក្រុមគ្រួសារដែលបានស្លាប់បាត់បង់ជីវិតមាននៅក្នុងសៀវភៅនេះ សូមទាក់ទងមកកាន់មជ្ឈមណ្ឌលឯកសារកម្ពុជាតាមរយៈ ញ៉ាណ សុជាតិ ទូរស័ព្ទលេខ ០៧០ ៩៨៨ ៦៦៦ ឬ អ៊ីម៉ែល ៖ truthsocheat@dccam.org ឲ្យបានឆាប់រហ័សតាមពេលវេលាដែលអាចធ្វើទៅបាន ។

***សូមផ្តល់ព័ត៌មានដូចខាងក្រោមៈ***

១) ឈ្មោះអ្នកប្រកាសប្រាប់, ២) តើមានបងប្អូនបង្កើតរួមទាំងឪពុកម្តាយស្លាប់ប៉ុន្មាននាក់នៅក្នុងសម័យខ្មែរក្រហម? ៣) ឈ្មោះអ្នកស្លាប់, ៤) ភេទអ្នកស្លាប់, ៥) អាយុអ្នកស្លាប់ (បើអាចចាំបាន), ៦) ត្រូវជាអ្វីនឹងអ្នកប្រកាស (ឧទាហរណ៍ៈ ឪពុក ម្តាយ បងប្រុស ប្អូនប្រុស បងស្រី ប្អូនស្រី), ៧) សាច់រឿងទាក់ទងនឹងការស្លាប់ (ឧទាហរណ៍ ៖ ស្លាប់នៅទីណា? មូលហេតុអ្វី?), ៨) វត្ថុតាងទាក់ទងនឹងអ្នកស្លាប់ (ឧទាហរណ៍ៈ រូបថត ឯកសារ ឬវត្ថុផ្សេងៗ), ៩) ព័ត៌មានសម្រាប់មជ្ឈមណ្ឌលទាក់ទង (ឧទាហរណ៍ៈ លេខទូរស័ព្ទ អាសយដ្ឋាន) ។

***ប្រសិនបើចង់ស្វែងរកអ្នកដែលបាត់ខ្លួនសូមផ្តល់ព័ត៌មានខាងក្រោមៈ***

១) ឈ្មោះអ្នកបាត់ខ្លួន, ២) ភេទ, ៣) អាយុ, ៤) ត្រូវជាអ្វី, ៥) សាច់រឿងទាក់ទងនឹងការបែកគ្នា, ៦) វត្ថុតាងទាក់ទងនឹងអ្នកបាត់ខ្លួន (ឧទាហរណ៍ៈ រូបថត ឯកសារ ឬវត្ថុផ្សេងៗ) ។

ដើម្បីយុត្តិធម៌និងការចងចាំ
ដែលជាមូលដ្ឋានដ៏សំខាន់ក្នុងការផ្សះផ្សាជាតិ

ឧបត្ថម្ភការបោះពុម្ពផ្សាយដោយ ទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិ សហរដ្ឋអាមេរិក (USAID)
អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មានលេខ ០២៩១ពម.៩៩ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

**មជ្ឈមណ្ឌលឯកសារកម្ពុជា ៖ ការិយាល័យព័ត៌មានសាធារណៈ**
ផ្ទះលេខ ៦៦, មហាវិថីព្រះសីហនុ ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ ៖ (៨៥៥) ២៣ ២១១ ៨៧៥ ទូរសារ ៖ (៨៥៥) ២៣ ២១០ ៣៥៨

DC-Cam/PIR : #66 ◆ Preah Sihanouk Blvd ◆ Phnom Penh ◆ Cambodia ◆ Tel: (855) 23 211 875 ◆ Fax: (855) 23 210 358 ◆ dccam@online.com.kh ◆ www.dccam.org.

A magazine of the Documentation Center of Cambodia: Searching for the truth. ◆ Number 200, 2016 ◆ Funded by USAID.
Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No.0291 P.M/99, 2 August 1999.